**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale De Droit et Des Sciences Économiques
Royal University Of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះៈ **ក. ខ្លួន សុជាតា**
**ក. ឌឹម បូរី**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ឃឹម ម៉ាំណែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាបឋម កូនសូមលំឱនកាយក្រាបថ្វាយបង្គំដោយកិច្ចប្រណិប័តន៍ សម្តែងនូវកតញ្ញូយ៉ាងជ្រាលជ្រៅបំផុតជូនលោកឪពុកអ្នកម្តាយ ដែលបានបង្កើតរូបរាងកាយ និង ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅឱ្យកូនបានសិក្សារៀនសូត្ររហូតទទួលបាននូវជោគជ័យដូចសព្វថ្ងៃនេះ នេះជាគុណូបការៈជាអនេកប្បការ និង វិសេសវិសាលខ្ពង់ខ្ពស់ថ្លៃថ្លាបំផុតមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងទ្វេ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំទាំងពីរក៏សូមធ្វើការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម បណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ដែលបានគ្រប់គ្រងដឹកនាំសាកលវិទ្យាល័យ និង បានខិតខំប្រឹងប្រែងបំពេញកាតព្វកិច្ច តាមមុខងារ ដោយអស់ពីកម្លាំងកាយចិត្ត និង បញ្ញាស្មារតី ក្នុងគោលបំណងកសាងធនធានមនុស្សប្រកបទៅដោយសមត្ថភាពគ្រប់គ្រាន់ ពោលសំដៅដល់ធនធានមនុស្សដែលមានវិជ្ជាជីវៈខ្ពស់ មានក្រមសីលធម៌ គុណធម៌ ដែលស្របតាមគោលដៅត្រូវការរបស់សង្គមប្រជាជាតិ នាពេលបច្ចុប្បន្ន និង អនាគត។

លើសពីនេះទៀត សូមថ្លែងអំណរគុណជូនដល់ ឯកឧត្តម នាយឧត្តមសេនីយ៍ **កង សុខន** អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរចុះធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានទាក់ទងនឹងប្រធានបទ **ការផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋនៅកម្ពុជា** មួយនេះ។ ព្រមទាំងសូមថ្លែងអំណរគុណដល់ ក្រុមការងារ នាយកដ្ឋាន អត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលបាន ណែនាំ ផ្តល់នូវពុទ្ធិដ៏មានតម្លៃ និង ឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីជាជំនួយក្នុងការសរសេរសៀវភៅនេះឡើង។

ដូចគ្នានេះដែរ ក៏សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដោយឡែកជូនចំពោះ អ្នកគ្រូសាស្ត្រាចារ្យ **ឃឹម ម៉ាណែត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន និង បានផ្តល់នូវដំបូន្មានល្អៗ ព្រមទាំងបទពិសោធន៍ផ្សេងៗជាច្រើន ដែលទាំងអស់នេះហើយសុទ្ធតែជាគំនិតក្នុងការដែលធ្វើឱ្យយើងខ្ញុំអាចតាក់តែងកិច្ចការស្រាវជ្រាវមួយនេះ ។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនស្នាដៃនិងគុណតម្លៃទាំងឡាយ ដែលបានទទួលពីការសិក្សាស្រាវជ្រាវមួយនេះ ជូនចំពោះអស់លោកអ្នកដែលមានគុណ ដូចដែលយើងខ្ញុំបានរៀបរាប់ខាងលើ។ យើងខ្ញុំសូមប្តេជ្ញាចិត្តថានឹងយកនូវ ចំណេះដឹង បញ្ញា ស្មារតី កម្លាំងកាយចិត្ត ដែលមានទៅជួយសង្គមកម្ពុជាមួយនេះ ឱ្យសមនឹងការតបស្នងជួយជ្រោមជ្រែងដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នា។ ជាមួយគ្នានេះដែរក៏សូមប្រសិទ្ធិពរជ័យ ជូនដល់អស់លោក លោកស្រី ឱ្យទទួលនូវសុខសុភមង្គលគ្រប់ពេលវេលាតរៀងទៅ។

# អារម្ភកថា

ប្រធានបទនៃកិច្ចការស្រាវជ្រាវស្តីពី **ការផ្តល់សេវាអគ្រានុកូលដ្ឋានជូនប្រជាពលរដ្ឋនៅកម្ពុជា** មួយនេះ គឺជាសមិទ្ធិផលដែលសម្រេចបានពីការខិតខំប្រឹងប្រែងរបស់ក្រុមនិស្សិតយើងខ្ញុំ។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការចំណាយនូវកម្លាំងកាយចិត្ត ដើម្បីរៀបចំនូវកិច្ចការមួយនេះឱ្យលេចចេញជារូបរៀងឡើង ព្រោះកិច្ចការមួយនេះបានធ្វើឱ្យយើងខ្ញុំចេះធ្វើកិច្ចការស្រាវជ្រាវ បង្កើននូវចំណេះ បណ្តុះគំនិតប្រាជ្ញា និងយល់ដឹងកាន់តែច្បាស់អំពីប្រធានបទមួយនេះ។

ក្រុមយើងខ្ញុំសង្ឃឹមនិងរំពឹងទុកជាមុនថា កិច្ចការមួយនេះនឹងអាចក្លាយជាប្រយោជន៍សម្រាប់មជ្ឈដ្ឋានអ្នកស្នេហាការសិក្សាទាំងឡាយ មិត្តនិស្សិត ក៏ដូចជាសិស្សានុសិស្សជំនាន់ក្រោយ ដោយចូលរួមក្នុងការបង្កើននូវពុទ្ធិ ចំណេះដឹងមូលដ្ឋានរបស់អ្នករាល់គ្នា ។

ដោយសារតែចំណេះដឹងនៅមានកម្រិត ហើយកង្វះខាតនូវឯកសារសម្រាប់ស្រាវជ្រាវ ដូច្នេះយើងខ្ញុំទាំងពីរនៅជឿជាក់ថាកំហុសឆ្គងនៅតែកើតមានឡើងដោយចៀសពុំរួចនោះឡើយ ទាំងអត្ថន័យខ្លឹមសារ ពាក្យពេចន៍ឃ្លោងឃ្លា ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រងនៅមានកម្រិតផងនោះ ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលនឹងអាចកើតមានពីសំណាក់លោកគ្រូសាស្ត្រាចារ្យ និង មិត្តនិស្សិតទាំងអស់ ហើយក៏រីករាយនឹងទទួលយកនូវការរិះគន់ដើម្បីជាទុនក្នុងការកែលម្អ និង ធ្វើឱ្យការសិក្សាស្រាវលើកក្រោយមានភាពល្អប្រសើរឡើង។

រាជធានីភ្នំពេញថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០២០

# មាតិកា

ទំព័រទី

**ពាក្យគន្លឹះ** ................................................ iii
**អក្សរកាត់** ................................................ vi
**សេចក្ដីផ្ដើម** ................................................ ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ................................................ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ................................................ ១
៣. គោលបំណងនៃការស្រាវជ្រាវ................................................ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ................................................ ២
៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ................................................ ២
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ................................................ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................ ៤

**ជំពូកទី១**

**សាវតានៃអត្រានុកូលដ្ឋាន**

**១.១.ទិដ្ឋភាពសង្គម** ................................................ ៥
១.១.១. មុនទសវត្សឆ្នាំ ១៩៧០ ................................................ ៥
១.១.២. ក្នុងកំឡុងទសវត្សឆ្នាំ ១៩៧០ - ១៩៧៩ ................................................ ៦
១.១.៣. ចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់មានអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានឆ្នាំ២០០០................ ៧
១.១.៤. ក្រោយមានអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានឆ្នាំ២០០០................................................ ៧
**១.២.ទិដ្ឋភាពច្បាប់** ................................................ ១២
១.២.១. ការវិវត្តនៃលិខិតបទដ្ឋានគតិយុត្ត ................................................ ១២
១.២.២. ការវិវត្តនៃការិយាល័យកំណត់អត្តសញ្ញាណប្រជាពលរដ្ឋ ................................................ ១២
១.២.៣. និយមន័យ (កំណើត, អាពាហ៍ពិពាហ៍, មរណភាព) ................................................ ១៤
១.២.៤. ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្ត ................................................ ១៥
១.២.៥. ថ្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋាន ................................................ ១៩
១.២.៦. បម្រាម និងការទទួលខុសត្រូវចំពោះមុខច្បាប់ស្ដីពីការងារអត្រានុកូលដ្ឋាន ................ ២០

**ជំពូកទី២**

**នីតិវិធី នៃការស្នើសុំលិខិតអត្រានុកូលដ្ឋាន**

**២.១. អត្រានុកូលដ្ឋានកំណើត** ................................................ ២២
២.១.១. សញ្ញាណនៃអត្រានុកូលដ្ឋានកំណើត................................................ ២២
២.១.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត................................................ ២៣
២.១.៣. នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋាន................................................ ២៣

២.១.៤. នីតិវិធីនៃការស្នើសុំសេចក្តីចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត........................២៧
**២.២. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍**................................................................................២៨
២.២.១. សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍ .........................................................................២៨
២.២.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ ....................................................៣០
២.២.៣. នីតិវិធីនៃការស្នើសុំសំបុត្រអាពាហ៍ពិពាហ៍ ...............................................................៣០
២.២.៤. នីតិវិធីនៃការស្នើសុំសំបុត្រចម្លង និង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ................................៣៤
**២.៣. អត្រានុកូលដ្ឋានមរណភាព**..........................................................................................៣៥
២.៣.១. សញ្ញាណនៃមរណភាព.........................................................................................៣៥
២.៣.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព ...........................................................៣៥
២.៣.៣. នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋានមរណភាព ..................................................៣៦
២.៣.៤. នីតិវិធីនៃការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានមរណភាព ................................៣៩

**ជំពូកទី៣**

**សារៈសំខាន់ បញ្ហាប្រឈម និងដំណោះស្រាយ**

**៣.១. សារៈសំខាន់អត្រានុកូលដ្ឋាន** .......................................................................................៤៣
៣.១.១. ចំពោះសង្គមជាតិ.................................................................................................៤៤
៣.១.២. ចំពោះខ្លួនយើង...................................................................................................៤៤
**៣.២. បញ្ហាប្រឈម និង ដំណោះស្រាយ**.....................................................................................៤៥
៣.២.១. បញ្ហាប្រឈម.......................................................................................................៤៥
៣.២.២. ដំណោះស្រាយ....................................................................................................៥២
**សេចក្តីសន្និដ្ឋាន**.......................................................................................................................៥៨
**អនុសាសន៍** ..........................................................................................................................៦០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ពាក្យគន្លឹះ

**កំណើត :** គឺជាព្រឹត្តិការណ៍គតិយុត្តនាំឱ្យកើតមាននូវរូបវន្តបុគ្គលពោល គឺជាការចាប់ផ្ដើមកកើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់ៗរូប។

**បទដ្ឋានគតិយុត្ត** : វិធានច្បាប់ដូចជា ច្បាប់ និងបទបញ្ញាផ្សេងៗ ដែលបានបង្កើតឡើងដោយរដ្ឋ វិធានច្បាប់ដែលនាំឱ្យមានតម្លៃបង្ខិតបង្ខំ (តម្រូវឱ្យអនុវត្តតាម) ទោះបីចេញពីប្រភពណាក៏ដោយ (ច្បាប់ សន្ធិសញ្ញា ...)។

**បុគ្គលឯកជន** : បុគ្គល ដែលមានសិទ្ធិ និងកាតព្វកិច្ចនៅក្នុងទំនាក់ទំនងគតិយុត្ត និងដែលត្រូវគ្រប់គ្រងដោយនីតិឯកជន។

**បញ្ជីប្រជាជន** : សំដៅលើបណ្ដុំទិន្នន័យរបស់បុគ្គលម្នាក់ៗដូចជា នាម គោត្តនាម ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត សញ្ជាតិ ស្ថានភាពពលរដ្ឋ ស្ថានភាពអាពាហ៍ពិពាហ៍ ឈ្មោះឪពុក ម្ដាយ កូន អាសយដ្ឋាន ទីសំណាក់ ព័ត៌មាន ជីវសាស្ត្រនិងទិន្នន័យអំពីឯកសារអត្តសញ្ញាណកម្មនានាដែលបានចេញឱ្យដោយអាជ្ញាធរ។

**ប្រជាជន** : សំដៅលើមនុស្សទាំងអស់ដែលរស់នៅក្នុងទីក្រុង តំបន់ ឬប្រទេសណាមួយ។ បើតាមសទ្ទានុក្រមប្រជាសាស្ត្រ បោះពុម្ពឆ្នាំ២០០៨ ដោយទីស្ដីការគណៈរដ្ឋមន្ត្រី ពាក្យប្រជាជនមានន័យថា ក្រុមនៃវត្ថុសារពាង្គកាយដែលមានប្រភេទដូចគ្នា។ ក្នុងន័យប្រជាសាស្ត្រ ប្រជាជនគឺជាមនុស្សដែលរស់នៅក្នុងប្រទេសណាមួយ ឬមានលក្ខណៈសម្គាល់ ប្រជាសាស្ត្រ សង្គម ឬសេដ្ឋកិច្ចរួម ដូចជា ភេទ អាយុ ប្រភេទកន្លែងរស់នៅ (ជនបទ ឬទីប្រជុំជន) ស្ថានភាពបំលាស់ទី ។ល។

**ប្រព័ន្ធរួមអត្តសញ្ញាណកម្ម** : គឺជាប្រព័ន្ធប្រតិបត្តិបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារ ប្រមូលផ្ដុំទិន្នន័យពលរដ្ឋជាឌីជីថល សម្រាប់ឱ្យស្ថាប័នផ្សេងៗនិង សម្រាប់ប្រព័ន្ធរបស់ស្ថាប័ននោះប្រើប្រាស់ជាប្រភពទិន្នន័យពលរដ្ឋចម្បងនិងតែមួយគត់។ ប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជនអាចដំណើរការបាន លុះត្រាតែមានការភ្ជាប់ទំនាក់ទំនង និងបញ្ចូលគ្នារវាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ នៅលើមូលដ្ឋានពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ នៅក្នុងគោលបំណងធានាឱ្យមានលទ្ធភាពនៅក្នុងការស្វែងរកទិន្នន័យត្រឹមត្រូវ និងពិតប្រាកដអំពីបុគ្គល។

**ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** : គឺជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារគ្រប់គ្រង ប្រមូល បញ្ជូន រក្សាទុកទិន្នន័យ ផ្ទៀងផ្ទាត់ជីវមាត្រ និងផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

**ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន** : គឺជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានមុខងារគ្រប់គ្រង ប្រមូល បញ្ជូន រក្សាទុកទិន្នន័យ ផ្ទៀតផ្ទាត់ជីវមាត្រ និងផលិតលិខិតឆ្លងដែនធម្មតា។

**ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ** : គឺជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារគ្រប់គ្រង ប្រមូល បញ្ជូន រក្សាទុកទិន្នន័យស្ដីពីការស្នាក់នៅ និងផលិតសៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ។

**ប្រព័ន្ធគ្រប់គ្រងសញ្ជាតិ** : គឺជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារគ្រប់គ្រង ប្រមូល បញ្ជូន រក្សាទុកទិន្នន័យការងារសញ្ជាតូបនីយកម្មនិងការលះបង់សញ្ជាតិខ្មែរ។

**ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន** : គឺជាប្រព័ន្ធប្រតិបត្តិការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារគ្រប់គ្រង ប្រមូល រក្សាទុកទិន្នន័យអត្រានុកូលដ្ឋាន និងផលិត ចម្លង សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ព្រមទាំងផលិតស្ថិតិអត្រានុកូលដ្ឋាន។

**ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន** : ជាបណ្តុំឧបករណ៍ កម្មវិធី និងបរិក្ខារកុំព្យូទ័រដែលត្រូវបានរៀបចំ និងប្រើប្រាស់បញ្ចូលគ្នា ក្នុងគោលបំណងសម្រាប់បង្កើត ទទួលរក្សាទុកប្រតិបត្តិការចែករំលែក និងបញ្ជូនទិន្នន័យនិងព័ត៌មានពីចម្ងាយតាមគ្រឿងអេឡិចត្រូនិច ដូចជា កុំព្យូទ័រ ទូរស័ព្ទ ទូរទស្សន៍ និងវិទ្យុ (ទាំងអាណាឡូក ទាំងឌីជីថល)។

**ពលរដ្ឋ** : សំដៅលើមនុស្សទាំងឡាយដែលបានទទួលស្គាល់តាមផ្លូវច្បាប់ថាជាសញ្ជាតិនៃរដ្ឋមួយទោះបីជាមនុស្សនោះជាជនជាតិដើម ឬបានទទួលសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្មក៏ដោយ។

**ព្រឹត្តិការណ៍ជីវិត** : សំដៅទៅលើព្រឹត្តិការណ៍នៃកំណើតរស់ មរណភាព មរណភាពគភ៌ ការរៀបអាពាហ៍ពិពាហ៍ ការសុំកូន ធម្មានុរូបកម្ម ការទទួលស្គាល់បុត្តភាព មោឃភាពអាពាហ៍ពិពាហ៍ ឬក៏ការលែងលះតាមផ្លូវច្បាប់ជាដើម។

**មរណភាព :** គឺជាព្រឹត្តការណ៍គតិយុត្ត ដែលបុគ្គលិកលក្ខណៈគតិយុត្តរបស់រូបវ័ន្តបុគ្គលនោះត្រូវបានបញ្ចប់។

**លេខកូដអត្តសញ្ញាណខ្មែរ** : ជាអត្តលេខពិសេសសម្រាប់សម្គាល់ខ្លួនបុគ្គលម្នាក់ៗឱ្យដាច់ពីគ្នា។ លេខកូដនេះត្រូវមានចំនួនដប់ខ្ទង់ បង្កើតឡើងដោយរបៀបចៃដន្យ មួយខ្ទង់ជាលេខបម្រុង ប្រាំបីខ្ទង់ជាលេខកំណត់ដោយចៃដន្យ និងមួយខ្ទង់ទៀតជាលេខផ្ទៀងផ្ទាត់ (Checksum) ដោយផ្អែកលើរូបមន្ត Modoul11 Algorithm។ លេខកូដនេះនឹងត្រូវប្រើប្រាស់ពេញមួយជីវិតរបស់បុគ្គល។

**ស្ថិតិអត្រានុកូលដ្ឋាន** : គឺជាទិន្នន័យបរិមាណទាក់ទងនឹងប្រជាជន ដូចជា ចំនួនកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ឬក៏ចង្អោមទិន្នន័យជាផ្លូវការដែលបានបង្ហាញអំពីស្ថានភាពពិតនៃព្រឹត្តិការណ៍កំណើត អាពាហ៍ពិពាហ៍ និងមរណភាពនៅក្នុងប្រទេសឬតំបន់ណាមួយ។ និយាយម្យ៉ាងទៀត ស្ថិតិអត្រានុកូលដ្ឋានគឺការចងក្រងនិងវិភាគលើព័ត៌មានដែលប្រមូលបានពីកំណត់ត្រាព្រឹត្តិការណ៍ជីវិតទាំងអស់ ហើយស្ថិតិនេះនឹងប្រើប្រាស់សម្រាប់រដ្ឋបាលនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិក្នុងការវិភាគលើនិន្នាការសុខាភិបាល ការរៀបចំកម្មវិធីនិងគោលនយោបាយអភិវឌ្ឍជាដើម។ ផ្អែកលើស្ថិតិនេះគេអាចធ្វើការបែកចែកតាមប្រភេទទិន្នន័យទៅតាមលក្ខណៈពិសេសណាមួយដែលគេចង់បាន។

**សុំកូន** : សុំកូនចែកចេញជាពីរគឺ សុំកូនធម្មតានិងសុំកូនពេញលេញ។ សុំកូនធម្មតាគឺការសុំកូនដែលកូននោះអាចជាអនីតិជន ឬនីតិជន ដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំកូននេះត្រូវ

សម្រេចដោយតុលាការ។ ការសុំកូនពេញលេញគឺការសុំអនីតិជនដែលមានអាយុក្រោម៨ឆ្នាំយកធ្វើជាកូនសុំដោយបញ្ចប់ញាតិជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត ហើយការសុំកូននេះត្រូវសម្រេចដោយតុលាការ។

**សំបុត្រអត្រានុកូលដ្ឋាន :** គឺជាសំបុត្រសម្រាប់កត់ត្រាភាពស៊ីវិល នៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ក្នុងដែនសមត្ថកិច្ចកំណត់នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

**សហព័ទ្ធ** : ប្ដី ឬប្រពន្ធ ឬទាំងប្ដី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

**អត្តាធីនភាព** : ស្ថានភាពមួយ ដែលផ្ដល់ឱ្យអនីតិជនបានរួចផុត ពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

**អត្រានុកូលដ្ឋាន :** គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្ដែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួនក្នុងសង្គមជាតិ និង ដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច។

**អត្តសញ្ញាណកម្ម** : កិច្ចការរបស់រដ្ឋដែលធានាឱ្យប្រជាជនគ្រប់រូបកើតមានអត្តសញ្ញាណជាក់លាក់ខាងផ្លូវច្បាប់ក្នុងគោលបំណងលើកកម្ពស់ការអនុវត្តសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បង្កើនប្រសិទ្ធិភាពនៃការផ្ដល់សេវាសាធារណៈជូនប្រជាជនជាដើម។

**អត្តសញ្ញាណប័ណ្ណ** : លិខិតជាផ្លូវការនៃអត្តសញ្ញាណ សំបុត្រជាគ្រឿងសម្គាល់ខ្លួនមនុស្ស សត្វ និងវត្ថុផ្សេងៗ។

**អាពាហ៍ពិពាហ៍ :** គឺជាកិច្ចសន្យាដ៏ឱឡារិកដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ។

# អក្សរកាត់

- ADB : ធនាគារអភិវឌ្ឍន៍អាស៊ី
- JICA : ភ្នាក់ងារសហប្រតិបត្តិការកម្ពុជា-ជប៉ុន
- MoI : ក្រសួងមហាផ្ទៃ
- MoH : ក្រសួងសុខាភិបាល
- MoP : ក្រសួងផែនការ
- UNHCR : ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន
- URC : សាកលវិទ្យាល័យស្រាវជ្រាវ
- UNFPA : មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន
- UNICEF : មូលនិធិអង្គការសហប្រជាជាតិសម្រាប់ការអប់រំកុមារអន្តរជាតិ
- USAID : ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
- WHO : អង្គការសុខភាពពិភពលោក

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការទទួលបានសេវា និង ការចុះបញ្ជីអត្រានុកូលដ្ឋានបានផ្តល់ផលប្រយោជន៍ជាច្រើនដល់បុគ្គលម្នាក់ៗ ក៏ដូចជាសង្គមជាតិផងដែរ។ ការចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាមធ្យោបាយតែមួយគត់នៃការបង្កើត និងការការពារអត្តសញ្ញាណប្រជាពលរដ្ឋ និងសិទ្ធិទាក់ទងនឹងបុគ្គលភាពគតិយុត្តនៃបុគ្គលមួយរូបៗ។ ឯកសារគតិយុត្តដែលបញ្ជាក់ពីអត្តសញ្ញាណ និងភាពជាប្រពលរដ្ឋមិនមែនត្រឹមតែផ្តល់នូវការប្រើប្រាស់របស់រដ្ឋ ឬការផ្ទេរសិទ្ធិនោះទេ ប៉ុន្តែក៏អាចជាការការពារប្រឆាំងនឹងការកេងប្រវ័ញ្ចលើរូបវ័ន្តបុគ្គលផងដែរ។ ដូច្នេះហើយទើបការចុះសៀវភៅអត្រានុកូលដ្ឋាន ដើរតួនាទីដ៏សំខាន់ចាំបាច់ក្នុងការផ្តល់នូវឯកសារគតិយុត្តជូនប្រជាពលរដ្ឋទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និង មរណភាព។ ឯកសារគតិយុត្តទាំងនេះ គឺជាឯកសារ និងជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗ សម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ និង ស្ថានភាពស៊ីវិលរបស់ខ្លួន ក្នុងគោលដៅលើកស្ទួយនូវសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗ នៅក្នុងត្រកូលគ្រួសារខ្លួន និង សង្គមជាតិ ។ មកដល់បច្ចុប្បន្នការវិវត្តនៃលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹង អត្រានុកូលដ្ឋាន មានការផ្លាស់ប្តូរ កែប្រែ និងបន្ថែមថ្មី ជាច្រើនដំណាក់កាល ដែលជាហេតុធ្វើឱ្យការអនុវត្ត និងការផ្តល់សេវាអត្រានុកូលដ្ឋានទៅកាន់ប្រជាពលរដ្ឋនៅមានភាពខ្វះចន្លោះនៅឡើយ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល។ ជាក់ស្តែងក្នុងនាមជាអាជ្ញាធរនៃមូលដ្ឋានរបស់ខ្លួន ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាអ្នកទទួលខុសត្រូវលើការរៀបចំឯកសារអត្រានុកូលដ្ឋានទាំងនេះ។ រាល់ពលរដ្ឋខ្មែរទាំងអស់ មានតួនាទីដើម្បីស្នើសុំការចុះអត្រានុកូលដ្ឋានរបស់ពួកគេ នៅក្នុងសៀវភៅបញ្ជីអត្រានុកូលដ្ឋាន។ ចំពោះជនណាដែលផ្តល់ព័ត៌មានមិនពិត ឬស្នើសុំការចុះបញ្ជីលើសពីមួយនៅទីកន្លែងតែមួយ ឬនៅកន្លែងផ្សេងគ្នា អាចនឹងរងការផាកពិន័យ និងផ្តន្ទាទោសទៅតាមច្បាប់។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ផ្អែកលើលំនាំបញ្ហាខាងលើយើងឃើញថា ទោះបីជាមានច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធច្រើនយ៉ាងណាក៏ដោយ ក៏នៅតែមាននូវចន្លោះប្រហោងដែលបង្កឱ្យការអនុវត្តការងារអត្រានុកូលដ្ឋាន ជួបនូវបញ្ហាប្រឈមនានាកើតមានឡើង។ ក្រុមយើងខ្ញុំ បានដាក់ចេញនូវបញ្ហាស្រាវជ្រាវមួយចំនួន ដើម្បីធ្វើការស្រាវជ្រាវរកដំណោះស្រាយមួយចំនួនដែលជាប្រយោជន៍ដល់ស្ថាប័នអនុវត្តដូចជា៖

១.តើការងារអត្រានុកូលដ្ឋានមានការវិវត្តយ៉ាងដូចម្តេចខ្លះ ហើយរាជរដ្ឋាភិបាលបានព្យាយាមចេញនូវលិខិតបទដ្ឋានគតិយុត្តអ្វីខ្លះដើម្បីកែប្រែ និង កែសម្រួលការងារនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ?

២. តើប្រជាពលរដ្ឋត្រូវឆ្លងកាត់នីតិវិធី និង លក្ខខណ្ឌអ្វីខ្លះ ដើម្បីទទួលបានសេវាអត្រានុកូលដ្ឋាន?

៣.តើអត្រានុកូលដ្ឋានដើរតួនាទីសំខាន់យ៉ាងដូចម្តេចខ្លះក្នុងការរួមចំណែកដល់ការរីកចម្រើនរបស់ប្រទេស? ហើយប្រជាពលរដ្ឋនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីការចុះបញ្ជីនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដូចខាងក្រោម៖

- ដើម្បីទទួលបាននូវបទពិសោធន៍ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើង នូវការកត់ត្រាអត្រានុកូលដ្ឋានសម្រាប់ផ្តល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធិភាព និងអាចឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋានតាមរយៈការចេញនូវលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់។
- ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលមន្ត្រីអត្រានុកូលដ្ឋានបានជួបប្រទះសម្រាប់ឱ្យការដំណើរការការងារអត្រានុកូលដ្ឋាននេះអាចសម្រេចបាននូវគោលបំណងនៃគោលនយោបាយវិមជ្ឈការ។
- សាធារណៈជនយល់ដឹងពីសារៈសំខាន់នៃអត្រានុកូលដ្ឋានរបស់ខ្លួនឯង និងនីតិវិធីដែលងាយស្រួល និងសាមញ្ញដែលពួកគេនឹងទទួលសេវាអត្រានុកូលដ្ឋាននេះបាន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និងដែនកំណត់នៃប្រធានបទនេះ ក្រុមយើងខ្ញុំបានសិក្សាពីអ្នកទទួលសេវា និងការផ្តល់សេវាអត្រានុកូលដ្ឋាននៅទូទាំងប្រទេស រំលេចឡើងនូវការផ្តល់សេវាអត្រានុកូលដ្ឋានតាំងពីពេលបុព្វកាលរហូតមកដល់បច្ចុប្បន្ន តែពុំផ្តោតសំខាន់ទៅលើការងារនិងបែបបទនៃការងាររបស់ក្រុមប្រតិបត្តិករនោះទេ។ ក្រៅពីនេះយើងក៏បានពឹងផ្អែកលើឯកសារថ្មីៗ ដែលទទួលបានពីនាយកដ្ឋានអត្រានុកូលដ្ឋានបន្ថែម ដូចជាអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ និងរបាយការណ៍ផ្សេងៗ។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

ចំពោះក្រុមយើងខ្ញុំផ្ទាល់ កិច្ចការមួយនេះបានពង្រឹង និងពង្រីកចំណេះដឹង និងស្រង់បទពិសោធន៍តាមរយៈការប្រមូលផ្តុំឯកសារតាមរូបភាពជាច្រើនដូចជា ការចុះដល់មូលដ្ឋានផ្ទាល់ក្នុងការសុំកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីសិក្សា ក្នុងគោលបំណងទទួលបានព័ត៌មានច្បាស់លាស់ ជាក់ស្តែង និងជាច់ដោយឡែក។ ជាមួយគ្នាផងដែរ ការស្រាវជ្រាវមួយនេះបានផ្តល់នូវពុទ្ធិតាមរយៈភាពឆ្លាតវៃក្នុងការស្វះស្វែងទាញយកប្រភពព័ត៌មាន និងដកស្រង់នូវខ្លឹមសារសំខាន់ៗ ដែលទាក់ទងទៅកិច្ចការងារអត្រានុកូលដ្ឋាន ពីប្រភពលិខិតបទដ្ឋានដ្ឋានគតិយុត្តនានា។ ជារួមសារៈសំខាន់ស្នូលនៃកិច្ចការស្រាវជ្រាវមួយនេះគឺ បង្កើនសមត្ថភាពនិស្សិតក្នុងកិច្ចការស្រាវជ្រាវទៅនិងប្រធានបទ ស្តីពី **ការផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋនៅកម្ពុជា**។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវលើប្រធានបទនេះ មានលក្ខណៈវិទ្យាសាស្ត្រ និងមានកម្រិតនៃការជឿជាក់ខ្ពស់ ដោយផ្អែកលើទិន្នន័យ និងការវិភាគទិន្នន័យ។

ការកំណត់អថេរ ដើម្បីកំណត់ទិសដៅស្វែងរកទិន្នន័យយើងបានកំណត់អថេរជាមុន ដែលមានទាំងអថេរឯករាជ្យ និងអថេរមិនឯងរាជ្យ។

❖ **អថេរឯករាជ្យ** សម្តៅលើច្បាប់បទដ្ឋានគតិយុត្ត ពាក់ព័ន្ធនានាដូចជា៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលត្រូវបានប្រកាសឱ្យប្រើតាមក្រឹត្យលេខ៥៦ ក្រ. ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩
- អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០
- សេចក្តីណែនាំស្តីពី ការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការ ចុះសៀវភៅអត្រានុកូលដ្ឋានចល័ត លេខ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧
- សេចក្តីណែនាំអន្តរក្រសួងស្តីពី ការកែតម្រូវ និង បំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ លេខ០១០ សណន មផក កយ/០៧ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧
- សេចក្តីណែនាំស្តីពី ការចេញលិខិតរដ្ឋបាល និង លិខិតអត្រានុកូលដ្ឋានឱ្យសហព័ទ្ធជាខ្មែរ កូន និង ជនបរទេសអន្តោប្រវេសន៍ លេខ០១៥ សណន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៩
- សេចក្តីណែនាំស្តីពី វិធានការពង្រឹងការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន លេខ០២៩ សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០
- សេចក្តីណែនាំស្តីពី ការកែតម្រូវ និង ការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន លេខ០៣៥ សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧
- កម្រងឯកសារស្តីពី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន (ខែតុលា ២០១៥) ជាដើម។

❖ **អថេរមិនឯករាជ្យ** សម្តៅលើយន្តការ និងដំណើរការនៃការអនុវត្ត ការងារអត្រានុកូលដ្ឋាន របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មផ្ទាល់ ។

**ការប្រមូលទិន្នន័យ**

កិច្ចការស្រាវជ្រាវមួយនេះ ត្រូវបានរៀបចំចងក្រងឡើងឆ្លងកាត់នូវដំណាក់កាលចំនួន**ពីរ**គឺ

- ដំណាក់កាលទី១ ៖ ស្វែងរកអត្ថបទច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលមានស្រាប់
- ដំណាក់កាលទី២ ៖ ចុះប្រមូលទិន្នន័យតាមបែបគុណវិស័យដោយជួបសំណេះសំណាលផ្ទាល់ ជាមួយមន្ត្រីអនុវត្តការងារ អត្រានុកូលដ្ឋាន ដើម្បី ទទួលបានបទពិសោធន៍ស៊ីជម្រៅ និង ពង្រីកពុទ្ធិយល់ដឹងទាក់ទងនឹងវិស័យការងារអត្រានុកូលដ្ឋាន បន្ថែមឱ្យបានទូលំទូលាយ។

**ការវិភាគទិន្នន័យ**

ទិន្នន័យដែលប្រមូលបានមក បានវិភាគតាមបែបពិពណ៌នា និងប្រៀបធៀបកាអនុវត្តជាក់ស្តែងជាមួយនឹងការកំណត់របស់ច្បាប់ថាមានលក្ខណៈបែបណា ដើម្បីស្វែងរកនូវគុណសម្បត្តិ គុណវិបត្តិ បញ្ហាដែលមន្ត្រីអត្រានុកូលដ្ឋាន និង មន្ត្រីការិយាល័យ នៃនាយកដ្ឋានអត្រានុកូលដ្ឋានកំពុងជួបប្រទះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយពីបានពិភាក្សាជាមួយដៃគូររួមក្រុម និងការស្វែងរកនូវប្រភពឯកសារពាក់ព័ន្ធនានារួចមក ក្រុមរបស់យើងខ្ញុំបានសម្រេចបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវជា១កថាខណ្ឌ និង ៤ជំពូកដូចខាងក្រោម៖

**កថាខណ្ឌ១** សេចក្តីផ្តើម ដែលនឹងបរិយាយអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១** សាវតានៃអត្រានុកូលដ្ឋាន

**ជំពូកទី២** នីតិវិធី នៃការស្នើសុំលិខិតអត្រានុកូលដ្ឋាន

**ជំពូកទី៣** សារៈសំខាន់ បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី១ ៖

# សាវតានៃអគ្រានុក្កូលដ្ឋាន

# ជំពូកទី១ : សាវតានៃអត្រានុកូលដ្ឋាន

## ១.១.ទិដ្ឋភាពសង្គម

### ១.១.១. មុនឆសវត្សឆ្នាំ ១៩៧០

ការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានមានសារៈសំខាន់ណាស់សម្រាប់សាធារណៈជនទូទៅ ក៏ដូចជារាជរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេចចិត្តរៀបចំផែនការសង្គម សេដ្ឋកិច្ច វិស័យសុខាភិបាល អប់រំ ការងារ និងអចលនទ្រព្យផងដែរក្នុងការរៀបចំផែនការអភិវឌ្ឍ និងការប្រើប្រាស់ធនធានដែលមានកម្រិតរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាលក៏ដូចជាថ្នាក់ដឹកនាំតាមសម័យកាលនីមួយៗខិតខំពង្រឹងនិងកែលំអប្រព័ន្ធនេះឱ្យកាន់តែមានភាពងាយស្រួល និងប្រសើរជាងមុនពីមួយកម្រិតទៅមួយកម្រិត។

ដោយយោងទៅលើក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ជាភស្តុតាង កម្ពុជាធ្លាប់មានមូលដ្ឋានច្បាប់ និងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវមួយសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋរបស់ខ្លួន តាំងពីមុនពេលមានសង្គ្រាមស៊ីវិលមកម្ល៉េះ។ ក្រមរដ្ឋប្បវេណីនេះបានអនុញ្ញាតឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ដាក់ចេញនូវសេចក្តីណែនាំមួយសម្រាប់ទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។ តាមរយៈនេះដែរ គេក៏បានដាក់ចេញនូវរបៀបកាន់កាប់បញ្ជីអត្រានុកូលដ្ឋាននៃជនបរទេសថែមទៀតផង។[1] អត្ថន័យនៃពាក្យថា អត្រានុកូលដ្ឋាន (ភាពស៊ីវិល) របស់បុគ្គលម្នាក់ក្នុងកំឡុងពេលនោះគឺជាឋានៈដែលបុគ្គលនោះកាន់កាប់ក្នុងគ្រួសារខ្លួនក្តី ក្នុងសង្គមជាតិក្តី និងជាឋានៈដែលជាទីកើតនូវសិទ្ធិ និងករណីយកិច្ចទាំងឡាយរបស់បុគ្គលនោះដែលត្រូវបានបញ្ជាក់ដោយអត្រានុកូលដ្ឋានសញ្ញាបត្រដែលបច្ចុប្បន្នយើងហៅថា សំបុត្រអត្រានុកូលដ្ឋាន។[2] នៅក្នុងពេលនោះ ឃុំនីមួយៗមានបញ្ជីសម្រាប់កត់កំណើត កត់សេចក្តីប្រកាសអាពាហ៍ពិពាហ៍ កត់អាពាហ៍ពិពាហ៍ និងកត់មរណភាពពួកគាត់ជាមន្ត្រីអត្រានុកូលដ្ឋានដូចទៅនឹងពេលបច្ចុប្បន្នដែរ។[3] ចំណែកឯក្រុងភ្នំពេញត្រូវកាន់កាប់ដោយចៅសង្កាត់ក្នុងក្រុង ហើយបញ្ជីអត្រានុកូលដ្ឋានដែលមេឃុំ និងចៅសង្កាត់កាន់ត្រូវបានចុះហត្ថលេខាសង្ខេប និង ចុះលេខនៅគ្រប់ទំព័រដោយចាងហ្វាងសាលាដំបូងមុនប្រគល់ជូនទៅឃុំ សង្កាត់នីមួយៗ។ ក្នុងពេលនោះដែររយៈពេលសម្រាប់ការចុះអត្រានុកូលដ្ឋានសញ្ញាបត្ររបស់ពួកគេមានរយៈពេលខ្លីណាស់ បើធៀបទៅនឹងពេលបច្ចុប្បន្ននេះ។ ចំពោះសំបុត្រកំណើត ឬសញ្ញាបត្រកំណើតអ្នកកាតព្វកិច្ចត្រូវប្ដឹងអាចប្តឹងបានក្នុងកំណត់១៥ថ្ងៃប៉ុណ្ណោះ។[4] ចំណែកមរណភាព សញ្ញាបត្រគេត្រូវប្តឹងយ៉ាងយឺតណាស់ ៣ថ្ងៃដល់មន្ត្រីអត្រានុកូលដ្ឋាន។[5]

[1] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១, មាត្រា៣៧

[2] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១, មាត្រា២៨

[3] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១, មាត្រា៣៦

[4] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១, មាត្រា៤៩

[5] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១, មាត្រា៥៥

ចំពោះអាពាហ៍ពិពាហ៍វិញក៏មានលក្ខណៈស្រដៀងនឹងបច្ចុប្បន្នដែរ គឺសាមីជន ឬឪពុកម្តាយទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋាននៅឃុំខាងស្រី ដើម្បីធ្វើប្រកាសបិទនៅទ្វាសាលាឃុំ។[6]

ដោយផ្អែកទៅលើច្បាប់ និងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅពេលនោះកិច្ចការអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជាទី១ ប្រព្រឹត្តទៅបានល្អ ប៉ុន្តែទោះបីជាដំណើរការយ៉ាងនេះក្តី ក៏ការងារអត្រានុកូលដ្ឋាននៅពេលនោះ ធ្វើមិនទាន់បានទូលំទូលាយទូទាំងប្រទេសនៅឡើយទេ ព្រោះប្រជាពលរដ្ឋខ្មែរមួយចំនួន នៅតែគ្មានលិខិតស្នាមអត្រានុកូលដ្ឋាន ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ខ្ពង់រាប និងតំបន់ជនបទដាច់ស្រយាល។

គួរបញ្ជាក់ផងដែរថានៅមុនពេលមានក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ មានក្រមរដ្ឋប្បវេណីមួយទៀតដែលមានឈ្មោះថា ក្រមមរតក(ឆ្នាំ១៨៩១) ប៉ុន្តែដោយក្រមនេះមានភាពលំបាកនៅក្នុងការអាននិងបកប្រែអត្ថន័យ ជាហេតុធ្វើឱ្យសាវតានៃការងារអត្រានុកូលដ្ឋានមិនអាចនឹងច្បាស់លាស់ពីប្រព័ន្ធ និងបែបបទនៃការចុះបញ្ជីអត្រានុកូលដ្ឋានបែបណានោះទេ។ តាមរយៈការសិក្សាស្រាវជ្រាវពីនាយកដ្ឋានអត្រានុកូលដ្ឋានបានបង្ហើបឱ្យដឹងថានាយកដ្ឋានក៏កំពុងសិក្សាស្រាវជ្រាវ និងបកប្រែពីដើមកំណើតពិតប្រាកដស្តីពីការងារអត្រានុកូលដ្ឋាននេះផងដែរ។

### ១.១.២. កំឡុងទសវត្សឆ្នាំ ១៩៧០ - ១៩៧៩

ក្នុងកំឡុងទសវត្សឆ្នាំ ១៩៧០ - ១៩៧៥ ប្រទេសកម្ពុជាស្ថិតក្នុងវិបត្តិសង្គ្រាមស៊ីវិល និងអស្ថេរភាពនយោបាយ។ ក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ លន់ នល់ ប្រទេសមានភាពវឹកវរ និងវិបត្តិផ្ទៃក្នុង ជាហេតុធ្វើឱ្យការអនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅមានកម្រិត និងមានបញ្ហាប្រឈមជាច្រើនជាពិសេសតំបន់ដាច់ស្រយាល និងទីជនបទ ពិសេសតំបន់ព្រៃភ្នំ ព្រោះជាតំបន់ដែលធ្លាប់មានសង្គ្រាមរវាងកងទ័ព លន់ នល់ និងខ្មែរក្រហម ហេតុដូចនេះការអនុវត្តការចុះបញ្ជីឬការសុំកែទិន្នន័យត្រូវធ្វើឡើងតែក្នុងតំបន់ទីក្រុង និងទីប្រជុំជនតែប៉ុណ្ណោះពិសេសក្រុងភ្នំពេញ។ ក្នុងកំឡុងទសវត្ស ៧០-៧៥ ដោយបញ្ហាសង្គ្រាមនេះគេបានចាប់ផ្តើមប្រមូលសៀវភៅអត្រានុកូលដ្ឋាន(សៀវភៅភ្លោះ)ដាក់រក្សាទុកនៅក្រសួងយុត្តិធម៌។

បន្ទាប់មកក្នុងកំឡុងឆ្នាំ ១៩៧៥ - ១៩៧៩ ស្ថិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបប៉ុលពតដែលជារបបដ៏ព្រៃផ្សៃ និងឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក៏ជាកំឡុងឆ្នាំដែលកម្ពុជាធ្លាក់ដល់ចំណុចសូន្យ ហើយការងារអត្រានុកូលដ្ឋានបានលុបចោលទាំងស្រុង ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ឬសូម្បីទិន្នន័យស្ថិតិប្រជាជន ប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីរបស់ប្រជាជនក៏ត្រូវបានបំផ្លាញចោលទាំងស្រុងផងដែរ។

[6] ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១, មាត្រា៦០

### ១.១.៣. ចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់មានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

មុនខែសីហា ឆ្នាំ២០០២ (មុនមានអនុក្រឹត្យលេខ១០៣) ការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា មិនទាន់មានមូលដ្ឋានច្បាស់លាស់ខាងផ្លូវច្បាប់ និងប្រព័ន្ធចុះបញ្ជីនៅឡើយទេ។ យើងឃើញថាបន្ទាប់ពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ កិច្ចការអត្រានុកូលដ្ឋានត្រូវបានចាប់ដំណើរការឡើងវិញតែនៅក្នុងរាជធានីភ្នំពេញ និងទីប្រជុំជនតែប៉ុណ្ណោះភាគច្រើនការចុះបញ្ជីមានតែសម្រាប់ពួកមន្ត្រីរាជការ និងនិស្សិតដើម្បីប្រើប្រាស់ក្នុងតម្រូវការដូចជាការបើកប្រាក់បៀវត្សរ៍ជាដើម។ ក្នុងពេលនោះគេក៏ឃើញមានលិខិតណែនាំរបស់សាលាក្រុងភ្នំពេញ ឆ្នាំ១៩៨០ ដែរ តែលិខិតនោះគ្មានលក្ខណៈរួម និងគ្មានមូលដ្ឋានគតិយុត្តឡើយ។ រហូតមកដល់ឆ្នាំ ១៩៩០ ប្រទេសជាតិហាក់មានការអភិវឌ្ឍខ្លាំងខាងសង្គម និងសេដ្ឋកិច្ចតែក្របខណ្ឌគតិយុត្តក្នុងការគ្រប់គ្រងការងារនេះនៅមានភាពទន់ខ្សោយនៅឡើយ ជាហេតុធ្វើឱ្យការចុះបញ្ជី និងទម្រង់បែបបទនៃការអនុវត្តមិនមានការឯកភាពគ្នាទូទាំងប្រទេស។ ពួកគេធ្វើតាមការចេះដឹង និងចងចាំតាមតំបន់ ឬខេត្តរបស់ពួកគេរៀងៗខ្លួន។

ម៉្យាងវិញទៀតប្រជាជនមួយចំនួនធំហាក់ពុំអើពើ និងយល់ដឹងពីសារៈសំខាន់នៃលិខិតទាំងនេះនៅឡើយ ជាហេតុធ្វើឱ្យប្រជាជនភាគច្រើននៅតែមិនបានចុះបញ្ជី។ ករណីខាងលើនេះបានបង្កឱ្យមានភាពអសកម្ម និងបញ្ហាស្មុគស្មាញជាច្រើនជាពិសេសការឆ្លៀតឱកាសពីជនខិលខូច។ នៅក្នុងឆ្នាំ១៩៩៣ មានការបោះឆ្នោតជាសកលដើម្បីជ្រើសរើសតំណាងរាស្ត្រដែលរៀបចំឡើងដោយ អ៊ុន តាក់ ជាលទ្ធផលរាជរដ្ឋាភិបាលកម្ពុជាទី២ ត្រូវបានបង្កើតឡើង។ ក្នុងឆ្នាំ១៩៩៨ ដោយមើលឃើញពីភាពអសកម្មទាំងឡាយដែលកើតពីបញ្ហាគ្មានភាពច្បាស់លាស់នៃក្របខណ្ឌគតិយុត្តក្នុងការគ្រប់គ្រងការងារអត្រានុកូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយអនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល បានចាប់ផ្តើមចាត់ចែងឱ្យមានការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតនូវក្របខណ្ឌគតិយុត្តក្នុងការគ្រប់គ្រងការងារអត្រានុកូលដ្ឋានឱ្យមានការឯកភាពទូទាំងប្រទេស និងប្រកបដោយប្រសិទ្ធិភាព។

### ១.១.៤. ក្រោយមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

ជាលទ្ធផលក្រសួងមហាផ្ទៃ សហការជាមួយក្រសួងយុត្តិធម៌ បានដាក់ជូនគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ និងអនុម័តនូវអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ មានអានុភាពក្នុងអនុវត្តទូទាំងប្រទេស។ ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យឯកភាពគ្នាទូទាំងប្រទេស។[7] គំរូសំបុត្រអត្រានុកូលដ្ឋានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ ការចុះបញ្ជីអត្រានុកូលដ្ឋានតាមគំរូថ្មី និងឯកភាពទូទាំងប្រទេសនេះមានគោលដៅចម្បង គឺលើកកម្ពស់ឯកភាពជាតិ កិត្តិយស សេចក្តីថ្លៃថ្នូររបស់ជាតិ ការការពារសិទ្ធិមនុស្ស ការការពារសិទ្ធិបុគ្គល ការលើកស្ទួយករណីយកិច្ចរបស់

[7] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៥

ប្រជាពលរដ្ឋនៅក្នុងសង្គម និងការរក្សាការពារប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រៅប្រទេស និងជនទាំងឡាយដែលរស់នៅស្របច្បាប់នៅកម្ពុជាដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ សាសនា ឬនិន្នាការនយោបាយឡើយ។

បើទោះបីជាអនុក្រឹត្យលេខ១០៣ នេះត្រូវបានអនុម័តតាំងពីឆ្នាំ២០០០ក្តី ក៏អនុក្រឹត្យនេះត្រូវបានដាក់ឱ្យអនុវត្តន៍នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតមកដល់បច្ចុប្បន្ន។ ការអនុវត្តមានភាពចម្រូងចម្រាស និងមានបញ្ហាប្រឈមជាច្រើនដែលតម្រូវឱ្យក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធចេញប្រកាស និងសេចក្តីណែនាំជាច្រើនលើកច្រើនសារ។ ការអនុវត្តកាងារអត្រានុកូលដ្ឋាននេះត្រូវបានបែងចែកចេញជាដំណាក់កាលដូចជាៈ

**ក. ស្ថានភាពមុនមានយុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត**

ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៤។ ក្នុងដំណាក់កាលនេះត្រូវបានធ្វើឡើងក្រោមលិខិតនានានៃអនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់ ទូទាំងប្រទេស។ ប្រជាពលរដ្ឋគ្រប់រូបអាចទៅចុះបញ្ជីអត្រានុកូលដ្ឋានតាមសាលាឃុំ សង្កាត់ដែលខ្លួនរស់នៅអចិន្ត្រៃយ៍។ ក្នុងដំណាក់កាលនេះ ចំនួនប្រជាពលរដ្ឋដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋាន តាមឃុំ សង្កាត់នីមួយៗមានចំនួនតិចតួចស្តួចស្តើងនៅឡើយ។

ចាប់តាំងពីផ្តើមអនុវត្តការងារអត្រានុកូលដ្ឋានពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតមកដល់ ខែមីនា ឆ្នាំ២០០៤ មានរយៈពេលជិត ០២ឆ្នាំ សម្រេចចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋគ្រប់ប្រភេទសរុបទូទាំងប្រទេស បានចំនួន ៤៥៨.៧៧៩នាក់ (ស្រីចំនួន ១៩៥.៥៦៩នាក់)។ បើប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋសរុប ១២.២៥១.០៩៨នាក់ (ស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០០៣) គឺបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ បានតែ ៣,៧៤% ប៉ុណ្ណោះ។ ក្នុងនោះ កំណើត និង បញ្ជាក់កំណើតមានចំនួន ៣៤១.៥០៨នាក់ ស្មើ ២,៧៩% នៃប្រជាពលរដ្ឋសរុប។

កត្តាដែលនាំឱ្យការចុះបញ្ជីអត្រានុកូលដ្ឋានបានតិចតួចអាស្រ័យដោយ ៖

- ប្រជាពលរដ្ឋពុំទាន់យល់ដឹងច្បាស់លាស់អំពីសារៈប្រយោជន៍ការងារអត្រានុកូលដ្ឋាន ហើយពុំបានចូលរួម
- សមត្ថភាពរបស់មន្ត្រីអត្រានុកូលដ្ឋានដែលអនុវត្តផ្ទាល់នៅមានកម្រិត ដោយសារការងារនេះថ្មីថ្មោង និងពុំទាន់មានបទពិសោធន៍គ្រប់គ្រាន់។

អាស្រ័យដោយលទ្ធផលនៃការចុះសៀវភៅអត្រានុកូលដ្ឋាន ក្នុងរយៈពេល ១៧ខែ ដំបូងមានកម្រិតទាប និងយឺតយ៉ាវមិនទាន់ឆ្លើយតបទៅនឹងសំណូមពរ ដែលរាជរដ្ឋាភិបាលចង់បានក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សា ឃុំ សង្កាត់ ក្រោមជំនួយឥតសំណងនៃប្រទេសហូឡង់ អង្គការ UNICEF និង អង្គការ PLAN អន្តរជាតិកម្ពុជា បានឯកភាពរៀបចំចាត់ចែងឱ្យមានការចុះសៀវភៅអត្រានុកូលដ្ឋានចល័តសាកល្បងចំនួនបីខេត្តចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៤ ក្នុងនោះ

មានខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង និង ខេត្តរតនៈគិរី ដោយខេត្តនីមួយៗជ្រើសយកស្រុកពីរ និង ស្រុកនីមួយៗជ្រើសរើសយកឃុំតែមួយ ដើម្បីអនុវត្តសាកល្បង។

ការអនុវត្តសាកល្បងនេះ ក្នុងរយៈពេល ៣ខែ សម្រេចបានលទ្ធផលគួរជាទីពេញចិត្ត ជាក់ស្តែងចំនួនស្ថិតិប្រជាពលរដ្ឋដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានចល័តទាំង៦ឃុំ សរុបមាន ១៧.៧៤៥នាក់ (ស្រី ៩.៣៤៦នាក់) ស្មើ ៣៣,៨៣% ប្រៀបធៀបចំនួនប្រជាពលរដ្ឋសរុបក្នុងឃុំទាំង ៦ មាន ៥២.៤៤៥នាក់។

**ខ. យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត**

ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ដែលជារយៈពេលចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅទូទាំងប្រទេស។ ក្នុងដំណាក់កាលនេះ ដើម្បីសំរួលដល់ការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រសួងមហាផ្ទៃ រៀបចំការងារសំខាន់ៗមួយចំនួនជាអាទិ៍៖

- ធ្វើការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ដើម្បីកែលំអគោលនយោបាយ និងនិតិវិធីមួយចំនួនដែលបានជួបប្រទះ ក្នុងរយៈពេលកន្លងមក ដូចជាការលើកលែងមិនយកកំរៃ ចំពោះការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត មរណភាព និងបញ្ជាក់កំណើត បញ្ជាក់មរណភាព ការកែសំរួលនីតិវិធីមួយចំនួននៃការចុះបញ្ជីអត្រានុកូលដ្ឋាន ឱ្យមានភាពងាយស្រួល
- រៀបចំផែនការស្តីពីយុទ្ធនាការ ចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ដែលតាមរយៈផែនការនេះ បានតម្រូវឱ្យរៀបចំការងារមួយចំនួនដូចជា៖
    - ការរៀបចំផែនការជាក់ស្តែងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់។
    - ការរៀបចំក្រុមចល័តសម្រាប់ចុះតាមភូមិ និងតាមគ្រួសារប្រជាពលរដ្ឋ ដែលមានសមាជិកក្រុមចល័ត ប្រមាណជាង ១៣ ០០០នាក់
    - ការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមចល័ត និងមន្ត្រីពាក់ព័ន្ធ នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល។
- ដើម្បីបម្រើដល់យុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត រាជរដ្ឋាភិបាល បានធ្វើការគាំទ្រមធ្យោបាយចាំបាច់មួយចំនួនដូចជា ការបោះពុម្ពបញ្ជី សៀវភៅ ក្រដាសស្នាមអត្រានុកូលដ្ឋានគ្រប់ប្រភេទ ប្រដាប់និងទឹកសម្រាប់ផ្តិតមេដៃ
- ទន្ទឹមនឹងនេះ ក្នុងដំណើរការនេះ ដៃគូអ្នកផ្តល់ជំនួយនានា និងអង្គការជាតិ អង្គការអន្តរជាតិមួយចំនួនក៏បានចូលរួមឧបត្ថម្ភគាំទ្រខាងមធ្យោបាយ សម្ភារៈ ថវិកា និងបច្ចេកទេសមួយចំនួន ក្នុងនោះជាសំខាន់ គឺគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ (CCDP) នៃធនាគារអភិវឌ្ឍន៍អាស៊ី អង្គការផ្លែនអន្តរជាតិកម្ពុជា

(PLAN International Cambodia) អង្គការ UNICEF ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិនានា។

ចាប់តាំងពីផ្តើមអនុវត្តន៍យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័តទូទាំងព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ លទ្ធផលដែលទទួលបានដូចខាងក្រោម ៖

- កំណើតចំនួន ៣៣១.៥៧០នាក់ ស្រីចំនួន ១៦២.៣១៨នាក់
- បញ្ជាក់កំណើតចំនួន ៧.៣៨១.៩៦៤នាក់ ស្រីចំនួន ៣.៧៥៤.៩៤០នាក់
- អាពាពិពាហ៍ចំនួន ១៨.៣៤៩គូ ស្មើនឹងចំនួន ៣៦.៦៩៨នាក់
- បញ្ជាក់អាពាពិពាហ៍ចំនួន ៥៧.៦១៤គូ ស្មើនឹងចំនួន ១១៥.២២៨នាក់
- មរណភាពចំនួន ៥.៥៣៨នាក់ ស្រីចំនួន ១.៨៤៤នាក់
- បញ្ជាក់មរណភាពចំនួន ៣.៩០៦នាក់ ស្រីចំនួន ១.១៦៦នាក់
- សរុបចំនួនប្រជាពលរដ្ឋដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទមានចំនួន ៧.៨៨០.២៣៤នាក់ (ស្រីចំនួន ៣.៩៩៨.៨៣៦នាក់) ស្មើនឹង ៦២,១៣% ប្រៀបធៀបនឹងចំនួនប្រជាពលរដ្ឋទូទាំងប្រទេស ១២.៦៨៣.៦៤០នាក់ (ស្ថិតិឆ្នាំ ២០០៤)
- ដោយឡែកចំពោះលទ្ធផលដែលប្រជាពលរដ្ឋមកចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើតមានចំនួន ៧.៧១៨.៦៧៥នាក់ (ស្រីចំនួន ៣.៩១៩.៧៧០នាក់) ស្មើនឹង ៦០,៨៦% ប្រៀបធៀបនឹងចំនួនប្រជាពលរដ្ឋ ១២.៦៨៣.៦៤០នាក់ (ស្ថិតិឆ្នាំ ២០០៤)។

សរុបរួមចំនួនប្រជាជនដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចាប់តាំងពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ មានចំនួន ៨,៣៣៩,០១៣នាក់ (ស្រីចំនួន ៤,១៩៤,៤០៥ នាក់)ស្មើនឹង ៦៥.៧៤% ប្រៀបធៀបនឹងចំនួនប្រជាពលរដ្ឋទូទាំងប្រទេស១២,៦៨៣,៦៤០នាក់ (ស្ថិតិឆ្នាំ ២០០៤)។

ចំពោះលទ្ធផលសរុបចំនួនប្រជាពលរដ្ឋ ដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនិងបញ្ជាក់កំណើតចាប់តាំងពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ មានចំនួន ៨,០៦០,១៨៣នាក់ ស្មើនឹង ៦៣.៥៥%ប្រៀបធៀបនឹងចំនួនប្រជាពលរដ្ឋទូទាំងប្រទេស១២,៦៨៣,៦៤០នាក់ (ស្ថិតិឆ្នាំ២០០៤)។

យោងតាមតួលេខដែលជាលទ្ធផលសរុប ក្នុងការអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋានពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ប្រជាពលរដ្ឋដែលបានមកចុះបញ្ជីអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើតមានចំនួន៨,០៦០,១៨៣នាក់ ស្មើនឹង៦៣.៥៥% នៃចំនួនស្ថិតិប្រជាពលរដ្ឋទូទាំងប្រទេសក្នុង

ឆ្នាំ២០០៤ ដោយពុំទាន់បានគិតពីកំណើនថ្មី។ ដូច្នេះនៅសល់ប្រជាពលរដ្ឋប្រមាណជា ៣៦,៤៥% ដែលមិនទាន់បានចុះបញ្ជីអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើត។

ការចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅមានមួយដំណាក់កាលទៀត ដើម្បីធានាលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលនៅសេសសល់ទាំងនេះ ឱ្យមានចុះបញ្ជីអត្រានុកូលដ្ឋានកំណើតឱ្យបានគ្រប់ៗគ្នា រាជរដ្ឋាភិបាលកម្ពុជាតាមរយៈលិខិត ទីស្តីការគណៈរដ្ឋមន្ត្រី លេខ១៤៣៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៦។ ក្នុងដំណាក់កាលនេះក្រសួងមហាផ្ទៃបានលើកការងារជាអាទិភាពដល់មន្ត្រីគ្រប់ជាន់ថ្នាក់ ដូចជា ថ្នាក់ជាតិ ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ ថ្នាក់ឃុំ សង្កាត់ និងមានរហូតដល់ ថ្នាក់ភូមិថែមទៀត។ ក្រសួងបានកំណត់ពីមុខងារ សកម្មភាព និងការទទួលខុសត្រូវរបស់មន្ត្រីទាំងនោះ ជាពិសេសការគាំទ្រ និងការគ្រប់គ្រងមធ្យោបាយ សម្ភារៈ ថវិកាសម្រាប់យុទ្ធនាការអត្រានុកូលដ្ឋានចល័តនេះ។ ដោយយោងទៅតាមសៀវភៅ ការធ្វើឱ្យប្រសើរឡើងនូវការចុះបញ្ជីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថាអត្រានៃការចុះបញ្ជីកំណើតនៅទូទាំងប្រទេសមានចំនួនលើសពី ៩០% ដែលមានប្រជាពលរដ្ឋប្រមាណ ១១លាននាក់ មានសំបុត្រកំណើតក្នុងដំណាច់ចុងឆ្នាំ២០០៦(ចុងបញ្ចប់នៃយុទ្ធនាការ)។

**គ. ការចុះបញ្ជីអត្រានុកូលដ្ឋានក្រោយបញ្ចប់យុទ្ធនាការ**

ក្នុងឆ្នាំ២០០៧ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ០០៨ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋាននៅឱ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត ដោយថែងលំអិតពីតួនាទីនៃមន្ត្រីមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ពាក់ព័ន្ធនឹងការងារចុះបញ្ជីអត្រានុកូលដ្ឋាន។ សេចក្តីណែនាំលេខ០០៨ ណែនាំថា មេភូមិត្រូវដើរតួនាទីសំខាន់ក្នុងការជំរុញការងារអត្រានុកូលដ្ឋានដោយកត់ត្រាពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងភូមិ ហើយរាយការណ៍ទៅថ្នាក់ឃុំ ព្រមទាំងលើទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចុះបញ្ជីអត្រានុកូលដ្ឋាន។ សេចក្តីណែនាំនេះ ក៏បានសង្កត់ធ្ងន់បន្ថែមទៀតដល់ដំណើរការនៃការរបាយណ៍ពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់កណ្តាលដើម្បីតាមដានពីអត្រាចុះបញ្ជីអត្រានុកូលដ្ឋាន និងដំណើរការនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។

បន្ទាប់ពីសេចក្តីណែនាំលេខ០០៨ ក្រសួងមហាផ្ទៃសហការជាមួយស្ថាប័នពាក់ព័ន្ធនានាបានព្យាយាមចេញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀតសម្រាប់ធ្វើការកែលំអ កែតម្រូវ និងមោឃភាពទិន្នន័យ កែសម្រួលមាត្រានានានៃអនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋាន ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យប្រព័ន្ធ និងការងារអត្រានុកូលដ្ឋានកាន់តែមានភាពល្អប្រសើរឡើង ឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកើតមាន ជាពិសេសបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែងទោះទីប្រជុំជន ឬតំបន់ដាច់ស្រយាល។

គួរបញ្ជាក់ផងដែរថា ចាប់ពីឆ្នាំ២០០៧ មកក្រសួងមហាផ្ទៃបានផ្អាកការចេញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ និងលិខិតបញ្ជាក់មរណភាពដូចពេលមុនតទៅទៀតហើយ ក្នុងកំឡុងឆ្នាំនេះក្រសួងមហាផ្ទៃក៏បានចេញលិខិត

ស្នើសុំយកសៀវភៅអត្រានុកូលដ្ឋាន(សៀវភៅភ្លោះ)ពីតុលាការ មកទុកនៅការិយាល័យរដ្ឋបាលទូទៅក្នុងក្រសួងខ្លួនវិញរហូតដល់ឆ្នាំ២០១៧ ទើបមានអនុក្រឹត្យស្តីពីការផ្ទេរសៀវភៅនេះ។

## ១.២.ទិដ្ឋភាពច្បាប់

### ១.២.១. ការវិវត្តនៃលិខិតបទដ្ឋានគតិយុត្ត

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាពុំទាន់មានច្បាប់ស្តីពីអត្រានុកូលដ្ឋាននៅឡើយទេ ក៏ប៉ុន្តែក្រសួងមហាផ្ទៃក៏ដូចជា អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម (នាយកដ្ឋានអត្រានុកូលដ្ឋាន) បាននឹងកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតក្នុងកិច្ចប្រជុំពិភាក្សាសាមីក្រសួង។ បើទោះបីជាពុំមានទាន់មានច្បាប់ស្តីពីអត្រានុកូលដ្ឋានបែបនេះក្តី រាជរដ្ឋាភិបាលក៏ដូចជាក្រសួងមានសមត្ថកិច្ចខិតខំបន្តដាក់ចេញនូវច្បាប់ និងបទដ្ឋានគតិយុត្តនានាដើម្បីគ្រប់គ្រងការងារនេះ។ លិខិតបទដ្ឋានគតិយុត្តទាំងនេះមានដូចជា ៖

កម្រងច្បាប់ដែលពាក់ព័ន្ធ ៖

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)
- ច្បាប់ស្តីពីសញ្ជាតិ
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- ច្បាប់ស្តីពីអន្តោប្រវេសន្ត
- ច្បាប់ស្តីពីសុំកូនអន្តរជាតិ។

**ការវិវត្តនៃកម្រងបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រងការងារអត្រានុកូលដ្ឋាន**

- អនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការកែសំរួលមាត្រា៨ និង មាត្រា២៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ
- អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ស្ទួនថ្មីនៃ អនុក្រឹត្យលេខ១៧ អនក្រ.បក
- ប្រកាសលេខ១០៨៦ ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះការិយាល័យកិច្ចការទូទៅ ជាការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋានចំណុះ សាលាខេត្ត ក្រុង

- អនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ថ្មីស្ទួននៃ អនក្រ.បក លេខ១០៦
- សេចក្តីណែនាំលេខ០០៨ សណន ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបចំអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សេចក្តីណែនាំលេខ០០១ ចុះថ្ងៃទី១២ ខែមករា ឆ្ននាំ២០០៩ ស្តីពីការកំណត់អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពីពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- ប្រកាសអន្តរក្រសួងលេខ៣៨៥៦ ប្រ.ក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ៥៦៧១ ប្រ.ក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបញ្ចប់ការទទួលពាក្យស្នើសុំជាជនបរទេសអន្តោប្រវេសន៍ និង បំណ្ណស្នាក់នៅអចិន្រ្តៃយ៍
- សេចក្តីណែនាំលេខ០១៥ សណន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការចេញលិខិតរដ្ឋបាល និងលិខិតអត្រានុកូលដ្ឋានឱ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍
- សេចក្តីណែនាំលេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបន្តដំណើរការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន។

### ១.២.២. ការវិវត្តនៃការិយាល័យកំណត់អត្តសញ្ញាណប្រជាពលរដ្ឋ

សេវាសាធារណៈ គឺជាសមាសធាតុដ៏សំខាន់មួយក្នុងការចូលរួមចំណែកបង្កើតឡើងនូវវិបុលភាពជូនប្រជាពលរដ្ឋ។ ការពង្រឹងនិងការលើកកម្ពស់គុណភាព ប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធិក្នុងការផ្តល់សេវាសាធារណៈដែលកាន់តែកៀកជិត ឆាប់រហ័ស បំបាត់នូវការិយាធិបតេយ្យ និងមានភាពកាន់តែងាយស្រួល គឺបានកំណត់ឡើងយ៉ាងច្បាស់លាស់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងបុព្វហេតុធ្វើកំណែទម្រង់វិស័យសេវាសាធារណៈនេះ ក្រសួងមហាផ្ទៃដោយមានការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងសេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃដែលពីមុនមកបាននៅរាយប៉ាយ ឱ្យមកស្ថិតនៅក្រោមការគ្រប់គ្រងដោយស្ថាប័នមួយជាក់លាក់។ គោលបំណងជាយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃគឺការពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនអត្រាចុះបញ្ជីអត្រានុកូលដ្ឋាន និងលើកកម្ពស់ការងារអត្តសញ្ញាណកម្មថ្មីមួយទៀត ទាក់ទងនឹងការរៀបចំឡើងវិញនូវប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបុគ្គល តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឈានទៅបង្កើតលេខកូដសម្គាល់អត្តសញ្ញាណ

បុគ្គលរបស់មនុស្សគ្រប់រូប និងបង្កើតមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យអត្តសញ្ញាណកម្ម សម្រាប់ការភ្ជាប់ប្រព័ន្ធនេះជាមួយនឹងវិស័យពាក់ព័ន្ធទាំងអស់ដើម្បីជួយឱ្យរាជរដ្ឋាភិបាលងាយស្រួលក្នុងការពង្រឹងការអនុវត្តច្បាប់ សិទ្ធិ សេរីភាព លុបបំបាត់ចោលនូវរាល់ទម្រង់រើសអើងនានា លើកកម្ពស់ការផ្តល់សេវាសាធារណៈ ការគោរពសិទ្ធិមនុស្ស សិទ្ធិនយោបាយ ប្រយុទ្ធប្រឆាំងនូវរាល់ទម្រង់នៃការកេងប្រវ័ញ្ចពលកម្មកុមារ ធានាការទទួលបានសេវាមូលដ្ឋាននានា ដូចជា សេវាសុខាភិបាល អប់រំ ព្រមទាំងជួយសម្រួល និងគាំពារដល់វិស័យឯកជនឱ្យទទួលបានព័ត៌មានប្រកបដោយភាពជឿទុកចិត្តអំពីអត្តសញ្ញាណបុគ្គល។

### ១.២.៣. និយមន័យ (កំណើត, អាពាហ៍ពិពាហ៍, មរណភាព)

#### ក.កំណើត

កំណើតជាព្រឹត្តិការណ៍គតិយុត្តដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គល ពោលគឺជាការចាប់ផ្តើកកើតនូវសិទ្ធិ និង កាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។ ដើម្បីឱ្យបានក្លាយជារូបវន្តបុគ្គលត្រូវមានលក្ខខណ្ឌពីរយ៉ាងគឺ ៖

- កើតមកជាមនុស្ស
- កើតមករស់ ហើយអាចនឹងរស់បាន។

#### ខ.អាពាហ៍ពិពាហ៍

**អាពាហ៍ពិពាហ៍** អាចសរសេរម៉្យាងទៀតថា **អាវាហៈវិវាហៈ**

ដែល **អាវាហៈ** មានន័យថា ការនាំកូនស្រីមកខាងលំនៅកូនប្រុស

និង **វិវាហៈ** មានន័យថា ការនាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ

ដូច្នេះ **អាវាហៈវិវាហៈ** មានន័យថា មង្គលការគូរបុរសស្ត្រីបាននាំមកហើយនាំត្រឡប់ទៅវិញ។[8]

ចំណងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី មានន័យថា បុរស ឬស្ត្រី ដែលមានវ័យគ្រប់ការតាមច្បាប់កំណត់អាចជ្រើសរើសយកប្តី ឬប្រពន្ធ បានដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំពីអ្នកដទៃឡើយ គឺមានសេរីភាពគ្រប់គ្រានក្នុងការជ្រើសរើស។

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ។

#### គ. មរណភាព

មរណភាពរបស់បុគ្គលម្នាក់ជាព្រឹត្តិការណ៍គតិយុត្ត ដែលនាំឱ្យបុគ្គលិកលក្ខណៈគតិយុត្តរបស់រូបវន្តបុគ្គលនោះត្រូវបញ្ចប់។ ទោះជាបុគ្គលិកលក្ខណៈគតិយុត្ត ត្រូវបានបញ្ចប់នៅពេលមរណភាពក៏ដោយ ក៏ច្បាប់បានកំណត់ទទួលស្គាល់ និងបានផ្តល់នូវអានុភាពខាងផ្លូវច្បាប់ខ្លះ ដូចជាបណ្តាំសាសន៍ជាដើម។

[8] វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត, បោះពុម្ពលើកទី៥

### ១.២.៤. ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្ត

#### ១.២.៤.១. ស្ថាប័នមានសមត្ថកិច្ចក្នុងប្រទេស

ការសុំចុះអត្រានុកូលដ្ឋាន ក្នុងសៀវភៅអត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។ ដូច្នេះ រដ្ឋបានរៀបចំយន្តការដើម្បីធានានូវការបម្រើសេវានេះឱ្យមានប្រសិទ្ធិភាព ដោយបែងចែកសមត្ថកិច្ច និងការទទួលខុសត្រូវ ដើម្បីអនុវត្តការងារនេះ ដូចខាងក្រោមៈ

**ក. ថ្នាក់ក្រសួង**

នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួងលើការងារអត្រានុកូលដ្ឋាន ដោយសិក្សារៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ក្នុងការចុះបញ្ជី និងផ្តល់សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព និងមានភារកិច្ចដូចតទៅៈ

- ធ្វើការងារកសាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធ្វើជាមូលដ្ឋានឯកភាពដល់ឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតរបស់ប្រជាពលរដ្ឋ
- ធ្វើការដឹកនាំ ត្រួតពិនិត្យ លើកិច្ចដំណើរការការងារនៃមន្ត្រីអត្រានុកូលដ្ឋាន ព្រមទាំងលើកគម្រោងផែនការកម្មវិធីបណ្តុះបណ្តាលមន្ត្រីអត្រានុកូលដ្ឋាន
- ធ្វើការងារពិនិត្យនីត្យានុកូលភាពនៃឯកសារអត្រានុកូលដ្ឋាន និងចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ធ្វើការងារពិនិត្យ និងលើកយោបល់លើសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- ធ្វើការងារអប់រំ ផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋអំពីការងារអត្រានុកូលដ្ឋាន
- សហការកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យានិងការពារហានិភ័យផ្សេងៗទៀត ដើម្បីការពារសន្តិសុខ សុវត្ថិភាព និងទិន្នន័យនៃអត្រានុកូលដ្ឋាន
- គ្រប់គ្រងចំណូលពីការងារអត្រានុកូលដ្ឋានតាមច្បាប់ជាធរមាន
- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ការងារបណ្តុះបណ្តាល និងការងារភស្តុភារ គណនេយ្យ របស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់នាយកដ្ឋានអត្រានុកូលដ្ឋានតាមរបបកំណត់
- ធ្វើការងារប័ណ្ណសាររបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មប្រគល់ឱ្យ។

**ខ. ថ្នាក់រាជធានី ខេត្តៈ**

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការអនុវត្តការងារស្ថិត និងអត្រានុកូលដ្ឋាន នៅរាជធានី ខេត្ត របស់ខ្លួន ដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃទីចាត់ការរដ្ឋបាលសាលារាជធានីខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងរាជធានី ខេត្ត និងផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃតាមការកំណត់
- ត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែ និងផ្ញើរបាយការណ៍ទៅក្រសួងមហាផ្ទៃ (នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ) រៀងរាល់ថ្ងៃទី១៥ នៃខែបន្ទាប់នីមួយៗ
- លើកគម្រោងទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់ផ្តល់ឱ្យក្រុង ស្រុក ខណ្ឌ ធ្វើការបែងចែកដល់ឃុំ សង្កាត់ និងផ្ញើរបាយការណ៍បូកសរុបការប្រើប្រាស់សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានឱ្យទាន់ពេលកំណត់
- សហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន
- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីការងារអត្រានុកូលដ្ឋានដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ចំណុះ
- ធ្វើការវាយតម្លៃការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋានក្នុងរាជធានី ខេត្តរបស់ខ្លួន
- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋាន
- ជំរឿន និងការគ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋក្នុងរាជធានី ខេត្ត
- គាំទ្រ តាមដាន ត្រួតពិនិត្យ និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន
- ពិនិត្យ និងផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមនីតិវិធីកំណត់
- ស្រាវជ្រាវ វិភាគ និងវាយតម្លៃអំពីកំណើត អាពាហ៍ពិពាហ៍ និងមរណភាព សម្រាប់បម្រើឱ្យការងារអត្រានុកូលដ្ឋាន
- ពិនិត្យ តាមដាន និងវាយតម្លៃការចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សិក្សា និងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការខាងមធ្យោបាយ និងសម្ភារៈទាក់ទងនឹងការងារអត្រានុកូលដ្ឋាននៅក្នុងរាជធានី ខេត្ត

- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់គោលដៅតាមរយៈការពិនិត្យតាមដាននូវការចុះបញ្ជីអត្រានុកូលដ្ឋានជាប្រចាំ ជាពិសេស ពិនិត្យពីការបែងចែកសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទដល់ឃុំ សង្កាត់គោលដៅ និងការប្រើប្រាស់សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាពរបស់មេភូមិ។

**គ. ថ្នាក់ឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ ដែលខ្លួនគ្រប់គ្រង។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន។ មន្ត្រីអត្រានុកូលដ្ឋាន មានភារកិច្ចដូចខាងក្រោម ៖

- លើកគម្រោងស្នើសុំសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានមកសាលាក្រុង ស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ចលនាប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យមកចុះសៀវភៅអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា
- ទទួលពិនិត្យ និងកត់ត្រារឿងហេតុសំខាន់ៗទាក់ទងទៅនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាព នៃជនទាំងឡាយ ចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ទៅតាមការស្នើសុំរបស់ប្រជាពលរដ្ឋ នៅឆ្នាំដែលមិនទាន់ដាច់
- អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និងបោះត្រាលើបញ្ជី និងសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬបដិសេធសំបុត្រអត្រានុកូលដ្ឋានតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋានតាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង
- បិទសៀវភៅអត្រានុកូលដ្ឋាន នៅពេលប្រើប្រាស់អស់បញ្ជី និងនៅដំណាច់ឆ្នាំនីមួយៗ ក្រោយពីបានពិនិត្យត្រឹមត្រូវរួចរាល់អស់ហើយ
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានដែលបិទបញ្ជីរួចទៅសាលាក្រុង ស្រុក ខណ្ឌ នៅដើមខែមករានៃឆ្នាំបន្ទាប់ ដើម្បីយកទៅតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និងនៅសាលារាជធានី ខេត្តសាមីមួយច្បាប់

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំសង្កាត់ ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទំនាក់ទំនងពីការងារអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ជារៀងរាល់ខែនាថ្ងៃទី០៥ នៃខែបន្ទាប់ និងរាល់ដំណាច់ឆ្នាំនីមួយៗផ្ញើទៅសាលាក្រុង ស្រុក ខណ្ឌសាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋានអំពីការងារអត្រានុកូលដ្ឋាន ក្នុងករណីចាំបាច់។

**ឃ. ថ្នាក់មេភូមិ**

- មេភូមិត្រូវចលនាឱ្យប្រប្រជាពលរដ្ឋទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងមរណភាព ឱ្យបានទាន់ពេលវេលា និងចលនាអ្នកដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឱ្យស្របទៅតាមច្បាប់ ត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅសាលាឃុំ សង្កាត់ ខាងលំនៅឋាននារី ស្របតាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិមួយចំនួនដែលនៅជាធរមាននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- មេភូមិត្រូវចេញលិខិតបញ្ជាក់ទទួលស្គាល់កំណើតទារកឱ្យឪពុកម្តាយទារក បើទារកកើតនៅផ្ទះ ដើម្បីឱ្យឪពុកម្តាយទារកមានឯកសារភស្តុតាងសម្រាប់ទៅសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យកូន
- មេភូមិត្រូវកត់ត្រាប្រចាំនីមួយៗឱ្យបានច្បាស់លាស់នូវស្ថិតិ
  - ទារកដែលកើត
  - ទារកដែលទើបកើត ហើយស្លាប់
  - អ្នកដែលបានរៀបអាពាហ៍ពិពាហ៍ និងអ្នកដែលរួមរស់ជាមួយគ្នាក្នុងស្ថានភាពប្តី ប្រពន្ធ
  - អ្នកដែលទទួលមរណភាព។
- មេភូមិត្រូវស្រង់ស្ថិតិ និងផ្ញើស្ថិតិនេះទៅសាលាឃុំ សង្កាត់ នៅថ្ងៃទី០៣ នៃខែបន្ទាប់ ដើម្បីធ្វើការបូក សរុប
- ចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីសារប្រយោជន៍ នៃការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងភូមិរបស់ខ្លួន ណែនាំដល់ឪពុក ម្តាយរបស់ទារក សាច់ញាតិរបស់អ្នកស្លាប់ សាមីខ្លួនដែលបានរៀបអាពាហ៍ពិពាហ៍ ឬរួមរស់ជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ ឱ្យទៅចុះបញ្ជីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់
- បំពេញការងារចាំបាច់ផ្សេងៗ ដែលទាក់ទងនឹងដំណើរការនៃការអនុវត្តនេះ តាមការណែនាំពីក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីតម្លៃសេវារដ្ឋបាលនៃការងារអត្រានុកូលដ្ឋានដល់ប្រជាពលរដ្ឋក្នុងភូមិ
- បំពេញការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងដំណើរការអនុវត្តនេះ។

### ១.២.៤.២. ស្ថាប័នមានសមត្ថកិច្ចក្រៅប្រទេស

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាននៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន ដូចការងារអត្រានុកូលដ្ឋានដែលបានអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវធ្វើសេចក្តីណែនាំបន្ថែមដោយប្រកាសរួម។

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី០១រូបនៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឱ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

### ១.២.៥. ថ្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋាន

ថ្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋានត្រូវអនុវត្តទៅតាមប្រកាសអន្តរក្រសួង លេខ១៤៤១៤ ប្រកស្តីពី ការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។

សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ អ្នកសុំត្រូវបង់ថ្លៃសេវារដ្ឋបាលដូចការកំណត់ដែលមានក្នុងតារាងដែលគេបានបិទទុកស្រេចទៅតាមក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់នីមួយៗទូទាំងប្រទេស។ ថ្លៃសេវារដ្ឋបាលអត្រានុកូលដ្ឋាន ត្រូវបានបែងចែកចេញជា២ផ្នែក គឺរាល់សេចក្តីចម្លង សំបុត្រអត្រានុកូលដ្ឋាន ឬបញ្ជាក់អត្រានុកូលដ្ឋានឆ្លងឆ្នាំត្រូវធ្វើឡើងនៅក្រុង ស្រុក ក្នុងខេត្ត និងខណ្ឌក្នុងរាជធានី ទូទាំងប្រទេស។ រីឯការសុំចុះបញ្ជីអត្រានុកូលដ្ឋាន ឬបញ្ជាក់អត្រានុកូលដ្ឋាន ត្រូវធ្វើនៅឃុំ សង្កាត់ដែលពួកគេស្នាក់នៅ។ ដោយយោងតាមសេចក្តីណែនាំលេខ០០៨ សណន របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ បានផ្តល់អាទិភាពតម្លៃដល់ខេត្តចំនួន០៥រួមមានខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និង ខេត្តឧត្តរមានជ័យ។ ការសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ឬបញ្ជាក់អត្រានុកូលដ្ឋានទាំង៣ប្រភេទមានតម្លៃត្រឹមតែ ១០០០រៀលប៉ុណ្ណោះ បើធៀបនឹងថ្លៃសេវាក្នុងរាជធានី និងខេត្តក្រៅពីខេត្តទាំង៥នោះ គឺថ្លៃ ៣០០០រៀល។ ចំពោះការសុំចុះអត្រានុកូលដ្ឋានស្ថិតក្នុងពេលដែលអនុក្រឹត្យលេខ១០៣ បានកំណត់មានដូចជាសំបុត្រកំណើត សំបុត្រមរណភាព ក្នុងកំឡុងថ្ងៃកំណើត និងពាក្យសុំរៀបអាពាហ៍ពិពាហ៍ពុំត្រូវបានបង់កម្រៃសេវានៅទូទាំងឃុំ សង្កាត់ទាំងអស់របស់ប្រទេសកម្ពុជា។ ចំពោះឃុំ សង្កាត់ទាំងអស់នៃខេត្តដែលបានរៀបរាប់

ទាំង៥ខាងលើ ត្រូវបានអនុគ្រោះថ្លៃដូចជា សំបុត្របញ្ជាក់កំណើតថ្លៃ ៣០០០រៀល ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ២០០០រៀល សំបុត្រអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរថ្លៃ ៥០០០រៀល ឯជនបរទេស និងពលរដ្ឋខ្មែរថ្លៃ ១៥០០០រៀល និងសំបុត្រមរណភាពដែលហួសពេលកំណត់ ១៥ថ្ងៃ ត្រូវបង់ថ្លៃ ១០០០រៀល ដែរ។ សេចក្តីចម្លង ឬសំបុត្រកំណើត ឬបញ្ជាក់កំណើតថ្លៃ ១០០០រៀល និងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (មិនឆ្លងឆ្នាំ) ថ្លៃ ៣០០០រៀល និងសេចក្តីចម្លងសំបុត្រមរណភាព ១០០០រៀល។ ចំពោះឃុំ និងសង្កាត់ដែលមិនស្ថិតក្នុងខេត្តទាំង៥ខាងលើ រាល់សំបុត្របញ្ជាក់កំណើតត្រូវបង់ថ្លៃ ១០,០០០រៀល ប័ណ្ណប្រកាសអាពាហ៍ពីពាហ៍ ៣០០០ រៀល សំបុត្រអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរថ្លៃ ១៥,០០០រៀល ឯពលរដ្ឋខ្មែរ និងជនបរទេសថ្លៃ ៣០,០០០រៀល ចំណែកសំបុត្រមរណហួសរយៈពេលកំណត់១៥ថ្ងៃ ត្រូវបង់ថ្លៃ ៣០០០រៀល ហើយចំពោះសេចក្តីចម្លងសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត និង អាពាហ៍ពិពាហ៍ មិនឆ្លងឆ្នាំថ្លៃ ៣០០០រៀល ដូចគ្នាឯសេចក្តីចម្លងសំបុត្រមរណភាពថ្លៃ ២០០០រៀល។

ថវិកាដែលបានមកពីការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្នុងឃុំ សង្កាត់ ត្រូវបង់ចូលថវិកា ឃុំ សង្កាត់ ត្រូវបង់ចូលថវិកា ឃុំ សង្កាត់តាមការកំណត់។ ឯថវិកាបានមកពីការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅសាលាក្រុង ស្រុក ត្រូវបង់ចូលថវិកា ក្រុង ស្រុក តាមការកំណត់ដោយឡែកចំពោះសាលាខណ្ឌត្រូវបង់ចូលថវិកាបស់រាជធានីភ្នំពេញ។

### ១.២.៦. បម្រាម និងការទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីការងារអត្រានុកូលដ្ឋាន

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ។ មន្ត្រីអត្រានុកូលដ្ឋាន អាជ្ញាធរស្រុក ខណ្ឌ ខេត្ត ក្រុង មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងឡើយ។ ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួន របស់ជនណាម្នាក់ទៀត។ សំបុត្រអត្រានុកូលដ្ឋានរបស់ជនណាមួយ ជាកម្មសិទ្ធិសម្រាប់តែជននោះប៉ុណ្ណោះ មិនអនុញ្ញាតឱ្យជនដទៃយកទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនឡើយ។ ហាមចុះសៀវភៅអត្រានុកូលដ្ឋានប្រភេទនីមួយៗ លើសពីមួយដងសម្រាប់មនុស្សតែម្នាក់ នៅច្រើនកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។ សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ដែលមានកោស ឆូត លុប សរសេរ ជ្រៀតថែម មិនមានតម្លៃប្រើប្រាស់ជាផ្លូវការទេ។ ការចុះសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ សាមីខ្លួន អ្នករាយការណ៍ សាក្សីត្រូវសម្តែងនូវការស្មោះត្រង់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ចំពោះការបញ្ជាក់អះអាងរបស់ខ្លួន អំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់។ ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយកាណ៍សុំចុះអត្រានុកូលដ្ឋានលើសពីមួយដង នៅកន្លែងដដែល ឬ កន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់

អត្រានុកូលដ្ឋានក្លែងបន្លំ ត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ។ បើមន្ត្រីអត្រានុកូលដ្ឋានណាសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ឬបានទារប្រាក់លើសពីការកំណត់ពីប្រជាពលរដ្ឋ សម្រាប់ការងារអត្រានុកូលដ្ឋានត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

# ជំពូកទី ២ ៖

# នីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាត

# អគ្រានុកូលដ្ឋាន

# ជំពូកទី២ : នីតិវិធី នៃការស្នើសុំលិខិតអត្រានុកូលដ្ឋាន

កាលប្រវត្តិនៃរូបវ័ន្តបុគ្គលគ្រប់រូប គឺមានកាលចំនួនបីសំខាន់ៗក្នុងវដ្តជីវិតរបស់ខ្លួនជាប់ជានិច្ចនោះគឺ កំណើត អាពាហ៍ពិពាហ៍ និងមរណភាព។ កាលទាំងបីនេះហើយដែលបង្កើតឱ្យរូបវ័ន្តបុគ្គលរូបនោះ កកើតនូវសិទ្ធិ និងករណីយកិច្ចសំខាន់ផ្សេងៗគ្នា។ ដើម្បីទទួលបានការទទួលស្គាល់អំពីសិទ្ធិ និងករណីយកិច្ចទាំងនោះពេញលេញស្របតាមផ្លូវច្បាប់នោះ រាល់បុគ្គលគ្រប់រូបត្រូវចុះបញ្ជីអត្រានុកូលដ្ឋាន។

អត្រានុកូលដ្ឋាន គឺជាបណ្តុំនៃព្រឹត្តហេតុ និងកិច្ចទាំងឡាយដែលនាំមកនូវផលវិបាកតាមច្បាប់ទៅលើស្ថានភាពគ្រួសាររបស់បុគ្គលដែលចាំបាច់ត្រូវតែធ្វើការកត់ត្រាក្នុងបញ្ជីនៃកំណត់ហេតុឯកសារយថាហេតុ ហៅថា **លិខិតអត្រានុកូលដ្ឋាន**។ ជាទូទៅបញ្ជីអត្រានុកូលដ្ឋានកត់ត្រាទុកជាផ្លូវការណ៍អំពីកំណើត និងមរណភាពរបស់បុគ្គល តែទន្ទឹមនឹងនោះ វាក៏ពាក់ព័ន្ធផងដែរទៅនឹងព្រឹត្តការណ៍ដទៃផ្សេងទៀតដែលអាចកើតមាន ឬជួបប្រទះក្នុងអំឡុងពេលមានអត្ថិភាព ត្រូវការធ្វើការផ្លាស់ប្តូរ ឬក៏កែតម្រូវ ទៅលើលក្ខន្តិកៈគ្រួសារ ហើយវានឹងជះឥទ្ធិពលទៅលើរាល់បណ្តាសិទ្ធិនានារួមជាមួយនូវបណ្តាកាតព្វកិច្ចទាំងឡាយប្រៀបធៀបទៅនឹងបណ្តាសមាជិកដទៃទៀតនៃគ្រួសារ។ កំណត់ត្រាជាផ្លូវការនេះ ធ្វើឡើងតាមរយៈលិខិតអត្រានុកូលដ្ឋានដែលក្នុងនោះមានតួនាទីផ្តល់ជាលម្អិតច្បាស់លាស់ទៅលើសភាពប្បវេណី (ឬ ភាពស៊ីវិល) របស់បុគ្គលទាំងនោះ។ លិខិតអត្រានុកូលដ្ឋានទាំងអស់រៀបចំឡើងដោយមន្ត្រីអត្រានុកូលដ្ឋាន ពោលគឺមេឃុំ ចៅសង្កាត់ ដែលអាចធ្វើប្រតិភូកម្មនៃអំណាចរបស់ខ្លួនទៅឱ្យជំទប់ ឬចៅសង្កាត់រង និងទៅឱ្យមន្ត្រីឃុំសង្កាត់ដទៃទៀតបាន។ លិខិតនេះគឺជាលទ្ធផលបង្កើតឡើងបានដោយកិច្ចសហការរវាងអាជ្ញាធរសាធារណៈនិងបុគ្គលឯកជន។ អាជ្ញាធរសាធារណៈតំណាងឱ្យដោយមេឃុំ ចៅសង្កាត់ ដែលអាចធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនទៅឱ្យជំទប់ ឬ ចៅសង្កាត់រង។ អន្តរាគមន៍របស់វាមានភាពចាំបាច់ណាស់តែវាមានលក្ខណៈចម្បងដោយការទទួលយកសេចក្តីប្រកាសរៀបចំតាក់តែងតាមទម្រង់ច្បាប់ និងចុះហត្ថលេខា។ កិច្ចការទាំងអស់នេះក៏ទាមទារនូវតួនាទីយ៉ាងសកម្មពីបណ្តាបុគ្គលឯកជននៅក្នុងដំណើរការប្រព្រឹត្តទៅនៃនីតិវិធី ៖ ចំពោះបណ្តាលិខិតមួយចំនួន ភាគីពាក់ព័ន្ធតែប៉ុណ្ណោះ។ ជាក់ស្តែង សាមីនៃលិខិតដែលត្រូវទទួល ៖ គូអង្គសហព័ទ្ធតែប៉ុណ្ណោះដែលពាក់ព័ន្ធ សម្រាប់លិខិតអាពាហ៍ពិពាហ៍ ឪពុកឬម្តាយ ឬទាំងពីរ ចំពោះលិខិតទាក់ទងទៅនឹងការទទួលស្គាល់បុត្តភាពគ្មានខាន់ស្លា ចំពោះបណ្តាលិខិតពាក់ព័ន្ធទៅនឹងកំណើត ឬមរណភាព តតិយជន ឬជនតំណាងទាមទារលិខិត។

## ២.១. អត្រានុកូលដ្ឋានកំណើត

### ២.១.១. សញ្ញាណនៃអត្រានុកូលដ្ឋានកំណើត

កំណើតគឺជាលក្ខខណ្ឌបង្កើតឱ្យមានបុគ្គលភាព។ នៅពេលកើត គ្រប់ក្មេងទាំងអស់ជារូបវន្តបុគ្គល។ ឪពុក ឬម្តាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬម្តាយក្នុង

អំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលទារកនោះចាប់កំណើត។ ប្រសិនបើឪពុក ឬម្តាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូន ត្រូវសុំចុះកំណើតរបស់កូននោះឱ្យបានឆាប់រហ័ស។

### ២.១.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតរួមមាន :

- សំបុត្រកំណើត
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត
- សេចក្តីសម្លងសំបុត្របញ្ជាក់កំណើត។

### ២.១.៣. នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋាន

#### ក. ចំពោះកូនដែលឪពុកម្តាយជាពលរដ្ឋខ្មែរ

##### ក.១. កូនដែលកើតចេញពី ឪពុកម្តាយ មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់

បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុនមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស៣០ថ្ងៃ។ ករណីឪពុក ម្តាយមានធុរៈចាំបាច់ពុំអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតបាន អាចពឹងសាច់ញាតិ ជានីតិជនដែលរស់នៅជាមួយឪពុក ម្តាយ ឱ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត។ ការដាក់ឈ្មោះ គឺត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីឪពុកម្តាយទារកនោះ និងត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្តាយទារក ឬឯកសារភស្តុតាងផ្សេងៗដែលមានបញ្ជាក់ភាពជាប្តីប្រពន្ធទៅជាមួយផង (ប្រសិនបើមាន)។ ទារកដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតក្នុងរយៈពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋាននឹងផ្តល់នូវសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ដោយឥតគិតថ្លៃ។

ប្រជាពលរដ្ឋខ្មែរដែលបានកើតហើយទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត (ជាលាយលក្ខណ៍អក្សរ) នៅសាលា ឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន២រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ចំនួន ០១ច្បាប់ ត្រូវបង់ថ្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋាន ៣០០០ រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និងបង់ថ្លៃសេវារដ្ឋបាលលើការងារអត្រានុកូលដ្ឋាន ១០០០០ រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ។

**ក.២. កូនដែលកើតចេញពី ឪពុកម្ដាយ មិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់**

ទារកកើតពីឪពុក ម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតដែរ។ នៅពេលធ្វើសំបុត្រកំណើត ប្រសិនបើឪពុក និង ម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក និងម្ដាយនោះជាឪពុក ម្ដាយរបស់កូននោះ។

ក្នុងករណីមានតែឪពុក ឬមានតែម្ដាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ។ ក្រោយពេលឪពុក ឬម្ដាយបានប្ដឹងចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬម្ដាយណាដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬម្ដាយនោះអាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន។ ការទទួលស្គាល់កូនអាចធ្វើមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាល់គ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន។

**ក.៣. កូនដែលកើតចេញពី ឪពុកម្ដាយ ជាពិរុទ្ធជន**

ពេលមានពិរុទ្ធជន ឬទណ្ឌិតណាម្នាក់បានសម្រាលកូនក្នុងមណ្ឌលអប់រំកែប្រែ ពេលនោះអ្នកទទួលខុសត្រូវនៃមណ្ឌលអប់រំកែប្រែត្រូវធ្វើកំណត់ហេតុអំពីទារកកើតឱ្យបានត្រឹមត្រូវ។ ចំពោះទីកន្លែងកំណើតទារក ត្រូវសរសេរទីកន្លែងនៃលំនៅរបស់ឪពុក ឬរបស់ម្ដាយទារកមុនពេលក្លាយជាទណ្ឌិត។ បើទារកនោះមានឪពុកត្រឹមត្រូវនៅរស់ អ្នកទទួលខុសត្រូវនៃពន្ធនាគារត្រូវប្រគល់កំណត់ហេតុនោះឱ្យឪពុកទារកយកទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឃុំ ឬសង្កាត់ ដែលខ្លួនកំពុងរស់នៅជាប់លាប់ឱ្យទាន់ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីទារកនោះកើត។ ក្នុងករណីទារកពុំទាន់មានឪពុកច្បាស់លាស់ទេ អ្នកទទួលខុសត្រូវនៃពន្ធនាគារ ត្រូវបញ្ជូនកំណត់ហេតុទារកកើតទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដែលម្ដាយទារកនោះរស់នៅជាប់លាប់ មុនពេលក្លាយជាទណ្ឌិត ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឱ្យទាន់ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីទារកនោះកើត។

**ក.៤. កូនដែលមានអាណាព្យាបាលមិនច្បាស់លាស់**

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលរើសទារកនោះ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើកំណត់ហេតុ និងចុះសៀវភៅអត្រានុកូលដ្ឋានកំណើតដោយរកឈ្មោះដាក់ឱ្យទារកនោះ។ ក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំកំណើតទារកដែលរើសបាននោះដោយស្មាន និងឈ្មោះឪពុកម្ដាយដាក់ថាមិនស្គាល់។ រាល់ការសុំកូនយកទៅចិញ្ចឹម ទាំងការសុំកូនធម្មតា និងសុំកូនពេញលេញ ត្រូវមានការសម្រេចពីតុលាការ។ បើជនណាសុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ហើយត្រូវយក

អ្នកសុំនោះធ្វើជាឪពុកម្ដាយ ហើយមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត។ ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះទៅមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និងធ្វើកំណត់ហេតុស្ដីពីការប្រគល់ទារកជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា។ ចំពោះទារក ឬកុមារដែលកំពុងចិញ្ចឹមបីបាច់ថែរក្សានៅក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាហើយពុំទាន់មានសំបុត្រកំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះ ត្រូវធ្វើសេចក្ដីរាយការណ៍ និងនាំទារក ឬកុមារនោះទៅបង្ហាញផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីផ្ដល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឱ្យ។ ចំពោះការដាក់ឈ្មោះឱ្យទារក ឬកុមារកំព្រាទាំងនោះ អាស្រ័យទៅលើអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌល និងមន្ត្រីអត្រានុកូលដ្ឋានឯកភាពដាក់ឱ្យ។ ការសុំទារក ឬកុមារដែលកំពុងចិញ្ចឹមបីបាច់ថែរក្សាក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងសុំទារក ឬកូនដែលកំពុងចិញ្ចឹមដោយឪពុក ម្ដាយរបស់ខ្លួនធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តផ្អែកតាមក្រមរដ្ឋប្បវេណី និងឬច្បាប់ស្ដីពីស្មុំកូនអន្តរប្រទេស។

**ជំហានសំខាន់ៗ នៃការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត**

- ពិនិត្យឯកសារដែលអ្នកសុំចុះបញ្ជីនាំមកជាមួយ (សំបុត្រពេទ្យ លិខិតបញ្ជាក់ពីមេភូមិ...)
- សរសេរចូលក្នុងបញ្ជីភ្លោះនៃសៀវភៅអត្រានុកូលដ្ឋាន (ទាំងពីរក្បាល)
- ឱ្យអ្នកសុំចុះបញ្ជី (អ្នករាយការណ៍) ពិនិត្យមើលទិន្នន័យដែលបានសរសេរចូលឱ្យបានច្បាស់លាស់ បើសិនជាគាត់ចេះអក្សរ ឬអានឱ្យគាត់ស្ដាប់ បើសិនជាគាត់មិនចេះអក្សរ មុននឹងអនុញ្ញាតឱ្យអ្នកសុំចុះបញ្ជីកំណើតទារក ផ្ដិតស្នាមមេដៃនៅលើបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន
- អនុញ្ញាតឱ្យអ្នកសុំចុះបញ្ជីផ្ដិតមេដៃស្ដាំត្រង់ពាក្យអ្នករាយការណ៍ (ផ្ដិតសើៗមិនឱ្យឈ្លីទេ)
- ស្រង់ទិន្នន័យពីក្នុងសៀវភៅសរសេរចូលទៅក្នុងសំបុត្រ
- ចុះហត្ថលេខា បោះត្រា និងផ្ដល់សំបុត្រទៅឱ្យអ្នកស្នើសុំចុះបញ្ជី ព្រមទាំងបញ្ជាក់ ប្រាប់គាត់ថា សូមរក្សាទុកសំបុត្រនេះ ឱ្យបានល្អព្រោះច្បាប់ដើមមានតែមួយ និងចេញតែម្ដងគត់ក្នុងមួយជីវិត
- ករណីចង់យកទៅប្រើប្រាស់ដោយប្រការណាមួយ ត្រូវតែសុំចម្លងនៅឃុំ សង្កាត់(ក្នុងឆ្នាំ) និង ចម្លងនៅសាលាក្រុង ស្រុក ខណ្ឌ ឬក្រសួងមហាផ្ទៃ (ឆ្លងឆ្នាំ)។

**ខ. ចំពោះកូនដែលឪពុកម្ដាយជាជនបរទេស**

ជនបរទេស និងជនអន្តោប្រវេសន្ដ៍ដែលបានរស់នៅស្របច្បាប់ ហើយបានកើតទារកនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឪពុកម្ដាយទារកនោះ អាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល

ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។ ចំពោះជនបរទេស ឬជនអន្តោប្រវេសន៍ស្របច្បាប់ ការមករាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ត្រូវតែឪពុក និងម្តាយផ្ទាល់ទើបបាន គឺមិនអនុញ្ញាតឱ្យអ្នកដទៃមករាយការណ៍ជំនួសឡើយ។ លិខិតស្នាមនានាដែលឪពុកម្តាយទារកត្រូវបង្ហាញមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ៖

- លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- លិខិតឆ្លងដែននៃប្រទេសសាមីរបស់ឪពុក ម្តាយទារក និងទិដ្ឋាការដែលនៅមានសុពលភាព ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាដែលនៅមានសុពលភាព (ចំពោះជនបរទេស ជនអន្តោប្រវេសន៍)
- សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍។

**បញ្ជាក់** ៖ ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋាន ពិនិត្យឃើញលិខិតឆ្លងដែន ឬទិដ្ឋាការ (ជាសេចក្តីអនុញ្ញាតឱ្យចេញចូលស្នាក់នៅក្នុងប្រទេសកម្ពុជា ដែលតាមធម្មតាអាជ្ញាធរអន្តោប្រវេសន៍ បានបោះត្រាលើលិខិតឆ្លងដែនរបស់សាមីខ្លួន) ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសរយៈពេលកំណត់ មិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានកំណើតទេ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច។

**លិខិតស្នាមនានា ដែលទាក់ទងនឹងទារកនៃឪពុកម្តាយជាពលរដ្ឋខ្មែរ**

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និង សុំសំបុត្រកំណើតត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម

- លិខិតបញ្ជាក់ទទួលស្គាល់កំណើត
  - លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងទារកកើត បើទារកកើតនៅមន្ទីរពេទ្យ ឬ
  - លិខិតបញ្ជាក់ទទួលស្គាល់កំណើតរបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
  - កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពរបស់មណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ។
- លិខិតបញ្ជាក់របស់ឪពុកម្តាយទារក អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក បើឪពុកម្តាយទារក ពឹងពាក់សាច់ញាតិ ឬអ្នកជិតខាងឱ្យទៅរាយការណ៍ជំនួស
- សៀវភៅស្នាក់នៅដែលមានឈ្មោះឪពុក ម្តាយទារក
- សៀវភៅគ្រួសារដែលមានឈ្មោះឪពុក ម្តាយទារក (ប្រសិនបើមាន)

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឪពុក ម្ដាយទារក (ប្រសិនបើមាន)
- សេចក្ដីចម្លងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុក ម្ដាយទារក។ សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុក ម្ដាយទារក (ប្រសិនបើមាន)។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកនូវលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតទារក ក្នុងសំណុំឯកសារកំណើតនៅឃុំ ឬសង្កាត់

- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ ឬ លិខិតបញ្ជាក់ទទួលស្គាល់របស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពរបស់មណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- លិខិតរបស់ឪពុក ម្ដាយទារកបញ្ជាក់ពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក (ករណីឪពុកម្ដាយពឹងពាក់ញាតិជានីតិជនដែលរស់នៅជាមួយ ឪពុក ម្ដាយ ឱ្យទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតជំនួស)។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតដែលត្រូវរក្សាទុក។

## ២.១.៤. នីតិវិធីនៃការស្នើសុំសេចក្ដីចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត

ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និង សំបុត្របញ្ជាក់កំណើតក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ហើយត្រូវបោះត្រាផង។ ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតនៅក្នុងឆ្នាំដែលន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ឬក្រសួងមហាផ្ទៃ។

បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌ ដែលអភិបាលក្រុង ស្រុក ខណ្ឌធ្វើប្រតិភូកម្មឱ្យ និងបោះត្រាផង។ បើសុំចម្លង ឬសម្រង់នៅក្រសួងមហាផ្ទៃ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬអគ្គនាយករងទទួលបន្ទុក ឬប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន ដែលធ្វើប្រតិភូកម្មឱ្យ និងបោះត្រាផង។ ប្រជាពលរដ្ឋខ្មែររស់នៅស្រុបច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ៖

ការសុំចម្លង ឬសម្រង់សំបុត្រកំណើត នៅក្នុងឆ្នាំមិនទាន់ដាច់ អ្នកសុំត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទៅនោះ។ ការសុំចម្លង ឬ សម្រង់សំបុត្រកំណើត នៅក្នុងឆ្នាំដែលកន្លងផុតទៅ អ្នកសុំត្រូវដាក់ពាក្យសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ហើយស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ត្រូវផ្ញើពាក្យសុំចម្លង ឬ សុំស្រង់មកក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅទីនោះ។

អ្នកមកសុំចម្លង ឬសម្រង់សំបុត្រកំណើត ត្រូវយកសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រ បញ្ជាក់កំណើតមកជាមួយ។ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត ត្រូវយកសំបុត្របញ្ជាក់កំណើត ច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតមកជាមួយ។

**បញ្ជាក់** ៖ ករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចមកសុំចម្លងបាន ត្រូវមាន លក្ខខណ្ឌដូចខាងក្រោម៖

- រាយការណ៍ជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃការបាត់បង់ និង
- បញ្ជាក់ពីឈ្មោះឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន ដើម្បីឱ្យមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានងាយស្រួលក្នុងការស្វែងរក។

## ២.២. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

### ២.២.១. សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្រប តាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ។[9]

ការរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងពីរថានឹង រួមរស់ជាមួយគ្នាមិនត្រឹមតែរយៈពេលខ្លីប៉ុណ្ណោះទេតែគឺអស់មួយជីវិត។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាង ទៀតបានឡើយ ហើយគ្មានជនណាមួយអាចបង្ខំបុគ្គលម្នាក់ឱ្យរៀបអាពាហ៍ពិពាហ៍ ឬ រារាំងមិនឱ្យរៀប អាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។ អាពាហ៍ពិពាហ៍មានភាពសំខាន់ណាស់នៅក្នុងជីវិតមនុស្សម្នាក់ៗ ហេតុនេះហើយទើបច្បាប់បាន ចែង និងកំណត់យ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍មិនអាចបង្កើតទៅ តាមអំពើចិត្តរបស់គូភាគីបានឡើយ ពោលគឺត្រូវគោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមគោលការណ៍ច្បាប់ ដូចដែលមាន

[9] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៤៥។

ថែងនៅក្នុងបទដ្ឋានគតិយុត្តនៃប្រទេសកម្ពុជា។ គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រម ដោយសេរី និងពេញលេញពីអនាគតប្តី ប្រពន្ធឡើយ។[10]

បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ប៉ុន្តែក្នុងករណីដែល ភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុតិចជាង១៦(ដប់ប្រាំមួយ)ឆ្នាំ អាច រៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាល សម្រាប់នីតិជនរបស់អនីតិជននោះ។ អាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពមួយជីវិតរវាងបុរស និងនារី ដូច្នេះបុរស និងនារីនោះចាំបាច់ត្រូវបានពេញវ័យទាំងផ្នែកសេដ្ឋកិច្ច សង្គម ផ្លូវចិត្ត និងផ្លូវកាយ។

អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការដាក់ពាក្យសុំរៀប អាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ នេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

តាមទំនៀមទម្លាប់ប្រពៃណីខ្មែរពីបុរាណមកយើងសង្កេតឃើញថា ការរៀបអាពាហ៍ពិពាហ៍គឺប្រព្រឹត្តបាន តែរវាងបុរសនិងនារីតែប៉ុណ្ណោះ ព្រោះគេជឿជាក់ថាអាពាហ៍ពិពាហ៍ដែលកើតឡើងរវាងភេទដូចគ្នា គឺវាផ្ទុយនឹង ក្រឹត្យក្រមធម្មជាតិ និងមិនអាចបង្កើតកូនដើម្បីបន្តពូជពង្សវង្សត្រកូលបានឡើយ។

### ក. ប្រភេទនៃការរៀបអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍ មាន៤ប្រភេទ ដូចខាងក្រោម

- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេសដែលរស់នៅស្របច្បាប់ នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និង ជនបរទេសដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរនិងជនបរទេស ដែលកំពុងរស់ នៅស្របច្បាប់ឯបរទេស។

### ខ. លក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន

- បុរសត្រូវមានអាយុចាប់ពី ២០ឆ្នាំឡើង
- នារីត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង
- ក្នុងករណីពិសេស បុរសដែលមានអាយុមិនគ្រប់២០ឆ្នាំ និងនារីមានអាយុមិនគ្រប់១៨ឆ្នាំ អាចរៀប អាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ព្រមទាំងមានការយល់ព្រមពីឪពុក ម្តាយ ឬ អាណាព្យាបាល។

[10] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម, តុលា ២០០៩, មាត្រា២៣ ចំណុចទី៣។

- ក្នុងករណីសហព័ទ្ធណាមួយបាត់ខ្លួនលើសពីមួយឆ្នាំ ដោយគ្មានអ្នកណាដឹងថាស្លាប់ ឬរស់ សហព័ទ្ធម្នាក់ទៀត អាចរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន។ ករណីនេះគ្មានជនណាអាចប្តឹងបដិសេធអាពាហ៍ពិពាហ៍បានឡើយ ទោះជាសហព័ទ្ធដែលបាត់ខ្លួនត្រឡប់មកវិញក៏ដោយ។

**គ. លក្ខខណ្ឌដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន**

- បុគ្គលមានភេទដូចគ្នា
- បុគ្គលគ្មានពលានុភាពនៃលិង្គ
- បុគ្គលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគដែលមិនទាន់ព្យាបាលជាដាច់
- ជនវិកលចរិក មិនដឹងខុសត្រូវ
- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ
- បុគ្គលដែលជាប់ចំណងសាច់ញាតិលោហិត (ញាតិដែលមានឈាមជាមួយគ្នា) ឬញាតិពន្ធ (សាច់ថ្លៃ) ក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះជាចំណងនោះមានខាន់ស្លា ឬឥតខាន់ស្លា ឬ សាច់ញាតិចិញ្ចឹម។

### ២.២.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ រួមមានៈ

- សំបុត្រអាពាហ៍ពិពាហ៍
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២ - ២០០៧)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ក្នុងឆ្នាំមិនទាន់ដាច់)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ក្នុងឆ្នាំដែលកន្លងផុតទៅ)
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (សម្រាប់ចម្លងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅក្រសួងមហាផ្ទៃ)
- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍។

### ២.២.៣. នីតិវិធីនៃការស្នើសុំសំបុត្រអាពាហ៍ពិពាហ៍

**ក. អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងខ្មែរ**

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅឋានសាមីខ្លួនខាងនារី។ បុរស នារីដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ ប៉ុន្តែពុំទាន់បានសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យការរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ មានលក្ខណៈជាប្តីប្រពន្ធពេញច្បាប់ ឬ

ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈពេញច្បាប់ សាមីខ្លួនទាំងពីររូប ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន។ បុរស នារី ដែលមកសុំច្បាប់រៀបអាពាហ៍ពិពាហ៍ ត្រូវភ្ជាប់មកជាមួយនូវ៖

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ របស់សាមីខ្លួនទាំង២នាក់។ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយទាំងពីរនាក់ ត្រូវចេញដោយមេឃុំ ចៅសង្កាត់សាមី
  - បើក្នុងករណីមេម៉ាយ ឬពោះម៉ាយ ដោយប្តី ឬប្រពន្ធស្លាប់ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬ សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព (ករណីបើសហព័ទ្ធដែលបានស្លាប់នោះមិនធ្លាប់បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា សហព័ទ្ធដែលនៅរស់ ត្រូវសុំបញ្ជាក់ភាពនៅលីវ មិនមែនសុំបញ្ជាក់ភាពមេម៉ាយ ឬពោះម៉ាយឡើយ)
  - បើក្នុងករណីមេម៉ាយ ឬពោះម៉ាយ ដោយប្តី ឬប្រពន្ធស្លាប់ ត្រូវភ្ជាប់មកជាមួយនូវសាលក្រមតុលាការ។
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលមានទិន្នន័យរបស់សាមីខ្លួនទាំងពីរនាក់ច្បាស់លាស់ និងត្រឹមត្រូវ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់សាមីខ្លួនទាំងពីរនាក់ (ប្រសិនបើមាន)។

នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់ចំពោះបុរស នារីដែលបានដាក់ពាក្យសុំនោះ។

- បើពិនិត្យទៅឃើញថា មិនមានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានទេ មន្ត្រីអត្រានុកូលដ្ឋាន មិនអាចអនុញ្ញាតឱ្យបុរស នារីនោះរៀបអាពាហ៍ពិពាហ៍បានឡើយ
- បើពិនិត្យទៅឃើញថា មានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ជាសាធារណៈ ចំនួន ០៥ច្បាប់ ដោយៈ
  - ០១ ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋានសាមីខ្លួននារី
  - ០១ ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
  - ០១ ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
  - ០២ ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈ នៅលំនៅដ្ឋានសាមីខ្លួនបុរស០១ច្បាប់ និង នៅសាលាឃុំ ឬ សង្កាត់សាមីខ្លួនបុរស ០១ច្បាប់។

ករណីបុរស និងនារីដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ក្រោយពីពិនិត្យឃើញថា មានឯកសារគ្រប់គ្រាន់ និង ត្រឹមត្រូវហើយ ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០៣ច្បាប់ ដូចខាងក្រោម៖

- ០១ ច្បាប់ បិទផ្សាយជាសាធារណៈនៅផ្ទះសាមីខ្លួនទាំងពីររូប
- ០១ ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ ឬសង្កាត់សាមី
- ០១ ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមី។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍ អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់។ បើមានបណ្តឹងជំទាស់ នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានដោះស្រាយរួចរាល់តាមគោលការណ៍ ដែលបានចែងក្នុង ក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរប័ណ្ណប្រកាសអាពាហ៍ពិពាហ៍:

- នាមត្រកូលនិងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ និង ទីលំនៅបច្ចុប្បន្ននៃអនាគតប្តី ឬប្រពន្ធ
- នាមត្រកូលនិងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្នរបស់ឪពុក ម្តាយនៃអនាគតប្តីប្រពន្ធ (បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ផង)។

### ខ. អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ការរៀបអាពាហ៍ពិពាហ៍ឱ្យសមស្របតាមផ្លូវច្បាប់មិនមែនត្រឹមតែគោរពទៅតាមលក្ខខណ្ឌគ្រឹះតែប៉ុណ្ណោះទេ តែទាមទារឱ្យមានការគោរពនូវលក្ខខណ្ឌទម្រង់ផងដែរ។ លក្ខខណ្ឌទម្រង់ គឺទាក់ទងនឹងនីតិវិធីនៃការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅមន្ត្រីអត្រានុកូលដ្ឋានជាដើម។ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងបរទេសគឺវាស្រដៀងគ្នានឹងការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ គ្រាន់តែមានភាពខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ។ ជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌ ហើយត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធី។

ត្រូវចាត់ទុកជាជនបរទេស គឺជាជនណាដែលគ្មានសញ្ជាតិជាខ្មែរ ទោះបីជននោះស្ថិតនៅក្រៅប្រទេសកម្ពុជាក្តី ឬកំពុងស្ថិតនៅ ឬស្នាក់នៅក្នុងប្រទេសកម្ពុជាក្តី។

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។ ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេស ហើយក្រសួង

ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យចុះបញ្ជីរួច ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

**សំណុំឯកសារជនបរទេសមាន ៖**

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារីទំហំ ៤x៦ ថតចំពីមុខ ក្នុងរយៈពេល ០៣ខែ ចុងក្រោយ
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស និងមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- សៀវភៅការងារចំពោះសាមីខ្លួនជនបរទេស ដែលប្រកបមុខរបរធ្វើអាជីវកម្ម ឬពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងឯកសារបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាព ពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា។

**សំណុំឯកសារពលរដ្ឋខ្មែរមាន ៖**

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារីទំហំ ៤x៦ ថតចំពីមុខ ក្នុងរយៈពេល ០៣ខែចុងក្រោយ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ដែលមានចុះបញ្ជីច្បាស់លាស់ និងត្រឹមត្រូវ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ចៅសង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដែលនៅមានសុពលភាព (ករណីពោះម៉ាយ ឬមេម៉ាយ ដោយប្រពន្ធ ឬប្តីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬមេម៉ាយ ដោយលែងលះ ត្រូវមានសាលក្រមស្ថាពរពីតុលាការ)

- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- សៀវភៅគ្រួសារដែលមានទិន្នន័យច្បាស់លាស់ និងត្រឹមត្រូវ។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ក្នុងការអនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

**គ. អាពាហ៍ពិពាហ៍រវាងជនបរទេស និងជនអន្តោប្រវេសន៍ ជាមួយជនបរទេស និងជនអន្តោប្រវេសន៍ដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា**

ជនបរទេស និងជនអន្តោប្រវេសន៍ដែលរស់នៅស្របច្បាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍បានដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន នៅទីកន្លែងដែលខ្លួនស្នាក់នៅជាប់លាប់ដោយប្រាប់ពីទីកន្លែង និងពេលវេលារៀបអាពាហ៍ពិពាហ៍នោះឱ្យបានច្បាស់លាស់។ ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អាចទៅសុំចុះនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា (ប្រសិនបើមាន) ឬអាចទៅសុំចុះនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ដោយអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ ឬសង្កាត់ អាចចុះសៀវភៅអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍នេះបាន ដោយអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

### ២.២.៤. នីតិវិធីនៃការស្នើសុំសំបុត្រចម្លង និង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំសង្កាត់ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ហើយត្រូវបោះត្រាផង។ ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌសាមី និងនៅក្រសួងមហាផ្ទៃ។ បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាប់ហត្ថលេខានោះដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង។ បើសុំចម្លង ឬសម្រង់នៅក្រសួងមហាផ្ទៃ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬអគ្គនាយករងទទួលបន្ទុក ឬប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន ដែលធ្វើប្រតិភូកម្មឱ្យ និងបោះត្រាផង។ ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ៖

ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង។

ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅទីនោះ។ អ្នកមកសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមកជាមួយ។ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវយកសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមមកជាមួយ។

## ២.៣. អត្រានុកូលដ្ឋានមរណភាព

### ២.៣.១. សញ្ញាណនៃមរណភាព

បុគ្គលភាពគតិយុត្តបញ្ចប់នៅពេលមនុស្សស្លាប់។ មរណភាពត្រូវមានការបញ្ជាក់ដោយគ្រូពេទ្យ ទើបមានលក្ខណៈត្រឹមត្រូវ ឬគេអាចសន្មតថាស្លាប់ គឺនៅពេលបេះដូងលែងធ្វើចលនា ទន្ទឹមជាមួយគ្នាការឈប់ដកដង្ហើមជារៀងរហូត ហើយបើឱ្យច្បាស់លាស់ គឺភាពឡើងរឹងនៃសាកសព។ ការស្លាប់គេសន្មតថាមានសាកសពមួយ ព្រោះសាកសពជាភស្តុតាងបង្ហាញថាមានការស្លាប់។ បើគ្មានសាកសពទេ ចាំបាច់ត្រូវមានសាលក្រមប្រកាសពីការបាត់ខ្លួន ព្រោះសាលក្រមនេះមានអានុភាពអាចចាត់ទុកថា ជនដែលបាត់ខ្លួនស្លាប់បាត់ទៅហើយ។ ជនដែលពាក់ព័ន្ធនឹងអ្នកស្លាប់ ត្រូវប្តឹងទៅមន្ត្រីអត្រានុកូលដ្ឋានយ៉ាងយូរ១៥ថ្ងៃ ក្រោយទទួលមរណភាព។[11] មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញលិខិតអនុញ្ញាតឱ្យយកសាកសពនោះទៅបញ្ចុះ ឬបូជា។

### ២.៣.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព រួមមាន

- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២ - ២០០៧)
- សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំសម្រាប់ចម្លងនៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ចម្លងនៅ ក្រុង ស្រុក ខណ្ឌ និងនៅក្រសួងមហាផ្ទៃ)
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព (សម្រាប់ចម្លងនៅក្រុង ស្រុក ខណ្ឌ និងនៅក្រសួងមហាផ្ទៃ)។

[11] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០, មាត្រា៣៥

### ២.៣.៣. នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋានមរណភាព

**ក.មរណភាពរបស់ពលរដ្ឋខ្មែរ**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ច នៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសពក្នុងករណីអ្នកស្លាប់ដោយចាស់ជរា ឬដោយជម្ងឺ (បញ្ជាក់ពីជម្ងឺជាក់លាក់) ឬដោយគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ។ បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាតដែលអាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យពីអំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណាដែលបានឃើញ ឬដឹងព្រហេតុការណ៍នោះ ត្រូវរាយការណ៍ភ្លាមទៅកាន់អាជ្ញាធរមានសមត្ថកិច្ចពីកន្លែងនៃអ្នកស្លាប់នោះ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយឱ្យបានទាន់ពេលវេលា។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន។

**ក.១. មរណភាពក្នុងរយៈពេលកំណត់១៥ថ្ងៃ**

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម៖

- **លិខិតជូនដំណឹងមរណភាព ៖**
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
  - លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
  - លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ

- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព បើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកស្លាប់
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)

សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់ ត្រូវមានឯកសារបន្ថែមទៀត៖

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលមានសុពលភាព
- ទិដ្ឋាការ ឬប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសុពលភាព
- ករណីឯកសារណាមួយខាងលើនេះបាត់បង់ ត្រូវមានលិខិតស្នាមនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់។

**បញ្ជាក់** ៖ បើលិខិតស្នាមណាមួយមានការសង្ស័យ មន្ត្រីអត្រានុកូលដ្ឋានត្រូវទំនាក់ទំនងជាមួយនឹងសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងលិខិតស្នាមនោះ។

**ក.២. មរណភាពហួសរយៈពេលកំណត់១៥ថ្ងៃ**

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម ៖

**លិខិតជូនដំណឹងមរណភាព ៖**

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព បើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកស្លាប់
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់ ត្រូវមានឯកសារបន្ថែមទៀត៖
  - លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលមានសុពលភាព
  - ទិដ្ឋាការ ឬប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសុពលភាព

ករណីឯកសារណាមួយខាងលើនេះបាត់បង់ ត្រូវមានលិខិតស្នាមនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់។

**ក.៣. មរណភាពទុកឱ្យហួសឆ្នាំ**

បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសាលក្រមពីតុលាការរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។

**អ្នកប្តឹងត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម៖**

- សៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំ
- សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការរាជធានី ខេត្តសាមី
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅដែលមានឈ្មោះអ្នកស្លាប់ ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកប្តឹងសុំ (ប្រសិនបើមាន)។

**មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព ៖**

- សាលក្រមបញ្ជាក់ពីមរណភាពរបស់សាលាដំបូងរាជធានី ខេត្តសាមី
- មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

**ខ. មរណភាពរបស់ជនបរទេស និងជនអន្តោប្រវេសន៍ដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា**

ជនបរទេស ឬជនអន្តោប្រវេសន្តរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដែលស្លាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ ឬអាជ្ញាធរមានសមត្ថកិច្ចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលស្លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។ បើចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលា

ឃុំ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរខ្មែរដោយយកសូរតាមលំនាំអក្សរឡាតាំង។ របៀបសរសេរចុះបញ្ជីមរណភាពសម្រាប់ជនបរទេស ឬជនអន្តោប្រវេសន្ត ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីមរណភាពរបស់ពលរដ្ឋខ្មែរដែរ លើកលែងតែចំណុចមួយចំនួន ដូចខាងក្រោម៖

- សញ្ជាតិ : ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន្តដែលស្លាប់ (តាមលិខិតឆ្លងដែន)
- ទីលំនៅឯបរទេស : ត្រូវសរសេរទីលំនៅ នៅប្រទេសដើមរបស់អ្នកស្លាប់ជាអក្សរខ្មែរ ដោយបញ្ជាក់ទីលំនៅនៅឯបរទេសឱ្យបានពិតប្រាកដ
- លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃទី ខែ ឆ្នាំ : ត្រូវសរសេរលេខលិខិតឆ្លងដែនរបស់អ្នកស្លាប់ និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព
- ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃ ខែ ឆ្នាំ : ត្រូវសរសេរលេខទិដ្ឋាការ ឬលេខលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព

**បញ្ជាក់** ៖ បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ត្រីមានសមត្ថកិច្ចភ្លាម។

### ២.៣.៤. នីតិវិធីនៃការស្នើសុំសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានមរណភាព

ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព គឺសម្រាប់អ្នកស្លាប់ទាំងឡាយដែលបានស្លាប់ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ និងអ្នកស្លាប់ទាំងឡាយ មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ដែលមានសំបុត្រមរណភាពច្បាប់ដើម។ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត១៥ថ្ងៃក្រោយពីថ្ងៃទទួលមរណភាព។ ក្រោយថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាព នេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន ១០០០រៀល (មួយពាន់រៀល) សម្រាប់ប្រជាពលរដ្ឋដែលមានទៅលំនៅ នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤០០០រៀល (បួនពាន់រៀល) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ។ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ សង្កាត់ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ហើយត្រូវបោះត្រាផង។ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌសាមី ឬនៅក្រសួងមហាផ្ទៃ។ បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះ

ដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង។ បើសុំចម្លង ឬសម្រង់នៅក្រសួងមហាផ្ទៃត្រូវចុះហត្ថលេខា ដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬអគ្គនាយករងទទួលបន្ទុក ឬប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន ដែលធ្វើប្រតិភូកម្មឱ្យ និងបោះត្រាផង។

ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសនោះ៖

- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅទីនោះ។

អ្នកមកសុំចម្លង ឬសម្រង់សំបុត្រមរណភាព ត្រូវយកសំបុត្រមរណភាពច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រមរណភាពមកជាមួយ។ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ត្រូវយកសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពមកជាមួយ

**បញ្ជាក់** ៖ ករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចមកសុំចម្លងបាន ត្រូវមានលក្ខខណ្ឌដូចតទៅ៖ រាយការណ៍ជាលាយលក្ខអក្សរឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃការបាត់បង់។ បញ្ជាក់ពីឈ្មោះឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន ដើម្បីមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានងាយស្រួលក្នុងការស្វែងរក។

**ក. លិខិតស្នាមនានា ដែលពាក់ព័ន្ធនឹងសព**

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម ៖

- លិខិតជូនដំណឹងមរណភាព
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ ឬ

- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងពន្ធនាគារ។

- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)
- សំបុត្រមរណភាពច្បាប់ដើមចាស់ ក្នុងករណី អ្នកស្លាប់មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រមរណភាពច្បាប់ដើម ដើម្បីប្តូរយកសំបុត្រមរណភាពថ្មី។

សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្ត ត្រូវមានឯកសារ២បន្ថែមទៀត

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលនៅមានសុពលភាព
- ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅមានសុពលភាព។

**បញ្ជាក់** បើលិខិតស្នាមណាមួយមានការសង្ស័យ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើទំនាក់ទំនងជាមួយនឹងសមត្ថកិច្ចដែលពាក់ព័ន្ធនឹងលិខិតស្នាមនោះ។

**មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព**

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀយ ករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ។
- សំបុត្រមរណភាពច្បាប់ដើមចាស់ ក្នុងករណី អ្នកស្លាប់មុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ហើយមានសំបុត្រមរណភាពច្បាប់ដើម ដើម្បីប្តូរយកសំបុត្រមរណភាពថ្មី។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

### ខ. ការសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសព

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬអ្នកមានភារកិច្ច នៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសពក្នុងករណី

អ្នកស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃបទឧក្រិដ្ឋណាមួយ។ បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាតដែលអាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬ បញ្ចុះសពតាមការសម្រេចនោះ។ បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណាដែលបានឃើញ ឬដឹងឮហេតុការណ៍នោះ ត្រូវរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ភ្លាម ដើម្បីឱ្យសមត្ថកិច្ចជំនាញនានាពិនិត្យស្រាវជ្រាវ និង ដោះស្រាយរួសរាន់។

ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬ បញ្ចុះសពបាន។ បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលអ្នកស្លាប់បានរស់នៅ មុនពេលស្លាប់ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់នោះឱ្យទៅយកសពមកធ្វើបុណ្យ និង ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ ឬសង្កាត់ដែលអ្នកស្លាប់នោះបានរស់នៅជាប់លាប់មុនពេលស្លាប់។ បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬបញ្ចុះសពនោះ និង ចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ។ នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព ដើម្បីសុំលិខិតអនុញ្ញាតធ្វើបុណ្យបូជា ឬបញ្ចុះសព សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង សុំសំបុត្រមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យមើលលិខិតស្នាម (ដូចមានបរិយាយនៅចំណុច ៣.២.១.) ឱ្យបានច្បាស់លាស់ បើឃើញត្រឹមត្រូវទៅតាមការកំណត់ហើយត្រូវសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពទៅតាមលក្ខណៈនៃការស្លាប់នោះ។

# ជំពូកទី ៣ ៖

# សារៈសំខាន់ បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣ : សារៈសំខាន់ បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១. សារៈសំខាន់អត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋានដើរតួនាទីជាបុរេលក្ខណៈទូលំទូលាយ ដែលនឹងត្រូវបង្កើតឡើងក្នុងការការពាររាល់បុគ្គលទាំងអស់ គាំទ្រពួកគេឱ្យទទួលបានសិទ្ធិពលរដ្ឋ សិទ្ធិផ្លូវច្បាប់ សិទ្ធិសង្គម សិទ្ធិនយោបាយ ក៏ដូចជាទទួលបាននូវសេវាកម្មទាំងឡាយដែលពួកគេមានសិទ្ធិទទួលបាន។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្មដែលមានមុខងារដំណើរការល្អ និងជួយធានាការចូលរួមក្នុងការបោះឆ្នោត ជួយសម្រួលដល់ការផ្តល់សេវាសាធារណៈ និងរួមចំណែកដល់ស្ថិរភាពសន្តិសុខរបស់ប្រទេសទាំងមូលទៀតផង។ ការប្រើប្រាស់សិទ្ធិមនុស្សជាច្រើន ត្រូវតែអាស្រ័យដោយផ្ទាល់ទៅលើវត្តមានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានដំណើរការល្អ។ ប្រព័ន្ធនេះនឹងជួយលើកកម្ពស់សមភាពយេនឌ័រទប់ស្កាត់និងកាត់បន្ថយហានិភ័យនៃនិរបេតិជន ការជួញដូរមនុស្ស ការរៀបអាពាហ៍ពិពាហ៍កុមារ ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ពលកម្មកុមារ និងហានិភ័យផ្សេងៗទៀត។ សំបុត្រកំណើតបានផ្តល់នូវអត្តសញ្ញាណផ្លូវច្បាប់មួយសម្រាប់បង្កើតអត្តសញ្ញាណបុគ្គលហើយអត្តសញ្ញាណបុគ្គលនេះនឹងអាចយកមកប្រើប្រាស់បានដោយបន្ថែមនូវទិន្នន័យជីវសាស្ត្រមួយចំនួនទៀត តាមរយៈការចេញឯកសារអត្តសញ្ញាណនានា ដូចជាអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងឯកសារផ្សេងៗទៀតទៅតាមការចាំបាច់។ អត្តសញ្ញាណផ្លូវច្បាប់គឺជាភស្តុតាងដែលបញ្ជាក់ថា រដ្ឋមួយបានទទួលស្គាល់ ការពារ និង គោរពជីវិតរបស់មនុស្សទាំងអស់ ដែលនេះគឺជាការទទួលខុសត្រូវរបស់រដ្ឋនោះ។

ការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិថា ជាការកត់ត្រានូវរាល់ព្រឹត្តិការណ៍ជីវិត ដោយមានលក្ខណៈជាសកល ជាបន្តបន្ទាប់ ជាអចិន្ត្រៃយ៍ ដោយខានមិនបាន ដែលត្រូវធ្វើឡើងតាមរយៈអនុក្រឹត្យ ឬ បទប្បញ្ញត្តិផ្សេងៗស្របតាមតម្រូវការផ្នែកច្បាប់របស់ប្រទេសនីមួយៗ។ នេះគឺជាការកត់ត្រាការចងក្រងឯកសារព្រឹត្តិការណ៍ក្នុងជីវិតរបស់មនុស្ស (រួមមានកំណើត អាពាហ៍ពិពាហ៍ ការលែងលះ ការសុំកូន និង មរណភាព) ហើយក៏ជាមុខងារជាមូលដ្ឋានដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលផងដែរ។ ជាក់ស្តែង គឺការផ្តល់ការបញ្ជាក់តាមផ្លូវច្បាប់អំពីព្រឹត្តិការណ៍ជីវិតរបស់បុគ្គលគ្រប់រូប ដែលជាការគាំទ្រក្នុងការបង្កើតអត្តសញ្ញាណខាងផ្លូវច្បាប់ ការបង្កើតឯកសារអត្តសញ្ញាណជាតិ ភាពត្រឹមត្រូវនៃទិន្នន័យប្រជាជន ព្រមទាំងការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ម៉្យាងវិញទៀត បង្កើតបានជាប្រភពទិន្នន័យតាមតម្រូវការសម្រាប់ប្រើប្រាស់ក្នុងការវិភាគទាំងឡាយ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ព្រមទាំងសម្រាប់បង្កើតរបាយការណ៍អំពីស្ថិតិអត្រានុកូលដ្ឋាន និងរបាយការណ៍អំពីប្រជាជន។

អត្រានុកូលដ្ឋាន ជាសេវាមូលដ្ឋានរបស់រដ្ឋ ដែលផ្តល់ប្រយោជន៍ចំពោះប្រជាពលរដ្ឋផង និងចំពោះសង្គមជាតិផង។ អត្រានុកូលដ្ឋានជាធាតុដើមមួយសម្រាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងផ្នែកធានារ៉ាប់រង

ដើម្បីសង្គមមានភាពសុខសាន្ត និង សុវត្ថិភាពដ៏រឹងមាំ។ សៀវភៅអត្រានុកូលដ្ឋានបានតម្កល់ទុកជាសក្ខីកម្ម ដែលមានប្រយោជន៍សម្រាប់ទិន្នន័យវិភាគនូវឯកសារសុខភាព អប់រំ និងសេវាសង្គមគ្រប់ប្រភេទ ដូចជា សម្រាប់ធ្វើបញ្ជីបោះឆ្នោត ទិញ លក់ដីធ្លី ទិញលក់ចលនទ្រព្យ និងអចលទ្រព្យ និងសម្រាប់ទារពន្ធដារ ជាដើម។ អត្រានុកូលដ្ឋាន ផ្តល់នូវសារៈប្រយោជន៍ សំខាន់ពីរយ៉ាង គឺចំពោះសង្គមជាតិ និងចំពោះខ្លួនយើង។

### ៣.១.១. ចំពោះសង្គមជាតិ

- **ជួយពង្រឹងនីតិរដ្ឋ និងអភិវឌ្ឍន៍ប្រទេសជាតិ :** មានន័យថា អត្រានុកូលដ្ឋានជាយុទ្ធសាស្ត្ររួម ក្នុងការធានានូវការអនុវត្តច្បាប់ ពីព្រោះថា បើប្រជាពលរដ្ឋមានឯកសារអត្រានុកូលដ្ឋានគ្រប់ៗគ្នា ការប្រតិបត្តិច្បាប់ និងដំណើរការស្ថាប័ននានា អាចប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធិភាពខ្ពស់។ ម៉្យាងទៀត ក្នុងការលើកស្ទួយសិទ្ធិមនុស្ស ការចុះសៀវភៅអាពាហ៍ពិពាហ៍ នាំឱ្យសហព័ទ្ធ ត្រូវគោរពសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ដូចជាជួយទប់ស្កាត់ប្តី ឬប្រពន្ធមិនឱ្យទៅរៀបអាពាហ៍ពិពាហ៍ ជាមួយបុគ្គលផ្សេងទៀតតាមទំនើងចិត្តបាន។
- **លើកកម្ពស់កិត្យានុភាពជាតិ :** បើប្រជាពលរដ្ឋយើងមានសំណុំឯកសារផ្ទាល់ខ្លួនគ្រប់ៗគ្នានោះ មានន័យថា ពលរដ្ឋយើងបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយតម្រូវឱ្យខ្លួនមានករណីយកិច្ចក្នុងសង្គម ដែលជាហេតុធ្វើឱ្យសង្គមមានការអភិវឌ្ឍ តាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។ ទាំងនេះហើយ ជាភាពថ្លៃថ្នូរ និង កិត្តិយសរបស់ប្រទេសជាតិ។
- **ជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ :** ព្រោះថាឯកសារអត្រានុកូលដ្ឋាន បានបង្ហាញប្រាប់នូវអត្តសញ្ញាណនៃរូបវន្តបុគ្គលក្នុងទំនាក់ទំនងគតិយុត្ត (សកម្មភាពទាក់ទងនឹងសិទ្ធិនិងកាតព្វកិច្ច)។ ហេតុដូចនេះ ឯកសារអត្រានុកូលដ្ឋានមានប្រយោជន៍ជាសំណុំលិខិតយុត្តិកម្មដែលត្រូវយកជាភស្តុតាងក្នុងនីតិវិធីតុលាការ។

### ៣.១.២. ចំពោះខ្លួនយើង

- សម្រាប់បញ្ជាក់ពីឋានៈ និងសិទ្ធិនៅក្នុងរង្វង់គ្រួសារ
- សម្រាប់សុំលិខិតឆ្លងដែន
- សម្រាប់សុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងចេញសៀវភៅគ្រួសារ និងប័ណ្ណស្នាក់នៅ
- សម្រាប់សុំចូលបម្រើការងារផ្សេងៗ ដើម្បីបញ្ជាក់ថា បុគ្គលម្នាក់មានអាយុអាចបំពេញការងារបាន
- សម្រាប់ចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត
- សម្រាប់ពេលសវនាការ ឬ ពេលដោះស្រាយវិវាទ។

## ៣.២. បញ្ហាប្រឈម និង ដំណោះស្រាយ

### ៣.២.១. បញ្ហាប្រឈម

#### ក. ភាពខ្វះចន្លោះនៃក្របខណ្ឌ និងការអនុវត្តច្បាប់

បច្ចុប្បន្នកម្ពុជាពុំទាន់មានច្បាប់ស្តីពីអត្រានុកូលដ្ឋាននៅឡើយនោះទេ ប៉ុន្តែយើងក៏នៅតែមានលិខិតបទដ្ឋានគតិយុត្តដែលអាចជាមូលដ្ឋានច្បាប់សម្រាប់អនុវត្តការងារអត្រានុកូលដ្ឋាននេះបានផងដែរ។ ម៉្យាងទៀតកម្ពុជានៅជាប្រទេសដែលក្មេងខ្ចី ព្រោះទើបងើបចេញពីការបំផ្លិចបំផ្លាញនៃសង្គ្រាមរុាំរ៉ៃ បើទោះបីជាមានអរិយធម៌ដ៏ចំណាស់យូរលង់ណាស់មកហើយក្តី ដោយបញ្ហានេះធ្វើឱ្យកម្ពុជាមានភាពលំបាក ក្នុងការខិតខំប្រឹងប្រែងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលបំផ្លិចបំផ្លាញ ហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត និងតុលាការ។ ជាលទ្ធផលកម្ពុជានៅតែសម្រេចបានក្រមរដ្ឋប្បវេណីថ្មី នៅខែធ្នូ ឆ្នាំ២០១១។ ក្រមរដ្ឋប្បវេណីថ្មីនេះ ក៏មានបញ្ញត្តិពាក់ព័ន្ធមួយចំនួនទៀតដូចជា ច្បាប់ស្តីពីសញ្ជាតិ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ស្តីពីការសុំកូន។ល។ ជាពិសេសអនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋានដែលចេញតាំងពីឆ្នាំ២០០០ និងដាក់ឱ្យប្រើប្រាស់បានក្នុងឆ្នាំ២០០២ ហើយត្រូវបានកែសម្រួលជាច្រើនលើក ច្រើនសារតាមស្ថានភាពសង្គមផលវិបាក និងការអនុវត្តដែលប្រឈមជាក់ស្តែង។

មកទល់ថ្ងៃនេះកម្ពុជាពុំទាន់មានកាតព្វកិច្ចផ្លូវច្បាប់ណាមួយដែលតម្រូវឱ្យមន្ទីរពេទ្យ ឬមូលដ្ឋានសុខាភិបាលរាយការណ៍ពីកំណើត និងមរណភាពនៅឡើយនោះទេ ជាពិសេសច្បាប់ពុំបានចែងពីបុគ្គលណាម្នាក់ដែលទទួលខុសត្រូវក្នុងការបញ្ជាក់ពីមូលហេតុនៃការស្លាប់។ ម៉្យាងវិញទៀត ដោយយោងទៅលើអនុក្រឹត្យលេខ១០៣ បានចែងថាត្រូវមានឯកសារផ្លូវការមុននឹងបញ្ចុះសព ហើយឯកសារផ្លូវការនេះត្រូវចេញដោយមេឃុំចៅសង្កាត់ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ការងារនេះគឺមិនត្រូវបានអនុវត្តនោះទេ ខ្លឹមសារនេះគេឃើញមានអនុវត្តឱ្យបញ្ចុះសពត្រូវបានស្នើផ្អែកលើករណីពិសេសតែប៉ុណ្ណោះ។ អនុក្រឹត្យនេះ ក៏មិនបានកំណត់ពីតួនាទី និងការទទួលខុសត្រូវខុសច្បាស់លាស់នៃអ្នកពាក់ព័ន្ធដទៃទៀតដូចជាក្រសួងសុខាភិបាល ផ្នែកប៉ូលីស ក្រសួងផែនការ ...។ លើសពីនេះ អនុក្រឹត្យនេះក៏ពុំបានលើកឡើងអំពីថវិកាគាំទ្រសម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។ យើងឃើញថាថវិកាគាំទ្រនេះត្រូវបានចាត់ទុកជាផ្នែកមួយនៃផែនការអភិវឌ្ឍ ឃុំសង្កាត់តែប៉ុណ្ណោះ។ អនុក្រឹត្យនេះក៏ពុំបានគ្របដណ្តប់ទៅលើកម្មករចំណាកស្រុក និងអ្នកសុំជ្រកកោន ឬជនភៀសខ្លួននោះឡើយ។ សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្រៅប្រទេស ពួកគេអាចទទួលបានសំបុត្រកំណើតនៅពេលដែលពួកគេមកប្រទេសកម្ពុជាតែប៉ុណ្ណោះ ហើយប្រសិនបើពួកគេមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា បើទោះបីជាមានមាត្រា១១ នៃអនុក្រឹត្យលេខ១០៣ អនក្រប.ក បានចែងពីតួនាទីមន្ត្រីអត្រានុកូលដ្ឋានសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្រៅប្រទេសក៏ដោយ។ ជាក់ស្តែងត្រូវមានសេចក្តីណែនាំរួមមួយដែលឱ្យមានការពិភាក្សារវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីអនុវត្តលើការងារនេះ។

តាមរយៈផែនការយុទ្ធសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម ២០១៧-២០២៦ ក៏បានលើកឡើងថារាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់អំពីតម្រូវការជាបន្ទាន់នូវកំណែទម្រង់ទូលំទូលាយលើផ្នែកច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាននេះ ព្រោះបច្ចុប្បន្ននេះកម្ពុជាត្រូវមើលឃើញថានៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋាននៃប្រព័ន្ធចុះបញ្ជី ជាពិសេសប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន តាមបែបទំនើប (ប្រព័ន្ធកុំព្យូទ័រ និងការងារអត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានតាមបែបទំនើបបែបនេះនៅឡើយទេ។ មកទល់ពេលនេះ តាមការស្រាវជ្រាវ យើងបានដឹងថា សេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋានកំពុងដំណើរការក្នុងក្រសួងសាមី (ក្រសួងមហាផ្ទៃ) ហើយយើងក៏សង្ឃឹមផងដែរថា សេចក្តីព្រាងច្បាប់នេះនឹងអាចគ្របដណ្តប់នូវរាល់បញ្ហាប្រឈមនានាកំពុងកើតឡើងនេះបាន។

**ខ. មន្ត្រីអត្រានុកូលដ្ឋាន**

យោងលើរចនាសម្ព័ន្ធនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានក្នុងប្រទេសកម្ពុជា សាលាឃុំ-សង្កាត់ចំនួន ១៦៤៦ បានបំពេញមុខងារជាកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាននៅទូទាំងប្រទេស។ មេឃុំ-ចៅសង្កាត់ដែលត្រូវបោះឆ្នោតដោយប្រជាពលរដ្ឋរៀងរាល់៥ឆ្នាំម្តង មានមុខងារជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិ។ ការិយាល័យអត្រានុកូលដ្ឋានមាននូវថ្នាក់ ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ប៉ុន្តែមានតែសាលាឃុំ សង្កាត់តែមួយគត់ដែលបំពេញមុខងារចុះបញ្ជីអត្រានុកូលដ្ឋាន។ ការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម ស្ថិតិអត្រានុកូលដ្ឋាន និងប្រព័ន្ធព័ត៌មានប្រជាជន ត្រូវការហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដ៏រឹងមាំ ហើយវាពិតជាសំខាន់ខ្លាំងណាស់សម្រាប់គុណភាព និងប្រសិទ្ធិភាពធនធានមនុស្សក្នុងការអនុវត្ត មិនថាតែមន្ត្រីអត្រានុកូលដ្ឋានទេ រួមទាំងអ្នកពាក់ព័ន្ធផ្សេងៗទៀតផងដែរ ចំណុចនេះគឺជាការទាមទារការកសាងសមត្ថភាពដល់មន្ត្រីអត្រានុកូលដ្ឋានទាំងអស់ឱ្យពួកគាត់មានលទ្ធភាពក្នុងការបង្កើត ថែរក្សា និងការតាមដាន។

បញ្ហាចោទជាច្រើនបានកើតឡើងទាក់ទងនឹងសមត្ថភាព និងចំនួនបរិមាណនៃមន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេស។ ដោយយោងទៅតាមសៀវភៅ "ការធ្វើឱ្យប្រសើរឡើងនូវការចុះបញ្ជីអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា" រៀបចំដោយក្រសួងមហាផ្ទៃ ឧបត្ថម្ភដោយអង្គការ UNICEF បានលើកឡើងថា បញ្ហាប្រឈមជាញឹកញយដែលប្រជាពលរដ្ឋជួបប្រទះនោះគឺ អវត្តមានរបស់មន្ត្រីសាលាឃុំ-សង្កាត់។ បញ្ហានេះចោទខ្លាំងចំពោះប្រជាពលរដ្ឋដែលស្ថិតនៅឆ្ងាយពីសង្កាត់ ឬតំបន់ដាច់ស្រយាល ពួកគេត្រូវចំណាយពេលច្រើន ចំណាយថវិកា និងពេលវេលារកស៊ី។ ទាំងនេះក៏ជាបញ្ហាចោទមួយដែលធ្វើឱ្យប្រជាពលរដ្ឋមានភាពអាក់អន់ស្រពន់ចិត្តក្នុងការទៅចុះបញ្ជីអត្រានុកូលដ្ឋាននេះផងដែរ។ ហេតុផលចំនួនពីរដែលត្រូវបានគេលើកឡើងពីបញ្ហាអវត្តមានរបស់មន្ត្រីសាលាឃុំ-សង្កាត់ គឺជម្លោះនៃការអនុវត្តការងារជាន់គ្នា ម៉្យាងវិញទៀត ការជាប់រវល់ក្នុងសកម្មភាពស្វែងរកប្រាក់ចំណូលរបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ឧទាហរណ៍ការធ្វើរបរកសិកម្មនានាដើម្បីបន្ថែមទៅលើ ប្រាក់ខែ

ដែលគាត់ទទួលបានទាប។ កត្តានេះភាគច្រើនចោទខ្លាំងតែនៅទីជនបទ ឬតំបន់ដាច់ស្រយាល ចំណែកនៅទីប្រជុំជនពុំមែនចោទជាបញ្ហាឡើយ។ ម៉្យាងវិញទៀត ចៅសង្កាត់ មេឃុំ ឬក្រុមប្រឹក្សាមួយចំនួន សមត្ថភាពពួកគាត់នៅមានកម្រិត។ បញ្ហាមួយត្រូវបានរកឃើញនៅពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់មិនអាចកត់ត្រាពីមូលហេតុនៃការស្លាប់ដែលបានមកពីមន្ទីរពេទ្យនៅក្នុងការចុះសម្រង់ការចុះបញ្ជីមរណភាពពីព្រោះសេចក្តីសម្រង់នោះគឺត្រូវសរសេរជាភាសាផ្សេង (បារាំង ឬអង់គ្លេស) ឬការសរសេររបស់វិជ្ជបណ្ឌិតគឺពិបាកក្នុងការអាន។ បញ្ហាមួយទៀតដែលមន្ទីអត្រានុកូលដ្ឋានជួបប្រទះនោះ គឺទីលំនៅអចិន្ត្រៃយ៍សម្រាប់ចុះបញ្ជី ដូចនេះអាជ្ញាធរមិនអាចចុះបញ្ជីនូវព្រឹត្តិការណ៍សំខាន់ៗរបស់ជនចំណាកស្រុកដោយសារតែគ្មានទីលំនៅអចិន្ត្រៃយ៍។

បញ្ហាប្រឈមខ្លាំងបំផុតសម្រាប់ថ្ងៃអនាគតចំពោះមន្ត្រីចុះបញ្ជីអត្រានុកូលដ្ឋាននោះគឺសមត្ថភាពនៃការចុះបញ្ជីអត្រានុកូលដ្ឋានតាមបែបបច្ចេកវិទ្យាទំនើបមួយដែលមានលក្ខណៈជាសកល (ភ្ជាប់ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត)។ បញ្ហាចោទពិសេសចំពោះតំបន់ដាច់ស្រយាលមួយចំនួនដែលអ៊ីនធឺណេតពិបាកក្នុងការគ្របដណ្តប់។ លើសពីនេះទៅទៀត បញ្ហាប្រឈមដែលតែងតែកើតឡើងចំពោះការចុះបញ្ជីអត្រានុកូលដ្ឋានក៏ត្រូវបានសរសេរក្នុងរបាយការណ៍របស់នាយកដ្ឋានអត្រានុកូលដ្ឋាន យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងាររបស់នាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មសម្រាប់ឆ្នាំ២០២០នេះ បានលើកឡើងពីបញ្ហាប្រឈមថា មន្ត្រីបម្រើការងារនៅនាយកដ្ឋានអត្រានុកូលដ្ឋានមានចំនួនតិចនៅឡើយ ដែលនាំឱ្យកិច្ចការមួយចំនួនមានការយឺតយ៉ាវ ព្រមជាមួយគ្នានេះដែរមន្ត្រីអនុវត្តការងារអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួនមានការផ្លាស់ប្តូរញឹកញាប់ ជាហេតុនាំឱ្យមានកំហុសឆ្គងពេលចុះបញ្ជីជូនប្រជាពលរដ្ឋមិនបានពេញលេញ។

**គ. កត្តាប្រជាពលរដ្ឋ**

នៅមុនឆ្នាំ១៩៩៣ កម្ពុជាធ្លាប់ជាប្រទេសមួយដែលមានប្រព័ន្ធគ្រប់គ្រងប្រជាជនប្រកបដោយប្រសិទ្ធិភាពដែលអាចឱ្យអាជ្ញាធរដឹងបានអំពីទីកន្លែងរស់នៅ ការផ្លាស់ប្តូរទីលំនៅ ការស្នាក់នៅបណ្តោះអាសន្ន និងបញ្ហាបម្រែបម្រួលផ្សេងៗទៀតរបស់ប្រជាជន។ ប្រព័ន្ធគ្រប់គ្រងបែបប្រជាធិបតេយ្យមួយត្រូវបានដាក់ឱ្យអនុវត្តនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣មក កម្ពុជាទទួលបានសច្ចាប័នទទួលស្គាល់ និងអនុវត្តតាមសន្ធិសញ្ញា កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិជាច្រើនដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាស្តីពីសិទ្ធិកុមារ កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ល។ ការវិវត្តសង្គម និងនយោបាយខាងលើនេះបានបង្កឱ្យមានភាពស្រពិចស្រពិល និងការយល់ច្រលំពីសំណាក់ប្រជាពលរដ្ឋថា កម្ពុជាជាប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យសេរី ដែលប្រជាជនមានសិទ្ធិធ្វើអ្វីទាំងអស់ដោយមិនចាំបាច់សុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ ការយល់ច្រលំនេះ ក៏ក្លាយជាសម្ពាធនយោបាយដ៏ធ្ងន់ធ្ងរ និងបានធ្វើឱ្យកម្ពុជាជួបការលំបាកយ៉ាងខ្លាំងក្នុងការរៀបចំគ្រប់គ្រងប្រជាជនឱ្យបានច្បាស់លាស់។

បញ្ហាប្រឈមផ្សេងទៀតគឺពាក់ព័ន្ធទៅនឹងការយល់ដឹងតិចតួចនៅក្នុងសង្គមទាំងមូលអំពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ការយល់ដឹងអំពីគុណតម្លៃនៃប្រកាស និងមានចេតនាប្រកាសពីព្រឹត្តិការណ៍ជីវិតឱ្យដល់អាជ្ញាធរមានសមត្ថកិច្ចថាវាមានសារៈសំខាន់ខ្លាំងប៉ុណ្ណាសម្រាប់ខ្លួន និងសមាជិកក្នុងគ្រួសារខ្លួន ក៏ដូចជារួមចំណែកមួយផ្នែកក្នុងការរីកចម្រើននៃសង្គមជាតិផងដែរ។ បញ្ហាចោទខ្លាំងបំផុតគឺការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព ស្ថិតក្នុងកម្រិតទាប និងការពុំបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ពីការស្លាប់ថែមទៀត។ បើធៀបទៅនឹងការយល់ដឹងពីការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា រៀបរៀងដោយក្រសួងមហាផ្ទៃ បានលើកឡើងពីការចុះសម្ភាសន៍គ្រួសារចំនួន៣៧ មានគ្រួសារចំនួន២៣ ស្មើនឹង៦២% បានលើកឡើងថាពួកគាត់រវល់ខ្លាំងពេកទើបមិនអាចទៅសាលាឃុំ សង្កាត់បាន។ កត្តានេះបានបង្ហាញថា នេះជាផ្នត់គំនិតមួយដែលពុំបានផ្តល់តម្លៃ (យល់ដឹងតិចតួច) ពីបញ្ហាប្រឈមពេលពួកគាត់ពុំបានធ្វើសំបុត្រអត្រានុកូលដ្ឋានទាំងនោះ។ ម៉្យាងវិញទៀតបញ្ហានឹងអាចចោទឡើងម្តងទៀតនៅពេលដែលពួកគាត់ត្រូវការសំបុត្រទាំងនោះ ហើយវាត្រូវហួសសុពលភាពនៃការចុះសំបុត្រមរណភាពឆ្លងឆ្នាំដែលតម្រូវឱ្យសាលក្រមពីតុលាការ ដែលធ្វើឱ្យពួកគេខាតបង់ទាំងពេលវេលា និងថវិកា។ សៀវភៅខាងលើនេះក៏បានបញ្ជាក់ទៀតថាគ្រួសារខ្លះក៏បានលើកឡើងពីបញ្ហាថវិកាខាងក្រៅប្រព័ន្ធខ្លះដែលពួកគេចាត់ទុកថាជាថ្លៃទឹកប៊ិកមន្ត្រីអត្រានុកូលដ្ឋាន ឬជាថ្លៃទឹកចិត្តពួកគាត់ដែលចង់តបស្នងចំពោះមន្ត្រីដែលបានជួយគាត់។ ថ្លៃកម្រៃទាំងនេះក៏បានចោទជាបញ្ហាខ្ពស់សម្រាប់ប្រជាជនក្រីក្រដែលរកព្រឹកខ្វះល្ងាច ឬល្ងាចខ្វះព្រឹក គួបផ្សំនឹងការយល់ដឹងនៅមានកម្រិត ជាហេតុកាន់តែធ្វើឱ្យពួកគេមិនចំណាយពេលតិចតួច របស់ពួកគេទៅសាលាឃុំ សង្កាត់នោះឡើយ។

បញ្ហាមួយទៀតក៏បានលើកឡើងពីការចុះបញ្ជីអត្រានុកូលដ្ឋាននៃភាពជាដៃគូ (អាពាហ៍ពិពាហ៍) គឺមិនមែនជាកាតព្វកិច្ច និងមិនភ្ជាប់ទៅនឹងការកំណត់ពេលវេលានោះទេ ដូច្នេះគូរស្វាមីភរិយាជាច្រើនមិនមានអារម្មណ៍ជំរុញឱ្យមានការបញ្ជាក់ពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់របស់ពួកគេនោះទេ។ គូរស្វាមីជាច្រើនមានអារម្មណ៍ថា វាមានភាពលំបាកខ្លាំងក្នុងការលែងលះ បន្ទាប់ពីអាពាហ៍ពិពាហ៍ត្រូវបានបញ្ជាក់ក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

### ឃ. ធនធានហិរញ្ញវត្ថុ

ការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម ស្ថិតិអត្រានុកូលដ្ឋាន និងប្រព័ន្ធព័ត៌មានប្រជាជនត្រូវការហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានរឹងមាំ។ ហើយវាពិតជាសំខាន់ណាស់ក្នុងការផ្តល់នូវហិរញ្ញប្បទានដែលធានាឱ្យប្រព័ន្ធដំណើរការជាប្រចាំ និងអចិន្ត្រៃយ៍ក្នុងការចុះបញ្ជី។ ម៉្យាងវិញទៀត វាក៏មានសារៈសំខាន់ផងដែរចំពោះការជំរុញឱ្យមានការកែលម្អជាបន្តបន្ទាប់ដល់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅក្នុងវិស័យធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងការផ្គត់ផ្គង់ជាដើម។ ធនធានមនុស្ស ធនធានបច្ចេកវិទ្យា និង

ធនធានផ្សេងៗទៀតត្រូវតែមានសម្រាប់ធ្វើឱ្យការចុះបញ្ជីមានប្រសិទ្ធិភាព។ ការកសាងសមត្ថភាពត្រូវតែគិតគូររៀបចំឡើងនៅគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលត្រូវចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។ ការកសាងសមត្ថភាពដល់មន្ត្រី គឺពិតជាសំខាន់ផងដែរដើម្បីឱ្យពួកគាត់មានលទ្ធភាពក្នុងការបង្កើត ការថែរក្សា និងការតាមដានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននេះ។ ដូចបានរៀបរាប់ខាងលើ ដំណើរការនេះត្រូវការជាចាំបាច់នូវធនធានហិរញ្ញវត្ថុជាច្រើនលើសលប់ ដើម្បីគាំទ្រ និងផ្គត់ផ្គង់។ ដោយយោងទៅតាមសៀវភៅផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦ បានប៉ាន់ស្មានថវិកាគ្រោងចំណាយទៅលើវិស័យនេះសរុបចំនួន ៤៧,៦៤៦,០០០ ដុល្លាអាមេរិចដើម្បីឱ្យកម្ពុជាឆ្ពោះទៅរកប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធអត្តសញ្ញាណកម្មទំនើបមួយដែលមានលក្ខណៈជាសកល។

គ្មានអ្វីដែលនៅឋិតថេរនោះទេ ដូច្នេះសេដ្ឋកិច្ចប្រទេសកម្ពុជា និងធ្វើដំណើរឆ្ពោះទៅមុខឱ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងពេលឆាប់ៗនេះ តាមរយៈការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា។ ហើយនៅពេលកម្ពុជានឹងមិនទទួលបានជំនួយឥតសំណងទៀតនោះទេ ពោលគឺត្រូវពឹងផ្អែកខ្លាំងទៅលើ ប្រាក់កម្ចី (កម្ចីសម្បទាន ឬកម្ចីផ្សេងៗទៀត) ហេតុនេះ កម្ពុជាត្រូវខិតខំបង្កើនធនធានរបស់ខ្លួនឱ្យកាន់តែច្រើនថែមទៀតនៅកម្រិតទីផ្សារទាំងប្រភពក្នុងស្រុក និងប្រភពក្រៅស្រុក ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគលើវិស័យនេះក៏ដូចផែនការវិស័យសាធារណៈទាំងមូល។ ទាំងនេះជាបញ្ហាប្រឈមមួយដ៏ធំដែលគេសម្លឹងឃើញនៅថ្ងៃអនាគត ប៉ុន្តែបើយើងងាកមកមើលបញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ននេះវិញ គឺស្របទៅតាមជំពូកទី១២ នៃអនុក្រឹត្យលេខ១០៣ ចែងថា ថវិកាប្រចាំឆ្នាំសម្រាប់ធ្វើការបោះពុម្ពសំបុត្រ សៀវភៅអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលត្រូវទទួលបានការវិភាជន៍ថ្នាក់ជាតិ ប៉ុន្តែមិនមានថវិកាវិភាជន៍សម្រាប់ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋានជាទៀងទាត់ទេ។ សូម្បីតែថវិកាថ្នាក់ជាតិជាញឹកញយក៏ត្រូវបានបង្វើបពីមន្ត្រីថ្នាក់ជាតិបានលើកឡើងថា ពួកគាត់បានស្នើសុំកញ្ចប់ថវិកាក្នុងដំណើរការផ្សេងៗលើវិស័យនេះ ដូចជាដំណើរការលើសេចក្តីព្រាងច្បាប់ស្តីអត្រានុកូលដ្ឋាន ការបណ្តុះបណ្តាលបុគ្គលិកជាញឹកញយមិនត្រូវបានអើពើពីថ្នាក់លើនោះទេ។

**ង. ស្ថាប័នពាក់ព័ន្ធ**

ដោយសារតែមានស្ថាប័ន និងតួអង្គជាច្រើនជាប់ពាក់ព័ន្ធ ហើយក៏ជាអ្នកទទួលបានផលប្រយោជន៍ពីប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នោះការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាព គឺជាលក្ខខណ្ឌក៏សំខាន់មួយដើម្បីធានាបាននូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មមានលក្ខណៈសកល និងមានការឆ្លើយតប។ ការសម្របសម្រួល គឺត្រូវធ្វើឡើងក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ដែលទទួលខុសត្រូវលើការងារគ្រប់កម្រិតរដ្ឋបាល ក៏ដូចជារវាងរាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ផងដែរ។

ការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាពចាំបាច់ ត្រូវធ្វើឡើងក្នុងចំណោមរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត និងភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ ដែលត្រូវចូលរួមធ្វើរបាយការណ៍ ការធ្វើ

កំណត់ត្រា និងការចុះបញ្ជីនៅពេលកើតឡើងនូវព្រឹត្តិការណ៍ជីវិតនានា។ ការចូលរួមបន្ទាប់ពីភាគីពាក់ព័ន្ធនៅគ្រប់កម្រិតរដ្ឋបាល គឺអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន រួមទាំងដៃគូអភិវឌ្ឍន៍ដែលបានចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម ២០១៧-២០២៦។

ជាក់ស្តែងតាមរបាយការណ៍របស់នាយកដ្ឋានអត្រានុកូលដ្ឋាន ក្នុងកំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ (២០១៨-២០១៩-២០២០) បានលើកឡើងពីភាពយឺតយ៉ាវនៃការប្រមូលសៀវភៅអត្រានុកូលដ្ឋានជូនថ្នាក់ជាតិឱ្យទាន់ពេលវេលាក្នុងការប្រើប្រាស់ទិន្នន័យ ម៉្យាងវិញទៀតមន្ត្រីអនុវត្តការងារអត្រានុកូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមមានការផ្លាស់ប្តូរជាញឹកញាប់ ជាហេតុធ្វើឱ្យមានកំហុសឆ្គងនៅពេលចុះបញ្ជីជូនប្រជាពលរដ្ឋ របាយការណ៍ទាំងនោះក៏បានបញ្ជាក់ពីការខ្វះខាតនានាដូចជាថវិកាក្នុងការថែទាំជួសជុលសម្ភារៈបរិក្ខា និងបច្ចេកទេសផ្សេងៗរួមជាមួយនឹងកង្វះខាតបុគ្គលិកធ្វើការ តែតាមការមើលឃើញ បញ្ហាប្រឈមនេះតែងតែលើកឡើងជារៀងរាល់ឆ្នាំនេះបញ្ជាក់ពីការមិនអើពើ ឬការចូលរួមពីស្ថាប័នពាក់ព័ន្ធ។ ម៉្យាងវិញទៀត ដោយអនុក្រឹត្យលេខ១០៣ ក៏ពុំបានចែងឱ្យច្បាស់ពីតួនាទី និងភារកិច្ចរបស់ស្ថាប័នដែលពាក់ព័ន្ធផង ជាហេតុធ្វើឱ្យស្ថាប័នទាំងនោះហាក់អនុវត្តការងារទាក់ទងនឹងវិស័យនេះ ដូចមិនសកម្មទាល់តែសោះ ដូចស្ថាប័នសុខាភិបាលទាំងមន្ទីរពេទ្យឯកជន និងរដ្ឋពុំបានចូលរួមបង្ហាញពីព្រឹត្តិការណ៍ជីវិតរបស់ប្រជពលរដ្ឋទាក់ទងទៅនឹងកំណើត និងមរណភាព ដែលជាពិសេសបញ្ហានៃការស្លាប់របស់ប្រជាពលរដ្ឋដោយគ្មានភាពច្បាស់លាស់ ឯខ្លះទៀតគ្មានមូលហេតុបញ្ជាក់វេជ្ជ-សាស្ត្រនោះទេ។

យោងទៅលើសៀវភៅ ការវាយតម្លៃលើគុណភាព និងការប្រើប្រាស់ព័ត៌មាន កំណើត អាពាហ៍ពិពាហ៍ និងមូលហេតុនៃការស្លាប់បានលើកឡើងពីការប៉ាន់ប្រមាណរបស់ក្រសួងមហាផ្ទៃថាភាពពេញលេញនៃការចុះបញ្ជីមរណភាពតិចជាង១០% ដែលមានទិន្នន័យអាចជឿទុកចិត្តបាននូវភាពពេញលេញនៃការបញ្ជាក់មូលហេតុនៃការស្លាប់។ ចំពោះក្រសួងផែនការវិញ អនុក្រឹត្យនេះក៏ពុំបានចែងពីតួនាទី និងការទទួលខុសត្រូវចំពោះការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែរ។ ចំពោះអង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាដៃគូរសហការឧបត្ថម្ភផ្សេងៗ គឺដូចទៅនឹងបញ្ហាប្រឈមទាក់ទងនឹងធនធានហិរញ្ញវត្ថុដែរ បញ្ហាត្រង់ថាកម្ពុជានឹងទទួលបានប្រាក់កម្ចីជាជាងប្រាក់ជំនួយ។

### ច. ទិន្នន័យនិងប្រព័ន្ធទិន្នន័យ

ការចុះបញ្ជីអត្រានុកូលដ្ឋានធ្វើឡើងតែនៅលើក្រដាសតែប៉ុណ្ណោះទេ។ វាពិតជាប្រឈមនឹងហានិភ័យជាច្រើនដូចជា គ្រោះធម្មជាតិនានាតួយ៉ាង ព្យុះ អគ្គីភ័យ ឬហានិភ័យដែលនាំឱ្យបាត់បង់ទិន្នន័យដោយថាហេតុផ្សេងៗ។ ហានិភ័យទាំងនោះអាចកើតមានចំពោះការបញ្ចូលទិន្នន័យ ការចុះបញ្ជីដែលមានភាពភ័ន្តច្រលំ កោស ឬលុបដែលអាចឱ្យប៉ះពាល់ទិន្នន័យដើម (សមត្ថភាពមន្ត្រីអត្រានុកូលដ្ឋាន) ការបញ្ជូនសៀវភៅ និងការរក្សាទុកទិន្នន័យ។

នៅក្នុងឆ្នាំ២០០៩ ធនាគារអភិវឌ្ឍអាស៊ី (ADB) និងទីភ្នាក់ងារអភិវឌ្ឍប្រទេសស៊ុយ អ៊ែត (SIDA) បានគាំទ្រគម្រោងមួយសម្រាប់វាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើតទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់សំបុត្រអត្រានុកូលដ្ឋានទាំងអស់ដែលបានអនុវត្តនៅក្នុងអំឡុងឆ្នាំ២០០២ ដល់ ២០០៦។ សំបុត្រទាំងនេះត្រូវបានស្កេន ដោយតម្កល់ទុកជាមួយនឹងទិន្នន័យទាំងអស់ក្នុងប្រព័ន្ធទិន្នន័យអត្រានុកូលដ្ឋានថ្មី។ ការវាយបញ្ចូលសំបុត្រកំណើតកន្លងមកត្រូវបានកំណត់ជាអាទិភាពក្នុងប្រព័ន្ធនេះ តែប៉ុន្តែនាពេលបច្ចុប្បន្នចាប់តាំងពីជំនួយត្រូវបានផ្អាក មជ្ឈមណ្ឌលទិន្នន័យអត្រានុកូលដ្ឋានបានដំណើរការតិចតួចបំផុត។ តាមការស្រាវជ្រាវនៅនាយកដ្ឋានអត្រានុកូលដ្ឋានបានដំណើរការតិចតួចបំផុត។ តាមការស្រាវជ្រាវនៅនាយកដ្ឋានអត្រានុកូលដ្ឋានតាមការលើកឡើងរបស់មន្ត្រីថ្នាក់ជាតិដែលបានអនុវត្តជាក់ស្តែងបានលើកឡើងថា ទិន្នន័យដែលបានរក្សាទុកក្នុងប្រព័ន្ធបច្ចេកវិទ្យានេះ ដំណើរការទៅលើតែអត្រានុកូលដ្ឋាន កំណើតប៉ុណ្ណោះ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងមរណភាពពុំទាន់មាននៅឡើយ។

ចំពោះប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធអត្តសញ្ញាណកម្មទំនើបមួយដែលមានលក្ខណៈជាសកលឱ្យស្របទៅនឹងផែនការជាតិស្តីពីអត្តសញ្ញាណកម្ម អាចប្រឈមទៅនឹងបញ្ហាផងដែរ។ តាមការមើលឃើញ ក្នុងផែនការនេះបានលើកឡើងនៅក្នុងគោលបំណងទី៣ ស្តីពីបង្កើតប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន ដោយលើកឡើងពីការបង្កើតឱ្យមានលេខកូដអត្តសញ្ញាណតែមួយគត់ដែលបានប្រគល់ទៅឱ្យបុគ្គលនៅពេលចុះបញ្ជីកំណើត ហើយត្រូវប្រើប្រាស់ពេញមួយជីវិត។ ប៉ុន្តែជាតុពិយើងឃើញថា គោលបំណងទី៣នេះពុំទាន់ត្រូវបានអនុវត្តន៍នៅឡើយទេ ក្នុងឆ្នាំ២០២០នេះ។ បច្ចុប្បន្នសូម្បីតែគោលបំណងយុទ្ធសាស្ត្រទី១ ស្តីពីការរៀបចំក្របខណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានឱ្យសភាជាតិអនុម័តឱ្យបានត្រឹមឆ្នាំ២០១៨ ក៏ពុំទាន់បានបញ្ចប់នៅឡើយ។ ស្របពេលប្រទេសត្រូវរឹកររដោយសារជម្ងឺកូវីដ-១៩ថែមទៀត។

**ឆ. កម្ពុជាឈានជើងចូលក្នុងក្របខណ្ឌអន្តរជាតិ**

ក្នុងក្របខណ្ឌតំបន់ និងពិភពលោក កិច្ចការអត្តសញ្ញាណកម្មនៃប្រទេសនីមួយៗបានក្លាយទៅជាកិច្ចការជាសកលដែលតម្រូវឱ្យប្រទេសទាំងអស់ត្រូវធានាកំណត់ឱ្យបាននូវអត្តសញ្ញាណរបស់ប្រជាជនខ្លួនដើម្បីឈានទៅធ្វើទំនាក់ទំនងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាដើមជាមួយនឹងប្រទេសនានា។

សន្និសិទ្ធិអន្តរជាតិស្តីពីការគ្រប់គ្រងអត្តសញ្ញាណកម្មដែលបានធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០១៤នៅទីក្រុងសេអ៊ូល បានក្រើនរំលឹកដល់រាជរដ្ឋាភិបាលនៃប្រទេសនីមួយៗឱ្យបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននៅក្នុងការអភិវឌ្ឍន៍ និងអនុវត្តនូវវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយសម្រាប់ការបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណដ៏រឹងមាំមួយ ដោយចាប់ផ្តើមពីការប៉ាន់ប្រមាណឱ្យបានស៊ីជម្រៅ និងដាក់ចេញនូវផែនការសកម្មភាពថ្នាក់ជាតិដើម្បីអនុវត្ត និងការកំណត់ធនធានឱ្យបានច្បាស់លាស់ក្នុងគោលបំណងពន្លឿនការកែលម្អប្រព័ន្ធចុះបញ្ជី

អត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ព្រមទាំងប្រព័ន្ធអត្តសញ្ញាណកម្ម និងការសម្របសម្រួលភាគីពាក់ព័ន្ធនានា ដើម្បីធានាការចុះបញ្ជីព្រឹត្តិការណ៍ជីវិតសំខាន់ៗឱ្យមានប្រសិទ្ធិភាពដែលធ្វើឱ្យមានតម្រូវការអន្តរ-ប្រតិបត្តិការរវាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធអត្តសញ្ញាណកម្មស៊ីវិល និងប្រព័ន្ធផ្សេងៗទៀត ដើម្បីពង្រឹងការផ្តល់សេវាធានាបានទិន្នន័យទាន់ពេលវេលាត្រឹមត្រូវ និងអាចជឿទុកចិត្តបានសម្រាប់ប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

នៅដំណាច់ឆ្នាំ២០១៥ ព្រះរាជាណាចក្រកម្ពុជាបានធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលនៅក្នុងនោះរបាំងជាច្រើនរបស់ប្រទេសនានានៅក្នុងតំបន់ត្រូវទម្លាក់ចោល។ ហេតុដូច្នេះ កម្ពុជាត្រូវត្រៀមខ្លួនឱ្យបានរួចជាស្រេចសម្រាប់ធ្វើយ៉ាងណាឱ្យប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធអត្តសញ្ញាណកម្មមានប្រសិទ្ធិភាព និងប្រសិទ្ធិផល ព្រោះវាជាសមាសធាតុក៏ខ្លាំងមួយសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បើសិនកម្ពុជាពុំបានកំណត់អត្តសញ្ញាណប្រជាជនឱ្យបានជាក់លាក់ទេ នោះកម្ពុជានឹងពិបាកក្នុងការការពារផលប្រយោជន៍ខាងផ្លូវច្បាប់ និងផ្លូវសេដ្ឋកិច្ចដល់ប្រជាជនខ្លួន ដើម្បីធានាឱ្យកម្ពុជាអាចទទួលបានផលប្រយោជន៍ពីសមាហរណកម្មនេះ។

### ៣.២.២. ដំណោះស្រាយ

#### ក. ដំណោះស្រាយកន្លងមក

កន្លងមករាជរដ្ឋាភិបាលប្រទេសកម្ពុជាក៏បានយកចិត្តទុកដាក់ខ្ពស់ទៅលើការងារអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មនេះផងដែរ ដោយមានក្រសួងមហាផ្ទៃ ត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើលដំណើរការជាទូទៅ ពិនិត្យលើការអនុវត្ត និងតាមដានការរីកចម្រើននានាដើម្បីឆ្ពោះទៅរកគោលបំណង និងគោលដៅនានាដែលបានគ្រោងទុកដោយការរួមសហការជាមួយស្ថាប័នពាក់ព័ន្ធនានា។

តាមរយៈការសិក្សាទៅលើសាវតានៃប្រព័ន្ធ និងការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧៩មក កម្ពុជាត្រូវងើបពីភក់ជ្រាំនៃសង្គ្រាមប្រល័យពូជសាសន៍ដ៏ឃោរឃៅ មានន័យថាកម្ពុជាត្រូវងើបពីបាតដៃទទេ។ រហូតមកដល់ឆ្នាំ១៩៩៣ ក្រោមជំនួយពីអ៊ុនតាក់ កម្ពុជាបានបោះឆ្នោតជាសកលដើម្បីបង្កើតរាជរដ្ឋាភិបាលផ្ទាល់ខ្លួន។ ចាប់តាំងពីពេលនោះមករដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីស្តារប្រទេសមួយនេះឡើងវិញក្រោមជំនួយ និងកម្ចីនានា។ ដោយមានកិច្ចខិតខំប្រឹងប្រែងនេះហើយ ទើបវិស័យអត្រានុកូលដ្ឋាន ក៏ត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ដូចគ្នា ដោយបានដាក់ចេញនូវអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ហើយត្រូវបានអនុវត្តខែសីហា ឆ្នាំ២០០២។ រាជរដ្ឋាភិបាលក៏ដូចជាក្រសួងមហាផ្ទៃ បានខិតខំប្រឹងប្រែងកែលម្អវិស័យនេះឱ្យកាន់តែមានភាពប្រសើរឡើងពីមួយកម្រិតទៅមួយកម្រិត ដូចជាការដាក់ចេញនូវយុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត មានន័យថាមន្ត្រីអត្រានុកូលដ្ឋានត្រូវទៅចុះបញ្ជីឱ្យប្រជាពលរដ្ឋ

របស់ខ្លួនដល់មុខផ្ទះតែម្តង ការបណ្តុះបណ្តាលដល់រាល់មន្ត្រីអត្រានុកូលដ្ឋានទាំងអស់ទូទាំងប្រទេស រៀបចំសិក្ខាសាលានានា ដូចជាសិក្ខាសាលាស្តីពីការវាយតម្លៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅកម្ពុជា សិក្ខាកាមចំនួន៧៤នាក់ មកពីក្រសួងពាក់ព័ន្ធ ដូចជាក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ ថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក និង ឃុំ សង្កាត់ ប្រព្រឹត្តទៅក្នុងខេត្តព្រះសីហនុ។ ដើម្បីឆ្លើយតបទៅនឹងផលវិបាកនានា ក៏ដូចជាការរីកចម្រើននៃសង្គមមនុស្ស និងបច្ចេកវិទ្យា ក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធបានចេញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើន រួមជាមួយនឹងការកែសម្រួលអនុក្រឹត្យលេខ១០៣ ជាច្រើនលើកច្រើនសារ។ លិខិតបទដ្ឋានគតិយុត្តនោះជាអាទិ៍ មានដូចជា អនុក្រឹត្យលេខ៦០ អនក្របក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា២៩ នៃអនុក្រឹត្យលេខ១០៣ ប្រកាសលេខ១០៨៦ ប្រ.កចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្តូរឈ្មោះការិយាល័យកិច្ចការទូទៅ ជាការិយាល័យស្ថិតិទូទៅ និងអត្រានុកូលដ្ឋានចំណុះ សាលាខេត្ត ក្រុង សេចក្តីណែនាំលេខ០០១ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ប្រកាសលេខ៥៦៧១ ប្រ.ក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបញ្ចប់ការទទួលពាក្យស្នើសុំជាជនបរទេស អន្តោប្រវេសន៍ និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សេចក្តីណែនាំលេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបន្តដំណើរការកែសម្រួល និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន។ល។ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតផងដែរ។ បច្ចុប្បន្ននេះសេចក្តីព្រាងច្បាប់ស្តីពីការងារអត្រានុកូលដ្ឋានស្ថិតនៅក្នុងការពិភាក្សានៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃនៅឡើយ។ សេចក្តីព្រាងច្បាប់នេះនឹងមកបំពេញនូវចន្លោះខ្វះខាតនានានៃអុក្រឹត្យលេខ១០៣។ ក្នុងនោះផងដែរ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវយុត្តិសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម ២០១៧-២០២៦ ដែលជាមគ្គុទេសក្នុងការពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីបង្កើតអត្រាចុះបញ្ជីអត្រានុកូលដ្ឋាន និងលើកកម្ពស់ការងារអត្តសញ្ញាណកម្ម។

មិនត្រឹមតែការខិតខំប្រឹងប្រែងចំពោះតែលិខិតបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងនោះទេ រាជរដ្ឋាភិបាលក៏ដូចជាក្រសួងមហាផ្ទៃក៏បានខិតខំពង្រឹងសមត្ថភាពមន្ត្រីរបស់ខ្លួនតាមរយៈការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស និងការផ្គត់ផ្គង់ទាំងឧបករណ៍ និងបច្ចេកទេសនានាដល់ការងារអត្រានុកូលដ្ឋាន។ បើទោះបីជាមានការលើកឡើងពីការខ្វះខាតមួយចំនួនក៏ដោយ និងការបង្កើតនូវអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដែលមានទីតាំងដាច់ដោយឡែកពីក្រសួងមហាផ្ទៃថែមទៀត។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅកម្ពុជាត្រូវបានអនុវត្តសម្រេចដោយជោគជ័យក្នុងទិដ្ឋភាពជាច្រើន ដោយសារការប្តេជ្ញាចិត្តពីក្រសួងមហាផ្ទៃ និងការគាំទ្រដៃគូរអភិវឌ្ឍដូចជា អង្គការ UNICEF, ADB, PLAN, UNHCR, UNFPA, USAID, JICA, URC, WHO និងដៃគូរអភិវឌ្ឍផ្សេងទៀត។

**ខ. ផែនការយុទ្ធសាស្ត្រ**

ដោយយោងទៅតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦ បានឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រ និងសកម្មភាពនានារបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធនានាក្នុងគោលបំណងធ្វើឱ្យប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធអត្តសញ្ញាណកម្មទំនើបមានលក្ខណៈជាសកលតាមស្តង់ដាអន្តរជាតិដោយភ្ជាប់ជាមួយទិន្នន័យត្រឹមត្រូវច្បាស់លាស់ ទាន់ពេលវេលា និងអាចចែករំលែកបានជាពិសេសអាចឆ្លើយតបបានទៅនឹងបញ្ហាប្រឈមដែលលើកឡើង។ ផែនការយុទ្ធសាស្ត្រទាំងនោះមានដូចជា៖

**ខ.១. រៀបចំក្របខណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណ**

ក្របខណ្ឌច្បាប់គឺជាមូលដ្ឋានសម្រាប់ចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន រាជរដ្ឋាភិបាលត្រូវតែនាំយកក្របខណ្ឌច្បាប់ដែលមានលក្ខណៈទាន់សម័យ និងអាចឆ្លើយតបបានពេញលេញទៅតាមតម្រូវការ និងការចង់បានរបស់ខ្លួន ព្រមទាំងស្របទៅនឹងប្រព័ន្ធផ្សេងៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងច្បាប់អន្តរជាតិនានា។ នេះមិនមែនមានន័យថាកិច្ចខិតខំប្រឹងប្រែងពីមុនមកត្រូវចាត់ទុកជាមោឃៈទេ វាគ្រាន់តែជាការកំណែទម្រង់ឱ្យកាន់តែល្អ និងឆ្លើយតបនឹងចន្លោះខ្វះខាតប៉ុណ្ណោះ។ ក្របខណ្ឌច្បាប់គួរតែរៀបចំតាមជំហាននានាដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន
- រៀបចំសកម្មភាពផ្សព្វផ្សាយនូវមូលដ្ឋាន

**ខ.២. បង្កើតប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន**

ការបង្កើតប្រព័ន្ធអត្តសញ្ញាណកម្មប្រជាជន ក្នុងគោលបំណងដោះស្រាយនូវតម្រូវការបង្កើតព័ត៌មានប្រជាជន និងអត្តសញ្ញាណពិសេសដែលជឿទុកចិត្តបានរបស់មនុស្សទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា។ ប្រព័ន្ធកំណត់អត្តសញ្ញាណប្រជាជនមានលក្ខណៈរួម ត្រូវបង្កើតឡើងដើម្បីបម្រើជាកន្លែងប្រមូលផ្តុំព័ត៌មានប្រជាជនសម្រាប់ស្ថាប័នផ្សេងៗ និងសម្រាប់ប្រព័ន្ធរបស់ស្ថាប័ននោះប្រើប្រាស់ជាប្រភពទិន្នន័យចម្បងតែមួយគត់។ បណ្តុំទិន្នន័យជាអប្បបរមានៃព័ត៌មានបុគ្គល (ហៅថាបញ្ជីប្រជាជន) ត្រូវបានកំណត់ និងស្តុកទុកនៅក្នុងទីតាំងកណ្តាលមួយ និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំពីស្ថានភាពបុគ្គល និងប្រព័ន្ធដទៃទៀត។ ផែនការយុទ្ធសាស្ត្រនេះត្រូវចែកជាសកម្មភាពមួយចំនួនដូចជា ៖

- បង្កើតហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលមានលទ្ធភាពខ្ពស់សម្រាប់បម្រើឱ្យប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនតាមស្តង់ដាសុវត្ថិភាព និងមាននិរន្តភាព
- បង្កើនសមត្ថភាពមន្ត្រីទាក់ទងនឹងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- កសាងទំនុកចិត្ត និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់លេខកូដអត្តសញ្ញាណខ្មែរដល់ប្រជាពលរដ្ឋ និងទម្រង់គំរូថ្មី

- រចនាទម្រង់អភិវឌ្ឍន៍បញ្ជីប្រជាជន
- ធានាសុវត្ថិភាព និងការប្រើប្រាស់ទិន្នន័យស្តីពីការប្រកាសការស្នាក់នៅ និងគ្រប់គ្រងព័ត៌មានសញ្ជាតិ អត្តសញ្ញាណប័ណ្ណ
- ធានាគុណភាពទិន្នន័យឌីជីថល និងភាពគ្មានស្ទួននៃអត្តសញ្ញាណបុគ្គលនៅក្នុងប្រព័ន្ធ និងប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន។

### ខ.៣. ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យប្រជាជន

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យប្រជាជនក្នុងគោលបំណងដើម្បីដោះស្រាយអំពីតម្រូវការភាគីពាក់ព័ន្ធក្នុងការទទួលបានទិន្នន័យប្រជាជនដែលគួរឱ្យទុកចិត្តបំផុតនៃព្រះរាជាណាចក្រកម្ពុជា និងមានចេតនាបង្កើតនូវប្រព័ន្ធមួយទៀតដែលមានមុខងារបញ្ចេញព័ត៌មានដ៏មានប្រសិទ្ធិភាពដែលព័ត៌មានទាំងនោះបានប្រមូលផ្តុំមកពីគ្រប់ប្រព័ន្ធរងផ្សេងៗទៀតរបស់ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជននៅក្នុងមណ្ឌលបែងចែកព័ត៌មានកណ្តាល។ រាល់ទិន្នន័យប្រជាជន ជាទិន្នន័យដែលចម្លងចេញពីបញ្ជីប្រជាជននៃព្រះរាជាណាចក្រកម្ពុជា និងធ្វើឱ្យទិន្នន័យទាំងនោះអាចស្វែងរកយ៉ាងឆាប់រហ័ស។ ប្រព័ន្ធនេះនឹងជួយដល់ការគ្រប់គ្រងអ្នកប្រើប្រាស់ ព្រមទាំងមានមុខងារខ្ពស់អាចតាមដាន និងធ្វើសវនកម្មទៅលើដំណើរការស្វែងរកព័ត៌មានគ្រប់ពេលវេលា។ វាក៏អាចជួយពង្រឹងសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ដែលមានការអនុញ្ញាត ក៏ដូចជាការធានាសុវត្ថិភាព ការសម្ងាត់នៃទិន្នន័យ។ ដើម្បីឱ្យការប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធិភាព និងធានាសុវត្ថិភាពទិន្នន័យសម្ងាត់ទាំងនេះបានគេត្រូវបង្កើតកិច្ចសន្យាសម្រាប់ភាគីអ្នកផ្តល់ និងភាគីទទួលទិន្នន័យ ចៀសវាងការបញ្ចេញព័ត៌មានណាមួយដោយគ្មានការអនុញ្ញាត ឬអាចបង្កជាបញ្ហាណាមួយម៉្យាងវិញទៀត គេក៏ត្រូវអប់រំរដ្ឋបាលសាធារណៈអំពីការប្រើប្រាស់ស្ថិតិប្រជាជនដែលផ្តល់ឱ្យពួកគេនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ស្ថាប័នខ្លួនក្នុងការរៀបចំផែនការកម្មវិធីយុទ្ធសាស្ត្រ និងសកម្មភាពនានា។

### ខ.៤. ការកែសម្រួលរបៀបរបបការងារ

ការកែសម្រួលរបៀបរបបការងារក្នុងគោលបំណងផ្តោតទៅលើការដោះស្រាយតម្រូវការនៃការកែលំអការផ្តល់សេវាតាមរយៈការពង្រឹង និងការកែសម្រួលរបៀបរបបការងារតាមវិធីសាស្ត្រដែលផ្តោតទៅលើប្រជាជន។ សេវាចុះបញ្ជីអត្រានុកូលដ្ឋាន និងការចេញឯកសារអត្តសញ្ញាណកម្ម គឺជាផ្នែកមួយនៃសេវាកម្មរបស់រាជរដ្ឋាភិបាលចំពោះប្រជាជន ហេតុនេះត្រូវតែធ្វើឱ្យមានស្តង់ដា និងគុណភាពខ្ពស់ ប្រសិទ្ធិភាព តម្លាភាព និងរហ័ស។ ត្រូវចាត់ទុកថា ប្រជាជនក៏ជាអ្នកលើកស្ទួយការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធិភាព ហើយប្រជាជនក៏ត្រូវតែមានលទ្ធភាពក្នុងការផ្តល់មតិយោបល់ត្រឡប់ពីគុណភាពនៃសេវាកម្មទាំងអស់។ កំណើននៃការចូលរួមពីប្រជាជនគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងទៅលើការងារវិមជ្ឍការ ដូច្នេះការចុះបញ្ជីអត្រានុកូលដ្ឋាន និងសេវាកម្មពាក់ព័ន្ធ

ផ្សេងៗទៀតក៏ត្រូវតែទទួលចំណែកពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទពីក្នុងចំណោមសមាជិកផ្សេងៗ និងអង្គភាពដែលតំណាងឱ្យប្រជាជន។

រាល់ការផ្តល់សេវាទាំងអស់ពាក់ព័ន្ធទៅនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ត្រូវមានទីកន្លែងសមរម្យ ងាយស្រួលដល់ប្រជាពលរដ្ឋ និងត្រូវអនុវត្តតាមស្តង់ដាខ្ពស់។ ដូចនេះការប្រើប្រាស់ប្រព័ន្ធការិយាល័យច្រកចេញចូលតែមួយក៏ត្រូវបានបង្កើនឡើងដែរ។ ក្នុងរយៈពេលវែង គោលដៅរួមគឺត្រូវផ្តល់សេវាទាំងអស់តាមរយៈមន្ត្រីដែលមានការបណ្តុះបណ្តាល (អ្នកឯកទេស)។ កត្តានេះត្រូវចូលរួមដោយសកម្មភាពដូចជា៖

- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ
- ធានាឱ្យមានការចូលរួមពីសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន
- ដាក់ឱ្យប្រើប្រាស់សេវាទូរស័ព្ទឥតគិតថ្លៃសម្រាប់ទទួលព័ត៌មានត្រលប់ពីប្រជាពលរដ្ឋ
- រៀបចំកែសម្រួល របៀបរបបការងារផ្ទៃក្នុងចំពោះយោបល់ត្រលប់ពីប្រជាជន
- ណែនាំប្រជាជនឱ្យប្រើប្រាស់សេវាតាមប្រព័ន្ធអេឡិចត្រូនិច និងប្រព័ន្ធបង់ប្រាក់តាមអេឡិចត្រូនិចផងដែរ
- រៀបចំសេចក្តីព្រាងអនុក្រឹត្យនានា
- ធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តនានានៃក្របខណ្ឌច្បាប់មួយចំនួនដែលនឹងមានអន្តរកម្មជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន ព្រមទាំងប្រតិបត្តិការណ៍របស់ប្រព័ន្ធរួមនេះ។

### ខ.៥. បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋានមានលក្ខណៈជាសកល

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតបដែលជួយដល់ការគោរពសិទ្ធិមនុស្ស មានសមធម៌ និងផ្តោតទៅលើមនុស្សគួរតែត្រូវបង្កើតឡើងសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដោយការបង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែល ៖

- តាមកុំព្យូទ័រដោយប្រើប្រាស់វេបសាយ និងបច្ចេកវិទ្យាចល័ត និងសហប្រតិបត្តិការអន្តរជាតិ
- ពង្រីកមុខងារជាមន្ត្រីអត្រានុកូលដ្ឋានដល់មន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ពង្រឹងសមត្ថភាពគ្រប់គ្រង និងប្រតិបត្តិការការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន
- បង្កើតសៀវភៅណែនាំស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលក្ខណៈឯកភាព និងបង្កើតគោលការណ៍ណែនាំនានា
- ការបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានដែលមានស្រាប់ជាប្រព័ន្ធឌីជីថល
- ផ្លាស់ប្តូរទម្រង់សំបុត្រកំណើត

- បង្កើតប្រព័ន្ធផលិតស្ថិតិអត្រានុកូលដ្ឋានជាទៀងទាត់ដោយផ្អែកលើកំណត់ត្រាអត្រានុកូលដ្ឋាន និងអនុញ្ញាតឱ្យសាធារណៈជនចូលយកប្រើប្រាស់បាន
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងកសាងសមត្ថភាពលើការងារបង្កើតស្ថិតិអត្រានុកូលដ្ឋាន
- ភ្ជាប់ប្រព័ន្ធព័ត៌មានសុខាភិបាល តុលាការ និងបញ្ជីប្រជាជន ទៅនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន
- បង្កើនឱ្យមានការចូលរួមពីវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីលើកកម្ពស់កំណើនតម្រូវការ
- កសាងទំនុកចិត្ត និងលើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- ការកសាងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីឆ្លងកាត់តាមរយៈ ការសិក្សាស្រាវជ្រាវ អំពីប្រធានបទស្តីពី **ការផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា** ខាងលើរួចមក យើងសង្កេតឃើញថា ការចុះសៀវភៅអត្រានុកូលដ្ឋាន គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋដែលមានទៅលើ រដ្ឋមួយដែលខ្លួនរស់នៅ។ ម៉្យាងវិញទៀតការចុះសៀវភៅអត្រានុកូលដ្ឋាន ក៏ដូចជា សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត សំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សំបុត្រមរណភាព ឬ សំបុត្របញ្ជាក់មរណភាព គឺមានលក្ខណៈស្មុគស្មាញ ជាពិសេសនៅពេលដែលមានធាតុផ្សំបរទេសចូលរួម។ ទោះជាយ៉ាងនេះក៏ដោយ ក៏អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានបានបញ្ញត្តិយ៉ាងច្បាស់គ្រប់ករណីដែលអាចនឹងកើតមានឡើង ងាយស្រួលដល់ការអនុវត្តន៍ក្នុងទិដ្ឋភាពផ្សេងគ្នា។ ការចុះសៀវភៅកំណើតដើម្បីបញ្ជាក់ពីសញ្ជាតិ ទីកន្លែងរស់នៅ និងអាណាព្យាបាលរបស់ទារក ការចុះសៀវភៅអាពាហ៍ពិពាហ៍គឺជាការចងបុគ្គលពីរដែលជាប្តីប្រពន្ធឱ្យស្ថិតក្នុងការទទួលខុសត្រូវក្នុងភាពជា មាតាបិតា និង ករណីយកិច្ចទៅវិញទៅមក ចំពោះសហព័ទ្ធ ចំណែកឯការចុះសៀវភៅមរណភាពគឺជាការប្រកាសនូវមរណភាពរបស់បុគ្គលដែលបានស្លាប់ដែលជាផលប្រយោជន៍ក្នុងការអនុវត្តន៍ច្បាប់កិច្ចសន្យានានា។

ការងារនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ប្រជាពលរដ្ឋក៏ដូចជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាមួយចំនួនតូចហាក់នៅតែពុំបានឱ្យតម្លៃចំពោះកិច្ចការទាំងនេះនោះទេ ជាពិសេសប្រជាជនដែលរស់នៅទីជនបទ និងតំបន់ដាច់ស្រយាល។ កត្តាទាំងនោះគឺអាចបណ្តាលមកពីកម្រិតនៃការយល់ដឹង ផ្នត់គំនិត ជីវភាព។ ឯកត្តាខ្លះទៀតអាចមកពីសមត្ថភាពនៃមន្ត្រីចុះបញ្ជីអត្រានុកូលដ្ឋានផ្ទាល់ និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

យើងឃើញថា ការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានក៏ជាផ្នែកមួយនៃសេវាសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានផលប៉ះពាល់ផ្ទាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់គោលដៅជាយុទ្ធសាស្ត្រស្តីពី ការពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបានប្រសិទ្ធិភាព និងប្រសិទ្ធិផលនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង ក្នុងយុទ្ធសាស្ត្រចតុកោណផងដែរ។ ម៉្យាងវិញទៀត ការឈានជើងចូលទៅក្នុងសមាហរណកម្មអាស៊ាន ជាកត្តាមួយដែលតម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជាកាន់តែត្រូវយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀតលើវិស័យនេះ ព្រោះលំហូរសេរីនៃពលកម្មអន្តរជាតិចូលមកកម្ពុជានឹងអាចធ្វើឱ្យកម្ពុជាបាត់បង់នូវផលប្រយោជន៍នានា ប្រសិនបើកម្ពុជាពុំបានរៀបចំរបាយការណ៍ប្រជាជនរបស់ខ្លួនឱ្យមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ រហ័ស និងជឿទុកចិត្តបាន។

ជាលទ្ធផលដោយផ្អែកតាមគោលនយោបាយ និង វិធានការរបស់ថ្នាក់ដឹកនាំ រួមទាំងការខិតខំប្រឹងប្រែងដោយផ្ទាល់របស់អាជ្ញាធរឃុំ សង្កាត់ទូទាំងប្រទេស ដោយមានការគាំទ្រពីក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ

អាជ្ញាធរខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងអង្គការជាតិ និង អន្តរជាតិនានា បានធ្វើឱ្យការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ បើទោះបីជាមានកំហុសឆ្គង និងឧបសគ្គខ្លះៗក៏យើងអាចវាយតម្លៃខ្ពស់ពីការខិតខំប្រឹងប្រែងរបស់ស្ថាប័នគ្រប់ជាន់ថ្នាក់ ព្រោះថាកម្ពុជាជាប្រទេសដែលអាចចាត់ទុកបានថា នៅក្មេងខ្ចី (ទើបរួចផុតពីវិបត្តិសង្គ្រាមរ៉ាំរ៉ៃ) ទោះបីអរិយធម៌ និងប្រវត្តិសាស្ត្រនៃប្រទេសនេះ មានភាពចំណាស់ជាងគេក៏ពិតមែន ក៏យើងមិនអាចប្រៀបធៀបទៅនឹងបណ្តាប្រទេសអភិវឌ្ឍន៍ដទៃទៀតបានដែរ។ យើងមានតែសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តការយកចិត្តទុកដាក់ខ្ពស់ទៅលើវិស័យនេះឱ្យដូចទៅនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពី អត្តសញ្ញាណកម្ម ២០១៧-២០២៦ ឱ្យកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផល។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និង ស្វែងយល់អំពីប្រធានបទដូចដែលបានបកស្រាយខាងលើរួចមកនេះ ក្រុមរបស់យើងខ្ញុំសូមធ្វើការផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីចូលរួមផ្តល់ជាគំនិតក្នុងការសិក្សាឈ្វេងយល់បន្ថែមដូចតទៅ៖

- ពង្រឹងការត្រួតពិនិត្យលើការអនុវត្តន៍ការងាររបស់រដ្ឋបាលឃុំ សង្កាត់ដែលជាមន្ត្រីចុះបញ្ជីអត្រានុកូលដ្ឋាន
- បង្កើត និងបង្កើនការផ្សព្វផ្សាយពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន នីតិវិធី និងភាពងាយស្រួលនៃការចុះបញ្ជី ការផ្សព្វផ្សាយតាមមូលដ្ឋានដោយមេភូមិ ចៅសង្កាត់ ស្ពតពាណិជ្ជកម្មតាមទូរទស្សន៍ ឬវិទ្យុ និងវីដេអូខ្លីៗតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម
- យកចិត្តទុកដាក់ និងពន្លឿនសេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋានឱ្យឆាប់ទទួលបានការអនុម័តពីសភា និងប្រកាសឱ្យប្រើប្រាស់
- ក្រសួងមហាផ្ទៃគួរបង្កើតផែនការ៣ឆ្នាំរំកិលនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្មឆ្នាំ២០១៧-២០២៦ ដោយកំណត់ពីផែនការសកម្មភាពតូចៗដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែងក្នុងពេលបច្ចុប្បន្ន
- កំណត់ពីកម្រិតនៃចំណេះដឹង និងបទពិសោធន៍របស់បេក្ខជនជាប់ឈ្មោះជាមេឃុំ ចៅសង្កាត់ ក៏ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើបច្ចុប្បន្នភាពពីស្ថានភាពប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេស អាចមួយឆ្នាំម្តង ឬ២ឆ្នាំម្តងតាមរយៈស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជាដែលមាននៅទីនោះ
- រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលមកពីក្រសួង និងអង្គការសង្គមស៊ីវិល
- នាយកដ្ឋានអត្រានុកូលដ្ឋានគួរមានកញ្ចប់ថវិកាផ្ទាល់ខ្លួនប្រចាំឆ្នាំ ដើម្បីទ្រទ្រង់រាល់សកម្មភាព និងផែនការនានារបស់នាយកដ្ឋានដែលត្រូវទទួលការយល់ព្រមពី MoI, MoH និងMoP
- មន្ត្រីចុះបញ្ជីអត្រានុកូលដ្ឋានគួររៀបចំឱ្យមាន៤ថ្នាក់ដូចទៅនឹងបណ្តាប្រទេសផ្សេងៗ មានដូចជាថៃ វៀតណាម ម៉ាឡេស៊ី
- ច្បាប់គួរបញ្ជាក់ពីការផ្តល់ព័ត៌មានចាំបាច់ពីមូលដ្ឋានសុខាភិបាល (ឯកជន និងសាធារណៈ) និងព្រឹត្តិការណ៍សំខាន់ៗ (កើត និងស្លាប់) ជាពិសេសការបញ្ជាក់ពីមូលហេតុនៃការស្លាប់ ឯការចុះបញ្ជីមរណភាពគួរភ្ជាប់មកជាមួយក្រដាសវេជ្ជសាស្ត្រ ឬលិខិតបញ្ជាក់ពីកោសល្យវិច្ច័យសាកសព។

# ឯកសារយោង

# ឯកសារយោង

❖ **ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលត្រូវបានប្រោសឱ្យបោះពុម្ពនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១
- ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ៥៦ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩
- ច្បាប់ស្តីពី អន្តោប្រវេសន៍ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៤
- ច្បាប់ស្តីពី សញ្ជាតិ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។

❖ **អនុក្រឹត្យ**

- អនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០
- អនុក្រឹត្យស្តីពី ការកែសម្រួលមាត្រា៨ និងមាត្រា៥៩ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពី អត្រានុកូលដ្ឋាន លេខ៦០ អនក្រប.ក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២
- អនុក្រឹត្យស្តីពី ការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ លេខ៦២ អនក្រប.ក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០២
- អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ ១៧ អនក្រប.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤
- អនុក្រឹត្យស្តីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ១៧ អនក្រប.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ១០៦ អនក្រប.ក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥
- អនុក្រឹត្យស្តីពី ការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ១០៦ អនក្រប.ក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ថ្មីស្ទួន លេខ ៨៩ អនក្រប.ក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦
- អនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបចំអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស លេខ១៨៣ អនក្រប.ក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨

- អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៥ នៃអនុក្រឹត្យលេខ១៥៨ អនក្រប.ក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ លេខ១៨២ អនក្រប.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ លេខ១០៩ អនក្រប.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥។

❖ ប្រកាស

- ប្រកាសស្តីពី ការប្តូរឈ្មោះការិយាល័យកិច្ចការទូទៅ ជាការិយាល័យស្ថិតិ និង អត្រានុកូលដ្ឋាន ចំណុះសាលា ខេត្ត ក្រុង លេខ១០៨៦ ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦
- ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៣៨៥៦ ប្រ.ក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣
- ប្រកាសស្តីពី រចនាសម្ព័ន្ធនាយកដ្ឋានអត្រានុកូលដ្ឋាននិងតួនាទី ភារកិច្ចរបស់ការិយាល័យចំណុះ លេខ៣០២៨ ប្រ.ក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤
- ប្រកាសស្តីពី ការបញ្ចប់ការទទួលពាក្យស្នើសុំជាជនបរទេសអន្តោប្រវេសន៍ និង ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ លេខ៥៦៧១ ប្រ.ក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។

❖ សេចក្តីណែនាំ

- សេចក្តីណែនាំការកំណត់អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស លេខ០០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩
- សេចក្តីណែនាំស្តីពី ការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការ ចុះសៀវភៅអត្រានុកូលដ្ឋានចល័ត លេខ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧
- សេចក្តីណែនាំអន្តរក្រសួងស្តីពី ការកែតម្រូវ និង បំពេញចំណុចខ្វះខាតនៅក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ លេខ០១០ សណន មជក កយ/០៧ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧
- សេចក្តីណែនាំស្តីពី ការចេញលិខិតរដ្ឋបាល និង លិខិតអត្រានុកូលដ្ឋានឱ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន៍ លេខ០១៥ សណន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៩
- សេចក្តីណែនាំស្តីពី វិធានការពង្រឹងការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋាន លេខ០២៩ សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០
- សេចក្តីណែនាំស្តីពី ការកែតម្រូវ និង ការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន លេខ ០៣៥ សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

- សេចក្តីណែនាំស្តីពី ការបន្តដំណើរការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន លេខ០៤៥ សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

❖ **សៀវភៅ និង កម្រងឯកសារពាក់ព័ន្ធផ្សេងៗ**

- កម្រងឯកសារ ស្តីពី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន (ខែតុលា ២០១៥)
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦
- របាយការណ៍វាយតម្លៃនៃក្រសួងមហាផ្ទៃ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការចុះបញ្ជីអត្រានុកូលដ្ឋាន នៅប្រទេសកម្ពុជា (ខែមិនា ឆ្នាំ២០១៥)
- របាយការណ៍ការវាយតម្លៃលើគុណភាព និងការប្រើប្រាស់ព័ត៌មាន កំណើត អាពាហ៍ពិពាហ៍ និងមូលហេតុនៃការស្លាប់
- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ២០១៩ របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែមិថុនា របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សម្រាប់ឆ្នាំ២០២០
- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សម្រាប់ឆ្នាំ២០២០។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ៖

# គំរូលិខិតអនុគ្រោះនុក្កូលដ្ឋានកំណើត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ៖---------------
ក្រុង ស្រុក ខណ្ឌ ៖---------------
ឃុំ សង្កាត់ ៖----------------
ភូមិ ៖---------------- ថ្ងៃទី------ ខែ---------- ឆ្នាំ-------

## លិខិតបញ្ជាក់ទទួលស្គាល់កំណើត

យើង-------------------- ជាមេភូមិ-------------------- នៃឃុំ សង្កាត់-------------------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត ------------ សូមបញ្ជាក់ថា (នាមត្រកូល-នាមខ្លួនទារក)---------------------- ភេទ----- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ នៅផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុមទី------- ភូមិ-------- ឃុំ សង្កាត់------------ ក្រុង ស្រុក ខណ្ឌ------------ រាជធានី ខេត្ត ------------- ឪពុកឈ្មោះ--------------------- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ ម្តាយឈ្មោះ----------------- កើតនៅថ្ងៃទី------ ខែ---------ឆ្នាំ--------- មានទីលំនៅបច្ចុប្បន្ននៅភូមិ---------------- ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ---------------------- រាជធានី ខេត្ត ------------- ពិតជាបានកើតនៅផ្ទះ ប្រាកដមែន ដែលមានឆ្មបបង្កើតឈ្មោះ------------------------ ភេទ------- ឆ្នាំកំណើត--------- មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ---------- ផ្លូវលេខ ---------- ក្រុមទី ---------- ភូមិ------------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ---------។

“លិខិតបញ្ជាក់ទទួលស្គាល់កំណើតនេះ ចេញឱ្យប្រើប្រាស់សម្រាប់ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត”

**មេភូមិ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យប្តឹងសុំសំបុត្រអត្រានុកូលដ្ឋានកំណើត

ខ្ញុំបាទ នាងខ្ញុំឈ្មោះ------------------------------------- សញ្ជាតិ---------- ឆ្នាំកំណើត----------- មុខរបរបច្ចុប្បន្ន------------------------------------------------------------------------------------------ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ--------- ក្រុមទី---------- ភូមិ------------ឃុំ សង្កាត់---------------- ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ------------------- ។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---------------------**

**កម្មវត្ថុ** ៖ សំណើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឱ្យឈ្មោះ------------------- ។

**យោង** ៖ លិខិត------------------------------------- លេខ----------- ចុះថ្ងៃទី------ ខែ---------

ឆ្នាំ--------- របស់--------------------------------------------------------------------- ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមជម្រាបជូន លោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋាន មេត្តាជ្រាបថា ឈ្មោះ-------------------------- ត្រូវជា------------------------- ពុំទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឡើយ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋានមេត្តាចុះសៀវភៅអត្រានុកូលដ្ឋានកំណើត តាមសំណើខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី------- ខែ----------- ឆ្នាំ--------

**ស្នាមមេដៃស្តាំអ្នកប្តឹង**

<u>សូមជូនភ្ជាប់មកជាមួយនូវ</u> ៖

- --------------------------
- --------------------------

**ខេត្ត ~~ក្រុង~~** (១)........... *កណ្តាល* ............. **លេខ** (៤)............ *២៥* ...............................

**ស្រុក ~~ខណ្ឌ~~** (២)........ *កណ្តាលស្ទឹង* ......... **សៀវភៅកំណើតលេខ** (៥)....០១/២០១២....

**ឃុំ ~~សង្កាត់~~** (៣)......... *គោកត្រប់* ............ **ឆ្នាំ** (៦)....... *២០១២*....................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | *សម* | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនទារក (៨) | | *សិទ្ធី* | *ប្រុស* | *ខ្មែរ* |
| ជាអក្សរឡាតាំង (១១) | នាមត្រកូល | SAM | កូនទី (១២) | មាន ឬឥតខាន់ស្លា (១៣) |
| | នាមខ្លួនទារក | SITHY | *មួយ* | *មានខាន់ស្លា* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៤) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | | |
| ទីកន្លែងកំណើត (១៥) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ........... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ................ ........................................................ | | |

| **ឪពុក ម្តាយទារក** | **ឪពុក** | | **ម្តាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៦) | *សម សោភ័ណ* (១៧) | រស់ ឬ ~~ស្លាប់~~ | *គុណ រតនា* | រស់ ឬ ~~ស្លាប់~~ |
| ជាអក្សរឡាតាំង (១៨) | *SAM SORPHORN* | | *KUN RATANA* | |
| សញ្ជាតិ (១៩) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* | |
| ទីកន្លែងកំណើត (២១) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | .........*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* ....................... | | ....... *ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា* ..... | |
| មុខរបរពេលទារកកើត (២២) | *គ្រូបង្រៀន* | | *ជាងកាត់ដេរ* | |
| ទីលំនៅពេលទារកកើត (២៣) | ....... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ..... | | ....... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ..... | |
| លេខអត្តសញ្ញាណប័ណ្ណ (២៤) | | | | |

| | | | | |
|---|---|---|---|---|

**មាត្រា ៣៧** ៖ បញ្ជីនោះត្រូវចាងហ្វាងសាលាដំបូងចុះសង្ខេបហត្ថលេខា និងលេខគ្រប់ទំព័រហើយដាក់ឲ្យមេឃុំកាន់រក្សា ឬ បើមេឃុំមានធុរៈ, ឲ្យជំទប់លេខ ១ កាន់រក្សាជួស ។

(ក្រមដូចខាងលើបន្ថែមដូចតទៅនេះ) ក៏ប៉ុន្តែដោយប្រមើលដល់ព្រឹត្តិការណ៍ក្នុងអនាគត, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងមហាផ្ទៃអាចកែប្រែខ្លះដោយសេចក្តីសម្រេចរួមគ្នាមួយនូវរបៀបកាន់កាប់បញ្ជីអត្រានុកូលដ្ឋាននៃជនបរទេស ។ បទបញ្ញត្តិទាំងឡាយណាដែលមានរួចមកហើយតាមន័យនេះត្រូវទុកជាបានការយ៉ាងពិតទាំងអស់ ។

បទបញ្ញត្តិនោះមានដូច្នេះជាដើម, ឈ្មោះនៃជនបរទេសទាំងឡាយមិនត្រូវចុះតែជាអក្សរខ្មែរប៉ុណ្ណោះទេ គឺត្រូវចុះអក្សរកំណើត នៃជននោះផងដោយគោរពយ៉ាងដាច់ខាតនូវអក្ខរាវិរុទ្ធនៃកាសារនោះ, នោះប្រសិនបើអាចធ្វើបាន ។

**មាត្រា ៣៨** ៖ ក្នុងក្រុងភ្នំពេញចៅសង្កាត់ទាំងឡាយត្រូវកាន់រក្សាបញ្ជីទាំងឡាយនោះ ។

**មាត្រា ៣៩** ៖ បញ្ជីមួយត្រូវធ្វើជាភ្លោះ, ពីរខ, តាមគំរូនិងទម្រង់ដែលដាក់ជាប់នឹងច្បាប់នេះ ។ បញ្ជីនោះមិនត្រូវឲ្យមានកោស, លុប, ច្រៀត, ថែមទេ, បើមានឆូតលុប ត្រូវទុកស័ព្ទដែលលុបនោះឲ្យនៅមើលឃើញបានហើយយោងន័យលក្ខណៈនោះនៅរឹមទំព័រថា "យល់ព្រមលុប" ទើបឲ្យមន្ត្រីអត្រានុកូលដ្ឋាន, អ្នកប្ដឹងនិងសាក្សីចុះហត្ថលេខាទាំងអស់គ្នា ។ សញ្ញាប័ត្រទាំងឡាយត្រូវចុះរៀងគ្នាពីមួយទៅមួយ, តៗគ្នាកុំបីចោលទំព័រឲ្យនៅទំនេរឡើយ ។

**មាត្រា ៤០** ៖ នៅថ្ងៃទី១ នៃខែនីមួយៗមន្ត្រីអត្រានុកូលដ្ឋានត្រូវស្រង់សេចក្ដីដែលខ្លួនបានកត់ក្នុងបញ្ជីក្នុងខែ ដែលដាច់ទៅហើយធ្វើជាបញ្ជីចុះហត្ថលេខាខ្លួនបញ្ជូនទៅទីសមុហបញ្ជីសាលាដំបូងត្រួតពិនិត្យសេចក្ដីនោះ, បើឃើញថាមានសេចក្ដីភ្លាត់ភ្លាំងដើម្បីកែតម្រូវ, ត្រូវចេញសាលក្រមបង្គាប់ឲ្យកែតម្រូវតាមគួរ ។

**មាត្រា ៤១** ៖ បញ្ជីនោះត្រូវបញ្ឈប់ផ្ដាច់ឆ្នាំ ទៅថ្ងៃទី ៣១ ធ្នូ ក្នុងឆ្នាំនីមួយៗ ។ សៀវភៅ ១ ក្បាល ត្រូវបញ្ជូនទៅសមុហបញ្ជីនៃសាលាដំបូងក្នុងខែ មករា ជាបន្ទាប់, សៀវភៅមួយក្បាលទៀតត្រូវទុកនៅបណ្ណសាដ្ឋានក្នុងឃុំ ឬក្នុងស្រុក, បើអង្គការឃុំមិនគប្បីឲ្យទុកបានទេ, ហើយផ្ញើនឹងមេឃុំ ឬ ស្មៀន,

យោក្ស៊ត្រ, ឬ ក្រមការសាលាស្រុកដែលមាននីតិសម្បទានក្នុងការនេះឲ្យថែរក្សា ។

**មាត្រា ៤២** ៖ អាពាហ៍ពិពាហ៍សញ្ញាប័ត្រ, ជាតិសញ្ញាប័ត្រ, មរណភាពសញ្ញាប័ត្រនៃព្រះរាជវង្សានុវង្ស ត្រូវដាក់ក្នុងបញ្ជីដោយឡែកដែលរក្សាទុកក្នុងទីព្រះរាជាយុត្តកៈនៅក្នុងបង្គាប់ត្រួតត្រានៃឧកញ៉ាវាំង ត្រួតត្រាឲ្យបានត្រឹមត្រូវហើយបញ្ជូនសេចក្តីចម្លងមួយច្បាប់ ជាចាំបាច់ទៅចៅសង្កាត់ក្នុងរវាង ២៤ ម៉ោងតាមសេចក្តីបញ្ញត្តិនៃព្រះរាជប្រកាស ចុះថ្ងៃអាទិត្យ ៨ រោជ ខែ ផគុណ ឆ្នាំវកសំរិទ្ធិស័ក ត្រូវនឹងថ្ងៃ ១៤ ខែ មារ្ស ឆ្នាំ ១៩០៩ ។ ចៅសង្កាត់ត្រូវចំឡងសេចក្តីនេះមួយរំពេចដាក់ក្នុងបញ្ជីអត្រានុកូលដ្ឋានដែលខ្លួនរក្សា ។

**មាត្រា ៤៣** ៖ ព្រះរាជវង្សានុវង្ស នៃព្រះករុណាទ្រង់រាជ្យ និងព្រះករុណាសុវណ្ណកត់ ដែលមានសិទ្ធិត្រូវឲ្យគត់អត្រានុកូលដ្ឋានដោយឡែកដូចនេះបានត្រឹមតែព្រះរាជបុត្រ, ព្រះរាជនត្តា និងព្រះរាជបុត្រ ឬ ព្រះរាជនត្តានៃព្រះមហាក្សត្រយ៍ទ្រង់រាជ្យ ។

**មាត្រា ៤៤** ៖ ជនណា មានកាតព្វកិច្ច ត្រូវប្តឹងកំណើត និងមរណភាពតាមសេចក្តីបញ្ញត្តិនៃមាត្រាខាងក្រោមនេះហើយភ្លេច ឬ ធ្វេសប្រហែសមិនបានប្តឹងដោយឥតហេតុដ៏គួរ, ជននោះនឹងត្រូវទណ្ឌកម្មជាលហុទោស ។

**មាត្រា ៤៥** ៖ ជនណាដោយមានក្លែងយកសេចក្តីខុស ឬ ក៏បណ្តោយឲ្យគេយកសេចក្តីខុសទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋាន ឬ ប្រាប់នូវពត៌មានខ្វះ ឬ មិនពិត, ជននោះនឹងត្រូវទណ្ឌកម្មដាក់គុកពី ១៥ ថ្ងៃទី ៣ខែ ឬ ពិន័យពីដប់រៀលទៅមួយរយ

រៀល, បើចូលក្នុងបទឧក្រិដ្ឋក្លែងលិខិតជាផ្លូវការ ឬ សមគំនិតក្លែងលិខិតជាផ្លូវការ ដែលមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌក៏នឹងត្រូវឲ្យមានទោសនោះផងទៀត ។

**មាត្រា ៤៦** ៖ មន្ត្រីអត្រានុកូលដ្ឋានដោយធ្វេសប្រហែសមិនថែរក្សាបណ្ដាលជាយថាហេតុឲ្យខានធ្វើ, ឲ្យអន្តរាយ, ឲ្យខូច ឬ ឲ្យបំផ្លាញនូវសញ្ញាប័ត្រណាមួយ ឬ សៀវភៅណាមួយនឹងត្រូវទោសគុកពី ៦ថ្ងៃ ទៅ៣ខែ និងត្រូវពិន័យជាប្រាក់ពីដប់រៀលទៅមួយរយរៀល ឬ គ្រាន់តែជាប់គុក ឬ គ្រាន់តែពិន័យតែមួយយ៉ាងក៏បាន, តែបើឃើញថាមានទោសក្លែងផងនឹងត្រូវធ្វើទោសតាមបទល្មើសនោះដែរ ។

**មាត្រា ៤៧** ៖ (ព្រះរាជប្រកាស លេខ ៩៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ ១៩២៧) ៖ សាក្សី២ នាក់ដែលជានីតិជននោះ, ទោះស្រីក្ដី, ប្រុសក្ដីអំណេះតទៅត្រូវមិនឲ្យមានក្នុងសំបុត្រកំណើត និងសំបុត្រមរណភាពទេ ។ សាក្សី២នាក់នោះត្រូវឲ្យមានតែក្នុងសំបុត្រអាពាហាពិពាហ តាមករណីដូចមានសម្ដែងក្នុងបញ្ញត្តិមាត្រា ៦៨នៃក្រមនេះ ។

**មាត្រា ៤៨** ៖ បញ្ជីដែលកាន់រក្សាក្នុងទីសមុហបញ្ជីនៃសាលាដំបូងត្រូវទុកជាបន្ទាល់ក្នុងតុលាការដរាបដល់មានបន្ទាល់ផ្ទុយទើបត្រូវឈប់ ។ មន្ត្រីអត្រានុកូលដ្ឋានអាចចេញកំណត់ដៃ (សេចក្ដីស្រង់) សញ្ញាប័ត្រដែលមានក្នុងឆ្នាំដែលកំពុងកាន់ឲ្យអ្នកសុំបាន ។

ឯបញ្ជីនៃឆ្នាំដែលកន្លងទៅហើយមន្ត្រីអត្រានុកូលដ្ឋានក្ដី, សមុហបញ្ជីក្នុងសាលាដំបូងក្ដីអាចចេញកំណត់ដៃ(សេចក្ដីស្រង់) ឲ្យជនណាដែលសុំបានទាំងអស់

គ្នាហើយត្រូវបានខ្វាត់ ៣ រៀល ក្រៅពីថ្លៃតែមផង ។ ឯប្រាក់ខ្វាត់ ៣ រៀល នេះត្រូវបានជាប្រយោជន៍នៃមន្ត្រីអត្រានុកូលដ្ឋាន ឬ សមុហបញ្ជី, ស្មៀន, យោក្ខ័ត្រ, ក្រមការដូចដែលមានសំដែងមកខាងលើនេះ ។

ឯសេចក្តីស្រង់នេះត្រូវមន្ត្រីអត្រានុកូល ឬ សមុហបញ្ជី សាលាដំបូង, ស្មៀន, យោក្ខ័ត្រ, ក្រមការ ចុះហត្ថលេខា ហើយថ្លៃដែលចេញឲ្យត្រូវសរសេរជាអក្សរពេញអង្គ ។ ហត្ថលេខាមេឃុំ, ស្មៀន, យោក្ខ័ត្រ, ក្រមការត្រូវឲ្យចៅហ្វាយស្រុកបញ្ជាក់ ។ ឯហត្ថលេខាក្រឡាបញ្ជីត្រូវឲ្យចាងហ្វាងសាលាដំបូងចុះសេចក្តីបញ្ជាក់ផង ។

## ផ្នែកទី ១
## សញ្ញាប័ត្រ កំណើត

**មាត្រា ៤៩** ៖ នាកាលមានទារកកើតក្នុងឃុំ, នោះអ្នកមានកាតព្វកិច្ចត្រូវប្តឹងក្នុងកំណត់ ១៥ ថ្ងៃ ។

**មាត្រា ៥០** ៖ នឹងប្តឹងនូវកំណើតទារកនោះ, បើឪពុកនៅ, ត្រូវឲ្យឪពុកប្តឹង, បើឪពុកមិននូវ ឬ មានធុរៈ ឬ បើម្តាយនៃទារកនោះមិនមានប្តីតាមច្បាប់ទេ, ជនដែលបានទៅជួយធុរៈក្នុងវេលាកើត ឬ ជនដែលនៅជាមួយនឹងស្រីដែលបង្កើតកូននោះត្រូវប្តឹងតាមសេចក្តីបញ្ញត្តិ ។

**មាត្រា ៥១** ៖ ជនដែលបានឃើញទារកទើបនឹងកើត ដែលគេបោះបង់ចោលត្រូវយកទៅប្រគល់ឲមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំព្រមទាំងសំពត់ដែលជាប់នឹងខ្លួនទារកនោះហើយជូនពត៌មានអំពីពេល និងទីកន្លែងដែលខ្លួនបានប្រទះឃើញ

ទារកនោះផង ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវកត់ពត៌មាននោះក្នុងសៀវភៅកំណើត ហើយដាក់អាយុទារកនោះដោយស្មាន, ដាក់ឈ្មោះទារកនោះមួយរំពេច ។

**មាត្រា ៥២** ៖ ក្រមលេខ ៩០៨ នស. ២៥-១០-៥៤ ជាតិសញ្ញាប័ត្រត្រូវប្រាប់ថ្ងៃ ខែ ដែលទារកកើត, ភេទ នៃទារក "គឺជាប្រុស ឬស្រី" ឈ្មោះ ត្រកូល, ឈ្មោះទារក, របរ និងលំនៅដ្ឋាន នៃឪពុកម្ដាយ ។ ទារកដែលកើតក្រៅខាន់ស្លាត្រូវដាក់តែឈ្មោះម្ដាយ, បើឪពុកប្រាកដជាបានសុំឲ្យចុះឈ្មោះខ្លួនជាឪពុកផងទើបដាក់បាន ។

ក្រោយដែលបានតែងសញ្ញាប័ត្រនោះហើយ, មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ទៅអ្នកប្ដឹងដោយឥតយកថ្លៃនូវព្រឹត្តិប័ត្រមួយសន្លឹក ដែលមានចុះឈ្មោះទារកនោះ និងឈ្មោះឪពុកម្ដាយវាព្រមទាំងថ្ងៃ ខែ ឆ្នាំ ដែលកើតទៀតផង ។

ព្រឹត្តិប័ត្រ ដែលបានចេញឲ្យយ៉ាងនេះព្រមទាំងកំណត់ដៃនៃសញ្ញាប័ត្រអត្រានុកូលដ្ឋាន ដែលចេញឲ្យពីនេះទៅមិនត្រូវឲ្យមានចុះសេចក្ដីដូចតទៅនេះទេ, ល្គឹកណាបើចុះ, មន្ត្រីអត្រានុកូលដ្ឋាននឹងត្រូវមានទោសពិន័យជាប្រាក់មួយពាន់រៀលហើយនឹងត្រូវបង់ជម្ងឺចិត្តឲ្យគេទៀតក៏បាន ៖

១. លក្ខណៈនៃកំណើតនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។

២. ថ្នាក់នៃខាន់ស្លារបស់ឪពុកម្ដាយ ។

៣. របរ, អម្បូរ, សាសនា, ឬ សញ្ញាតិរបស់ឪពុកម្ដាយ

៤. ការណ៍ដែលកាលចុះបញ្ជីកំណើតនោះចុះដោយមានគេទៅប្ដឹងឲ្យចុះ ឬ ចុះតាមសាលក្រមជំនួយសញ្ញាប័ត្រកំណើត ។

ពត៌មានទាំងអស់នេះមានតែអាជ្ញាធរខាងរដ្ឋបាល ឬ ខាងតុលាការប៉ុណ្ណោះទេ ដែលអាចបង្គាប់ឲ្យគេជូនដល់ខ្លួនបានហើយក្នុងការជាអាថ៌កំបាំងទៀតផង ។

**មាត្រា ៥៣** ៖ បណ្ដឹងពីកំណើតទារកដែលកើតចេញអំពីឪពុកខ្មែរខាងក្រៅដែនកម្ពុជា គឺកើតក្នុងស្រុកណាមួយដែលពុំមានបង្កើតអត្រានុកូលដ្ឋានទេ ត្រូវឪពុកឬម្ដាយប្ដឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំដែលខ្លួននៅក្នុងកំណត់៨ថ្ងៃ ក្រោយដែលវិលមកដែនខ្មែរវិញ, មន្ត្រីអត្រានុកូលដ្ឋានត្រូវកត់កំណើតនោះក្នុងបញ្ជីកំណើតក្នុងឆ្នាំនោះ ហើយចុះនិទ្ទេសនៅរឹមទំព័រនៃសញ្ញាប័ត្រកំណើតណាដែលមានថ្ងៃ.ខែ ជិតជាងគេក្នុងសៀវភៅមួយក្បាលៗ ដែលរក្សាទុកក្នុងបណ្ណសាដ្ឋាននៃសាលាឃុំ និងសមុហបញ្ជីនៃសាលដំបូងផង ។

បើទារកនោះកើតក្នុងប្រទេសដែលមានអត្រានុកូលដ្ឋាន ឬ ក្នុងបរទេសណាក៏ដោយឪពុកម្ដាយនៃទារក, កាលបើត្រូវគេដាក់កំហិតឲ្យបង្ហាញភស្តុតាងនូវបណ្ដឹងកំណើតកូនដែលបានប្ដឹងនោះអាចជូនកំណត់ដៃសញ្ញាប័ត្រតាមទម្រង់ដែលមានប្រើនៅប្រទេសនោះក៏បាន, ជូនសេចក្ដីចំឡងនៃសញ្ញាប័ត្រនោះដែលមានសេចក្ដីបញ្ជាក់ជាត្រឹមត្រូវប្រសិនបើឪពុកម្ដាយនោះបានសុំឲ្យចុះកំណើតរបស់កូនខ្លួនក្នុងបញ្ជីដែលភ្នាក់ងារទូត ឬ កុងស៊ុលនៃដែនជាមុខក្រសួងបានកាន់កាប់ ។

**មាត្រា ៥៤** ៖ ខ្មែរ ដែលកើតមុនមានបញ្ជីអត្រានុកូលដ្ឋានអាច នឹងធ្វើបុគ្គភាពរបស់ខ្លួនជាសំបុត្រ "ពង្សាវលី" ដែលមានសាក្សី ៣ នាក់ ជាមនុស្សគួរគេជឿបានមកបញ្ជាក់នៅមុខមេឃុំ តាមបែបដែលត្រូវធ្វើសំបុត្របានសេចក្ដីបញ្ជាក់នោះដែរ ។

បើបញ្ជីនោះគេមិនបានប្រើ ឬ បាត់ ឬ ខូចក៏ត្រូវធ្វើដូច្នេះដែរ ។

ក៏ប៉ុន្តែអ្នករាជការ, ភ្នាក់ងារ ឬ និយោជិតនៃក្រសួងរាជការផ្សេងជាអ្នកត្រូវបានបេឡាសោធន ឥណ្ឌាចិន ឬ សិទ្ធិវន្តនៃជនទាំងនោះធ្វើបញ្ជីជាតិរបស់ខ្លួនដែលមិនទាន់មានដោយហេតុដូចបានពោលទាំងពីរបែបខាងលើនេះឲ្យមានបានដោយសុំដល់ចាងហ្វាងសាលាដំបូងខាងទីកំណើតរបស់ខ្លួន, មិនមែនសុំមេឃុំទេ, ឲ្យចេញ Acte de notoriete tenant lieu d...cte d‶haissanceឲ្យ។ ក្នុងលិខិតនេះត្រូវឲ្យមានហត្ថលេខាក្រឡាបញ្ជីព្រមទាំងហត្ថលេខាសាក្សី ៣ នាក់ទៀតផង ។

## ផ្នែកទី ២
## អំពីមរណភាព សញ្ញាប័ត្រ

**មាត្រា ៥៥** ៖ (ព្រះរាជប្រកាសលេខ ៩៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ ១៩៣៧) កាលបើមានមរណភាពក្នុងឃុំឯណាមួយអ្នកដែលបានផ្តល់ដំណឹងត្រូវប្តឹង, បើយ៉ាងយឺតណាស់ ៣ ថ្ងៃដល់មន្ត្រីអត្រានុកូលដ្ឋាន ។ មន្ត្រីនេះត្រូវធ្វើកំណាត់ហេតុតាមបណ្តឹងនោះ ។ បើមានមរណភាពក្នុងគុក និងក្នុងមន្ទីររាជការសាធារណៈនោះត្រូវឆ្មាំនាយកគុក ឬ ចាងហ្វាងគុក ឬ ចាងហ្វាងទីនោះប្តឹង ។

**មាត្រ ៥៦** ៖ បើមន្ត្រីអត្រានុកូលដ្ឋានមិនបានចេញសំបុត្រធ្វើដោយក្រដាសលាតឥតថ្លៃឲ្យកប់នូវសពនោះទេ, ជនណានឹងយកទៅកប់មិនបាន ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវ អនុញ្ញាត្តិឲ្យកប់សពនោះក្រោយ ១២ ម៉ោងពីមរណៈដែលខ្លួនបានពិនិត្យដោយខ្លួនបាន ពិនិត្យដោយខ្លួនឯងឬជំទប់ពិនិត្យជួស ។

**មាត្រា ៥៧** ៖ អ្នកផងដែលបានប្រទះឃើញនូវសពណាមួយត្រូវប្ដឹងមន្ត្រីអត្រានុកូលដ្ឋានមួយរំពេច ។ មន្ត្រីនេះត្រូវទៅកាន់ទីកន្លែងនៃសពនោះ, សាកសួរពត៌មានឲ្យបានដឹងពីអត្តសញ្ញាណនៃសពហើយកត់ត្រាសេចក្ដីនោះក្នុងបញ្ជីមរណភាព ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ចែងឲ្យកប់នូវសពនោះផង ។ តែប្រសិនបើមានស្លាកស្នាមជាទីនាំឲ្យមានសេចក្ដីសង្ស័យអំពីហេតុដែលស្លាប់នៅ , មន្ត្រីនេះត្រូវប្ដឹងអាជ្ញាធររដ្ឋបាល និងតុលាការឲ្យចេញសំបុត្រអនុញ្ញាតឲ្យកប់ក្រោយដែលបានចាត់ការជាចាំបាច់ គឺឲ្យស៊ើបរកឈ្មោះអ្នកប្រព្រឹត្តនូវឃាតកម្មនោះ ។

**មាត្រា ៥៨** ៖ មរណៈភាពសញ្ញាប័ត្រនោះត្រូវប្រាប់ត្រកូល, ឈ្មោះ, របរ, ទីលំនៅ, ថ្ងៃដែលស្លាប់ ។ ឯថ្ងៃខែ និងទីកើត និងឈ្មោះឪពុកម្ដាយនៃខ្មោចបើដឹងក៏ឲ្យដាក់ផង ។

**មាត្រា ៥៩** ៖ នាកាលខ្មែរម្នាក់ស្លាប់ក្រៅលំនៅខ្លួនដែលធ្លាប់នៅ, មន្ត្រីអត្រានុកូលដ្ឋានដែលធ្វើមរណភាពសញ្ញាប័ត្រនៃជននោះត្រូវបញ្ជូន, កុំឲ្យយឺតយូរ, នូវ សេចក្ដីចំឡងមួយច្បាប់ទៅមន្ត្រីអត្រានុកូលខាងលំនៅសព ។ មន្ត្រីអត្រានុកូលដ្ឋាននេះ ចំឡងសេចក្ដីនោះដាក់ក្នុងបញ្ជីមរណភាពដែលខ្លួនកាន់រក្សា ។ បើមរណភាពបានមានហើយក្នុងដែនដីបរទេស ហើយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះបានធ្វើមរណភាពសញ្ញាប័ត្រ ដែលតាមទម្រង់ដែលគេប្រើក្នុងប្រទេសគេ, សញ្ញាប័ត្រនោះត្រូវទុកជាត្រឹមត្រូវដរាបដល់មានភស្តុតាងផ្ទុយ ឬ

ម្យ៉ាងទៀត, បើមានភាគីណាម្នាក់ដែលមានប្រយោជន៍ក្នុងរឿងនេះបានសុំឲ្យចុះមរណភាពនោះក្នុងបញ្ជីមរណភាពសញ្ញាប័ត្រ ដែលមានរក្សាទុកក្នុងអង្គទូត ឬកុងស៊ុលនៃដែនដីមានសមត្ថភាព, សេចក្ដីចំឡងនៃសញ្ញាប័ត្រនោះដែលមានសេចក្ដីបញ្ជាក់ជាត្រឹមត្រូវទុកជាបន្ទាល់បានដែរ ។

## ផ្នែកទី ៣
## អំពីអាពាហ៍ពិពាហ៍ សញ្ញាប័ត្រ

**មាត្រា ៦០** ៖ នាកាល ការដណ្ដឹងបានស្រេចហើយ, មេបាខាងប្រុស ខាងស្រីក៏បានសម្រេចថ្ងៃ. ខែ រៀបអាពាហ៍ពិពាហ៍ ហើយ, ឪពុក ឬម្ដាយខាងប្រុស ខាងស្រី ឬ អ្នកដែលជួសឪពុកម្ដាយត្រូវទៅប្ដឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំខាងស្រីអំពីអាពាហពិពាហនោះ ។

**មាត្រា ៦១** ៖ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើប្រកាសបិទនៅទ្វារសាលាឃុំដើម្បីផ្សាយភ្លាម ។

### ប្រកាសនោះត្រូវមានចុះ

១. ត្រកូល, ឈ្មោះ, អាយុ, របរ និងទីលំនៅនៃអនាគតប្ដី, នៃអនាគតប្រពន្ធម្នាក់ៗ ។

២. ត្រកូល, ឈ្មោះ, អាយុ, មុខរបរ និងទីលំនៅនៃឪពុកម្ដាយខាងប្រុសខាងស្រី, បើឪពុកឬម្ដាយស្លាប់ឲ្យដាក់ថាស្លាប់ផង

៣. ប្រពន្ធដែលនឹងរៀបការនោះមានខាន់ស្លាទីប៉ុន្មាន ។

ប្រកាសមួយច្បាប់ទៀតត្រូវមន្ត្រីអត្រានុកូលដ្ឋានបញ្ជូនទៅឲ្យមេឃុំខាងលំនៅនៃអនាគតប្តីប្រពន្ធឲ្យយកទៅបិទនៅទ្វារសាលាឃុំនោះភ្លាម ។

**មាត្រា ៦២** ៖ ប្រកាសនេះត្រូវបិទកំណត់ប្រាំបីថ្ងៃ ។ លុះផុតកំណត់នេះហើយទើបសាមីខ្លួនអាចរៀបការបាន ។

**មាត្រា ៦៣** ៖ មន្ត្រីអត្រានុកូលដ្ឋាន នាកាលបានទទួលបណ្តឹងទាស់ពីខាងណាហើយ, ត្រូវចុះសេចក្តីបណ្តឹងទាស់នោះយ៉ាងសង្ខេបលើប្រកាសនោះមួយរំពេច ។

**មាត្រា ៦៤** ៖ មន្ត្រីអត្រានុកូលដ្ឋានត្រូវឲ្យដំណឹងដំណឹងដល់អនាគតប្តីប្រពន្ធនោះអំពីបណ្តឹងទាស់ដែលខ្លួនបានទទួល ។ លុះតុលាការមានសមត្ថកិច្ចបានជំនុំជំរះបណ្តឹងទាស់នេះជ្រះស្រឡះ ហើយទើបមន្ត្រីអត្រានុកូលដ្ឋានអាចនឹងធ្វើអាពាហ៍ពិពាហ៍សញ្ញាប័ត្របាន, បើពុំដូច្នេះនោះទេ, មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវមានទោសដែលមានសញ្ញាប័ត្រក្នុងមាត្រា ៤៦ នៃក្រមនេះ ។

**មាត្រា ៦៥** ៖ នៅថ្ងៃដែលរៀបការ រួចស្រេចហើយ ប្តីប្រពន្ធថ្មីនេះត្រូវទៅប្តឹងមន្ត្រីអត្រានុកូលដ្ឋានជាថ្មីទៀត, មន្ត្រីនេះបើឥតមានបណ្តឹងទាស់ទៀតទេ, ត្រូវចុះអាពាហ៍ពិពាហ៍នោះ ក្នុងបញ្ជីអាពាហ៍ពិពាហ៍ព្រមទាំងពត៌មានដែលបានជូនហើយពីថ្ងៃមុនផង ។ មន្ត្រីនេះត្រូវឲ្យប្តីប្រពន្ធថ្មី, ឪពុកម្តាយ ឬ ជនណាដែលបានជំនួសឪពុកម្តាយនិងអ្នកមហា ឬ សាក្សី២នាក់ចុះហត្ថលេខា ។ បើអ្នកប្តឹង និងសាក្សីមិនចេះសរសេរ និងចុះហត្ថលេខា មិនកើត, ត្រូវឲ្យផ្តិតមេដៃកត់ថាជននោះ

ចុះហត្ថលេខាមិនកើតទេ ។ ក្នុងលំដាប់នោះ, មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាក្នុងបញ្ជីនោះផង ។

ការដែលប្រុស និងស្រីយកគ្នាជាប្ដីប្រពន្ធមិនបានប្ដឹងប្ដល់តាមច្បាប់នោះ មិនត្រូវឲ្យមានទោសជាបទអាជ្ញាឡើយ តែការដែលយកគ្នាឥតប្ដឹងប្ដល់នេះមិនមានលក្ខណៈជា ធម្មានុរូប ហើយមិនមានអានុភាពខាងផ្លូវច្បាប់ដែលកើតមកពីអាពាហ៍ពិពាហ៍នោះឡើយ។

**មាត្រា ៦៦** ៖ ជនខ្មែរណារៀបការក្រៅដែនកម្ពុជា, ក្នុងប្រទេសដែលពុំមានរបៀបអត្រានុកូលដ្ឋានទេ, ហើយមានប្រាថ្នាចង់ឲ្យសមគ្គសង្វាសនៃខ្លួនមានលក្ខណៈជាធម្មា នុរូប, ជនខ្មែរនោះត្រូវប្ដឹងមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំដែលខ្លួននឹងតាំងទីលំនៅនោះឲ្យចុះអាពាហ៍ពិពាហ៍សញ្ញាប័ត្រឲ្យ ។

បណ្ដឹងនោះត្រូវចុះត្រឹមថ្ងៃដែលប្ដឹងក្នុងបញ្ជីអាពាហ៍ពិពាហ៍ហើយប្ដីដែលប្ដឹង និងប្រពន្ធត្រូវចុះហត្ថលេខាផង ។ បើរៀបការក្នុងប្រទេសដែលមានរបៀបអត្រានុកូលដ្ឋានវិញ, ប្ដីប្រពន្ធមិនចាំបាច់ប្ដឹងដូច្នេះជាថ្មីដើម្បីឲ្យអាពាហ៍ពិពាហ៍របស់ខ្លួនមានលក្ខណៈជា ធម្មានុរូបឡើយ, ប្ដីប្រពន្ធនោះយកតែសេចក្ដីស្រង់នៃអាពាហ៍ពិពាហ៍ដែលបានធ្វើក្នុងប្រទេស នោះមកប្រើក៏គ្រប់គ្រាន់ហើយ ឬ សេចក្ដីចំឡងនៃសញ្ញាប័ត្រដែលបានចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៅអគ្គទូត ឬ នៅកុងស៊ុលជាមុខក្រសួងក៏បានដែរ ។

**មាត្រា ៦៧** ៖ ប្ដីប្រពន្ធដែលរៀបការ មុនកើតបញ្ជីអត្រានុកូលដ្ឋាន និងយក

ប័ណ្ណ ឬ សាក្សីជាបន្ទាល់ក៏បាន ។ នាកាលបញ្ជីនោះគឺគេមិនបានប្រើ ឬ បាត់ ឬ ខូចក៏ត្រូវបញ្ជាក់ដូច្នេះបានដូចគ្នាដែរ ។

**មាត្រា ៦៨** ៖ នាកាលនឹងរៀបខាន់ស្លា ផ្សេងទៀតក្រៅពីខាន់ស្លាទី១, អាពាហ៍ពិពាហ៍នោះក៏ត្រូវឲ្យប្តឹងមន្ត្រីអត្រានុកូលដ្ឋានជាមុខក្រសួងដូចគ្នាដែរ ។

**មាត្រា ៦៩** ៖ ក្នុងពេលវេលាដែលគូស្វាមីជនចូលមកប្តឹងចូលមកប្តឹងជាដំបូងអំពីខាន់ស្លារបស់ខ្លួន, មន្ត្រីអត្រានុកូលដ្ឋាន, មុននិងកត់ត្រា, ត្រូវសួរទៅគូស្វាមីជននិងសាក្សីនោះឲ្យដឹងប្តីនោះមានប្រពន្ធដើមហើយ ឬ ប្រពន្ធថ្មីនេះនៅជាប់អាពាហ៍ពិពាហ៍ពីមុនដែរសិនទើបត្រូវចុះសេចក្តីនោះក្នុងប្រកាសដែលត្រូវបិទផ្សាយនោះបាន ។

**មាត្រា ៧០** ៖ សាលក្រមដែលកាត់សេចក្តីឲ្យលែងគ្នា, ត្រូវមន្ត្រីអត្រានុកូលដ្ឋានកត់ដាក់ទៅរឹមទំព័រនៃអាពាហ៍ពិពាហ៍សញ្ញាប័ត្រតាមសេចក្តីដែលគូក្តីណាមួយសុំ ឬ ក៏តាមសេចក្តីសុំអំពីសមុហបញ្ជីក៏បាន ។

## ផ្នែកទី ៤
## បទបញ្ញត្តិពិសេស

**មាត្រា ៧១** ៖ បទល្មើសទាំងឡាយដែលមានបញ្ញត្តិក្នុងមាត្រា៤៥, ៤៦, ៦៤ និងត្រូវជំនុំជម្រះនៅសាលាមជ្ឈិម, ឯបទល្មើសដែលមានបញ្ញត្តិក្នុងមាត្រា៤៤ នឹងត្រូវជំនុំជម្រះជាបទលហុតាមបណ្តឹងរបស់ក្រសួងរដ្ឋបាល ឬ របស់សាមីជនទាំងឡាយបាន ។

# ឧបសម្ព័ន្ធទី៤ ៖

# អនុក្រឹត្យស្តីពី អគ្រានុកូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## អត្រានុកូលដ្ឋាន

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសឱ្យប្រើដោយក្រឹត្យ លេខ ៥៦ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

dec40

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.—**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និង និតិវិធី នៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.—**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និង ដែលបង្កើតឱ្យជននោះមានសិទ្ធិ និង ករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និង ជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្រមរណភាព ។

**មាត្រា ៣.—**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៤.—**

រាល់ការសុំចុះសៀវភៅអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នករាយការណ៍ និង ឬ សាក្សី និង ឬ សាមីខ្លួន ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និង សាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៥.—**

ទម្រង់បែបបទ និង សំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យឯកភាពគ្នាទូទាំងប្រទេស ។

គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.—**

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូនរដ្ឋមន្ត្រីព្រះបរមរាជវាំង ។

**មាត្រា ៧.—**

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

រាល់ការចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី ១០ នៃអនុក្រឹត្យនេះ ។

dec46

ɣ

## ជំពូកទី២
## អំពីមន្ត្រីអត្រានុកូលដ្ឋាន

**មាត្រា ៨.–**

មេឃុំ ឬ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។

នៅពេលដែលមេឃុំ ឬ ចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរឱ្យជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម និង រាយការណ៍ជូនអភិបាលស្រុក ឬ ខណ្ឌតាមផ្លូវការ ។

ក្នុងករណីមេឃុំ ឬ ចៅសង្កាត់អវត្តមានដោយស្លាប់ ឬ ដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬ ចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ជូនទៅជំទប់ ឬ ចៅសង្កាត់រង តាមឋានានុក្រម ។

**មាត្រា ៩.–**

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ៖

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬ សម្រង់ នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និង ធ្វើបុណ្យបូជា ឬ បញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និង បោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវឬបដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬ តាមបទប្បញ្ញត្តិ នៃច្បាប់
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និង ការគ្រប់គ្រង
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬ ខណ្ឌផ្ទាល់ ០១ច្បាប់ និង នៅតុលាការខេត្ត ឬ ក្រុងសាមី ០១ច្បាប់
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ ឱ្យបានយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬ សាលាខណ្ឌ សាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

dcc40

**មាត្រា ១០.-**

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និង សំបុត្រអត្រានុកូលដ្ឋានដូចការងារអត្រានុកូលដ្ឋាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

**មាត្រា ១១.-**

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ឱ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដោយជូនពត៌មានទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី៣
## អំពីសៀវភៅអត្រានុកូលដ្ឋាន

**មាត្រា ១២.-**

ក្នុងឃុំ ឬ សង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា០២ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និង ចុះលេខរៀងសន្លឹក ពីសន្លឹកទី១ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និង សន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និង ត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬ អភិបាលខណ្ឌ ។ សន្លឹកទី២ និង សន្លឹកដទៃទៀតអាចចុះហត្ថលេខាសង្ខេប និង បោះត្រារបស់អភិបាលស្រុក ឬ អភិបាលខណ្ឌគ្រប់សន្លឹក ។

**មាត្រា ១៣.-**

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវឱ្យមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ ។ បើមាន កោស ឆូត លុប ត្រូវទុកពាក្យទាំងនោះឱ្យនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និង យល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬ សាក្សី និង ឬ សាមីខ្លួនចុះហត្ថលេខា ឬ ផ្តិតមេដៃស្តាំទាំងអស់គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនឱ្យហែកចោលឡើយ ។

dec40

មាត្រា ១៤.-

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ច្បាប់ ទៅសាលាស្រុក ឬ ខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និង តម្កល់ទុកនៅទីនោះ និង បញ្ជូន ០១ច្បាប់ទៀតដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬ ក្រុងសាមី ដើម្បីមុខការតាមផ្លូវច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅ ស្ថានទូត ស្ថានអគ្គកុលស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៅខែ មករា ឆ្នាំ បន្ទាប់ មកតម្កល់ទុក ០១ច្បាប់ នៅក្រសួងមហាផ្ទៃ និង ០១ច្បាប់ទៀតមកតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

មាត្រា ១៥.-

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និង សំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានឱ្យបានល្អ និង រក្សាការសម្ងាត់ របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ ឬ សង្កាត់ណា ដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់នោះ ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬ ខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុក ឬ ខណ្ឌ ទៅតាមបែបបទដូចបានអនុវត្តនៅសាលាឃុំ ឬ សង្កាត់ ។

មាត្រា ១៦.-

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានឱ្យបានឯកភាពទូទាំងប្រទេស និង បណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និង ធានាផ្គត់ផ្គង់សៀវភៅ និង សំបុត្រអត្រានុកូលដ្ឋានឱ្យបានគ្រប់គ្រាន់ និង ទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី៤
## អំពីសំបុត្រកំណើត

មាត្រា ១៧.-

បើមានទារកកើត ឪពុក ឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃ ដោយបញ្ជាក់ឱ្យបានច្បាស់ថា ឪពុក និង ម្តាយនៃទារកនោះ មានខាន់ស្លា ឬ ឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតឱ្យទៅចុះសៀវភៅកំណើត ឱ្យបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និង ម្តាយទារកនោះជាប់ទៅជាមួយផង ។

dec40

**មាត្រា ១៨.—**

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬ អាច យកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្ដាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនឱ្យទារក ។

**មាត្រា ១៩.—**

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬ សង្កាត់ នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរក ឈ្មោះដាក់ឱ្យ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំកំណើតទារកដែលរើសបាននោះ ដោយស្មាន និង ឈ្មោះឪពុក ម្ដាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើស បាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រ កំណើតរបស់ទារកនោះ និង កំណត់ហេតុស្ដីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌល កុមារកំព្រា ។

**មាត្រា ២០.—**

ចំពោះទារក ឬ កុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារ កំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះ ត្រូវធ្វើសេចក្ដីរាយការណ៍ និង នាំទារក ឬ កុមារនោះ ទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌល នោះតាំងនៅ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានផ្ដល់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតឱ្យ ។

**មាត្រា ២១.—**

ការសុំទារក ឬ កុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និង ការសុំទារក ឬ កូនពីឪពុក ម្ដាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋាន ជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ២២.—**

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្ដាយ ឬ ឪពុក ។

**មាត្រា ២៣.—**

ទារកកើតពីឪពុក ម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេល ធ្វើសំបុត្រកំណើត បើឪពុក ម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះ

dcc40

មុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្ដាយ នោះថា ជាឪពុក ម្ដាយរបស់កូននោះ ។

ករណីមានតែឪពុក ឬ មានតែម្ដាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬ ម្ដាយបានប្ដឹងចុះក្នុងសៀវភៅកំណើត ឪពុក ឬ ម្ដាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្ដាយនោះ អាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្ដាយបានទទួលស្គាល់ នឹង ទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្ដាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា នឹង ពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

**មាត្រា ២៤.—**

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍ នូវសំបុត្រកំណើតច្បាប់ដើម ០១សន្លឹកទុកជាសម្គាល់ និង ចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២៥.—**

បើមានទារកកើតហើយ ទុកឱ្យហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្ដាយ ឬ អាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬ ម្ដាយ ឬ អាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្ដីណែនាំបន្ថែម ។

**មាត្រា ២៦.—**

ទារកកើតពីម្ដាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬ ពីឪពុកជាពលរដ្ឋខ្មែរ ម្ដាយជាជនបរទេស ឬ ពីឪពុកជាជនបរទេស ម្ដាយជាពលរដ្ឋខ្មែរ ឪពុក ម្ដាយ នៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញឱ្យ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មី ឱ្យយកទៅប្រើប្រាស់ ។

បើឪពុក ម្ដាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់ឱ្យនោះមកប្រើប្រាស់ជាផ្លូវការបាន ។

dec40

**មាត្រា ២៧.–**

ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬ អាចទៅចុះសៀវភៅកំណើតនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និង នាមផ្ទាល់ខ្លួន និង នាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី៥
## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨.–**

បុរស នារី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩.–**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និង នៅសាលាឃុំ ឬ សាលាសង្កាត់ នៃសាមីខ្លួននារី ០១ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និង បិទនៅសាលាឃុំ ឬ សង្កាត់ នៃសាមីខ្លួនបុរស ០១ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ ៖

១- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅនៃអនាគត ប្តី ប្រពន្ធ ។

២- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង លំនៅរបស់ ឪពុក ម្តាយ នៃអនាគត ប្តី ប្រពន្ធ បើឪពុក ឬ ម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ ។

៣- រយៈពេលប្តឹងជំទាស់

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ ។ ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។ បើមានបណ្តឹងជំទាស់ នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់ ។

dec40

៥

**មាត្រា ៣០.–**

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និង នារី ដែលស្ម័គ្រចិត្ត ទទួលគ្នាជា ប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និង ផ្តិតមេដៃ ប្តី ប្រពន្ធ និង សាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

**មាត្រា ៣១.–**

ពេលសាមីខ្លួនជាអនាគត ប្តី និង ប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៣២.–**

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ ឬ រវាងពលរដ្ឋខ្មែរ និង ជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូភាគីមានទីលំនៅ ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ និង អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេស នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬ បើប្តី ប្រពន្ធមកតាំងលំនៅ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍ នៅសាលាឃុំ. ឬ សង្កាត់ ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ឬ មន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ពិពាហ៍ថ្មី ឱ្យទៅជននោះយកទៅប្រើប្រាស់ ។

**មាត្រា ៣៣.–**

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ជនបរទេស ឬ ជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.–**

ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬ ជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ ពីទីកន្លែង និង ពេលវេលា ដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះឱ្យបានច្បាស់ ។

dec40

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬ សុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់ព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី៦
## អំពីសំបុត្រមរណភាព

**មាត្រា ៣៥.—**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ច នៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់ របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬ បញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬ ដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬ ផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬ ផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬ បញ្ចុះសពតាមការសម្រេចនោះ ។

**មាត្រា ៣៦.—**

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ពន្ធ័ដល់ការមន្ទិលសង្ស័យ ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬ ជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និង ដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬ បញ្ចុះសពបាន ។

**មាត្រា ៣៧.—**

បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬ សង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬ សង្កាត់ផ្សេង មន្ត្រីអត្រានុកូល-ដ្ឋាននៃឃុំ ឬ សង្កាត់ ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់របស់អ្នកស្លាប់រស់នៅ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឱ្យទៅយកសពធ្វើបុណ្យ និង ចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬ គ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវចាត់ចែងបូជា ឬ បញ្ចុះសពនោះ និង ចុះសៀវភៅមរណភាពក្នុងឃុំ ឬ សង្កាត់នោះ។

**មាត្រា ៣៨.-**

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

**មាត្រា ៣៩.-**

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាព រួចប្រគល់ឱ្យអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៤០.-**

បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត -ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

**មាត្រា ៤១.-**

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬ សង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់ឱ្យសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញអាចយកសំបុត្រមរណ៍ភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ៤២.-**

ជនអន្តោប្រវេសន៍ និង ជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬ អ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬ អាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។

បើចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ។

dec40

## ជំពូកទី៧
## អំពីសំបុត្របញ្ជាក់កំណើត

**មាត្រា ៤៣.–**

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់កំណើតបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជននិងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និង ធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃខែឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។

**មាត្រា ៤៤.–**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់ឱ្យសាមីខ្លួន ឬ ក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី៨
## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

**មាត្រា ៤៥.–**

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬ ប្រពន្ធពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និង ជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះនិងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៦.–**

ពេលមានសាមីខ្លួនប្តី និង ប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ។

dec40

## ជំពូកទី៩
## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧.-**

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលមានអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬ សង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២រូប ជានីតិជន និង ជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮ ផ្ទាល់អំពីការស្លាប់ និង ធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨.-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់ឱ្យអ្នកមកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី១០
## អំពីសេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋាន

**មាត្រា ៤៩.-**

សេចក្តីចម្លង ឬ សម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និង សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នានឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន។

**មាត្រា ៥០.-**

បើមានអ្នកមកសុំចម្លង ឬ សុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬ សម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រានុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និង កំពុងថែរក្សាក្នុងឆ្នាំដែលមិនទាន់ដាច់ នៅសាលាឃុំ ឬ សាលាសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្តីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ទើបធ្វើការចម្លង ឬ សម្រង់ចេញពីសន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំមាន ហើយយកទៅប្រើការបាន ។

dec40

**មាត្រា ៥១.–**

ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សុំស្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬ ខណ្ឌ និង បោះត្រាផង ។

**មាត្រា ៥២.–**

ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សុំស្រង់នៅសាលាស្រុក ឬ ខណ្ឌ ឬ នៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬ សម្រង់នៅសាលាស្រុក ឬ សាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូល-ដ្ឋាន និង ត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬ ខណ្ឌ និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់នៅតុលាការខេត្ត ក្រុងត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និង ត្រូវបញ្ជាក់ហត្ថលេខានោះ ដោយប្រធានតុលាការ ឬ ចៅក្រមជំនួស និង បោះត្រាផង ។

**មាត្រា ៥៣.–**

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូល-ដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬ កុងស៊ុល និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬ សុំស្រង់នៅក្រសួងមហាផ្ទៃ ឬ នៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី១១

## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់ ស្ដីពីការចារអត្រានុកូលដ្ឋាន

**មាត្រា ៥៤.–**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬ សាក្សី ត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួន អំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្ដីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥.–**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់មានការឃុបឃិត ឬ ក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

dec40

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ នឹងប្តឹងទៅតុលាការ ដើម្បីបដិសេធ និង សុំផ្តន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២
## អំពីថវិកា អត្រានុកូលដ្ឋាន

**មាត្រា ៥៦.–**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង ការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧.–**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង ការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨.–**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និង ការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និង ថ្លៃបិទតែមប្រ៊ី ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬ សង្កាត់ និង ចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និង ថ្លៃតែមប្រ៊ីត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី១៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៩.–**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះ សៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតឱ្យប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**មាត្រា ៦០.–**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ផ្សេងទៀត ។

dec40

មាត្រា ៦១.–

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និង អត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៨ ហើយរក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន តាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

មាត្រា ៦២.–

ក្នុងករណីដែលពិនិត្យឃើញសំបុត្រអត្រានុកូលដ្ឋានចាស់ពីមុនណាមួយ ដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋាននោះមកវិញ រួចណែនាំឱ្យសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

មាត្រា ៦៣.–

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និង នៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី១៤
## អំពីទោសប្បញ្ញត្តិ

មាត្រា ៦៤.–

ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី ០១ដង នៅទីកន្លែងដដែល ឬ ទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

មាត្រា ៦៥.–

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋ ដែលមកសុំ ឬ បានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

មាត្រា ៦៦.–

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី.២៩.ខែ...ធ្នូ...ឆ្នាំ២០០០*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ស ខេង** **យូ ហុកគ្រី** **អ៊ុក វ៉ីធុន**

<u>**ចម្លងជូន**</u>

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦៧*
- *កាលប្បវត្តិ- ឯកសារ*

dec40

# ឧបសម្ព័ន្ធទី៥ ៖

# អនុក្រឹត្យស្តីពី ការបង្កើត

# អគ្គនាយកដ្ឋានអគ្គសញ្ញាណកម្ម

# ចំណុះក្រសួងមហាផ្ទៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យ លេខ១៥៨អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រាមួយ._**

មាត្រា៥ នៃអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ ត្រូវបានកែសម្រួលដូចតទៅៈ

**មាត្រា ៥._ថ្មី**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មមានរចនាសម្ព័ន្ធ ដូចតទៅៈ

១.នាយកដ្ឋានរដ្ឋបាលសរុប

២.នាយកដ្ឋានអត្រានុកូលដ្ឋាន

៣.នាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៤.នាយកដ្ឋានលិខិតឆ្លងដែន

៥.នាយកដ្ឋានសញ្ជាតិ

៦.នាយកដ្ឋានស្ថិតិប្រជាពលរដ្ឋ

៧.នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៣០២៤ ប្រក

# ប្រកាស

# ស្តីពី

# រចនាសម្ព័ន្ធនាយកដ្ឋានអត្រានុកូលដ្ឋាន និងតួនាទី ភារកិច្ចរបស់ការិយាល័យចំណុះ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា៥ នៃអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំណុះក្រសួងមហាផ្ទៃ។
- យោងតាមសំណើរបស់ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់អំពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន និងតួនាទី ភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋានអត្រានុកូលដ្ឋាន។

**ប្រការ ២.-**

*នាយកដ្ឋានអត្រានុកូលដ្ឋាន មានរចនាសម្ព័ន្ធដូចខាងក្រោម:*

១- ការិយាល័យ រដ្ឋបាល-សរុប

២- ការិយាល័យ កិច្ចការច្បាប់

៣- ការិយាល័យ ត្រួតពិនិត្យនិងគាំទ្រកិច្ចការអត្រានុកូលដ្ឋាន

៤- ការិយាល័យ អភិវឌ្ឍន៍សមត្ថភាព

៥- ការិយាល័យ អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស

៦- ការិយាល័យ គ្រប់គ្រងទិន្នន័យអត្រានុកូលដ្ឋាន

**ប្រការ ៣.-**

*ការិយាល័យរដ្ឋបាល-សរុប មានតួនាទីភារកិច្ច:*

ធ្វើជាសេនាធិការជូននាយកដ្ឋាន លើការងាររដ្ឋបាល ការកសាងផែនការ កម្មវិធីការងារ ការងារកស្ដុការ គណនេយ្យ ការងារគ្រប់គ្រងឯកសារ ការងារពិធីការ និងមានភារកិច្ចដូចតទៅ៖

- សម្របសម្រួលរៀបចំផែនការ សកម្មភាព ថវិកា និងទិសដៅអនុវត្តការងារប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ចាត់ចែងមធ្យោបាយ សង្ហារិម សម្ភារ ថវិកា និងបរិក្ខារផ្សេងៗរបស់នាយកដ្ឋាន
- ធ្វើការងារកស្ដុការ គណនេយ្យរបស់នាយកដ្ឋាន
- គ្រប់គ្រង ប្រមូល និងចាត់ចែងចំណូលពីការងារអត្រានុកូលដ្ឋាន តាមការកំណត់
- រៀបចំប្រតិទិនការងារ និងកាលវិភាគកិច្ចប្រជុំរបស់នាយកដ្ឋាន
- លើកសំណើគម្រោងតម្រូវការថវិកាសម្រាប់បោះពុម្ពសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋាន
- គ្រប់គ្រង បែងចែកសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋាន
- ទទួលការងាររបៀប លិខិតស្នាមចូល ចេញ លេខហារី មធ្យោបាយទំនាក់ទំនងផ្សេងៗ និងថតចម្លងឯកសារ និងលិខិតបញ្ញាបេសកកម្ម
- តម្កល់ទុកឯកសាររដ្ឋបាលរបស់នាយកដ្ឋាន ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគោលការណ៍ណែនាំ និងឯកសារផ្សេងៗទៀត
- ទទួលកិច្ចការទំនាក់ទំនងសាធារណៈនិងបដិសណ្ឋារកិច្ច
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំថ្ងៃ សប្ដាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤.-**

*ការិយាល័យកិច្ចការច្បាប់ មានតួនាទី ភារកិច្ចៈ*

ធ្វើជាសេនាធិការជូននាយកដ្ឋាន លើការងារកសាងលិខិតបទដ្ឋានគតិយុត្តនានា ការងារស្រាវជ្រាវបណ្តឹងពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន និងមានភារកិច្ចដូចតទៅ ៖

- សិក្សាស្រាវជ្រាវ ផ្តួចផ្តើមរៀបចំ និងកែសម្រួល ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានតាមការចាំបាច់
- សិក្សាស្រាវជ្រាវ និងលើកយោបល់ដោះស្រាយលើរាល់បណ្តឹង ព័ត៌មានពីសកម្មភាព និងបញ្ហាមិនប្រក្រតីនានាពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន
- សហការអប់រំ ផ្សព្វផ្សាយជាសាធារណៈអំពីសារៈសំខាន់នៃសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ
- រៀបចំលើកសំណើផែនការ សកម្មភាព ថវិកា និងទិសដៅអនុវត្តការងារប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនិងទិសដៅការងារប្រចាំថ្ងៃ សប្តាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ប្រចាំឆ្នាំរបស់ការិយាល័យ ជូននាយកដ្ឋានតាមរបបកំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៥.-**

*ការិយាល័យត្រួតពិនិត្យនិងគាំទ្រកិច្ចការអត្រានុកូលដ្ឋាន មានតួនាទី ភារកិច្ចៈ*

ធ្វើជាសេនាធិការជូននាយកដ្ឋាន លើការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃកិច្ចការអត្រានុកូល-ដ្ឋាន និងមានភារកិច្ចដូចតទៅ ៖

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តការងារអត្រានុកូលដ្ឋាននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ប្រមូលរបាយការណ៍ស្តីពីការងារអត្តសញ្ញាណកម្ម តាមរយៈប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ជូននាយកដ្ឋានរដ្ឋបាល-សរុប
- ធ្វើការវិភាគលើស្ថានភាពកំណើត អាពាហ៍ពិពាហ៍ មរណភាព និងរៀបចំសំណើគម្រោងផ្សេងៗ
- ត្រួតពិនិត្យសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តដោយមន្ត្រីអត្រានុកូលដ្ឋាន
- ចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រ និងជំរុញការអនុវត្តការងារអត្រានុកូលដ្ឋាន
- រៀបចំលើកសំណើផែនការ សកម្មភាព ថវិកា និងទិសដៅអនុវត្តការងារប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនិងទិសដៅការងារប្រចាំថ្ងៃ សប្តាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ប្រចាំឆ្នាំរបស់ការិយាល័យ ជូននាយកដ្ឋានតាមរបបកំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៦.-**

*ការិយាល័យអភិវឌ្ឍន៍សមត្ថភាពមានតួនាទី ភារកិច្ច:*

ធ្វើជាសេនាធិការជូននាយកដ្ឋាន លើការងារអភិវឌ្ឍន៍សមត្ថភាព ការងារគ្រប់គ្រងបុគ្គលិក និង មានភារកិច្ចដូចតទៅ ៖

- ធ្វើការសិក្សាវាយតម្លៃ និងកំណត់តម្រូវការបណ្តុះបណ្តាល ស្តីពីការងារអត្រានុកូលដ្ឋាន
- រៀបចំកម្មវិធីបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋានដល់មន្ត្រីទទួលបន្ទុកកិច្ចការអត្រានុកូលដ្ឋាន និង មន្ត្រីអត្រានុកូលដ្ឋាននៅទូទាំងប្រទេស
- ធ្វើការវាយតម្លៃសមត្ថភាពមន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាន និងស្មៀនឃុំ សង្កាត់
- ជួយអន្តរាគមន៍ និងគាំទ្រសមត្ថភាពដល់មន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាន និងស្មៀនឃុំ សង្កាត់
- លើកសំណើតែងតាំង តម្លើងឋានៈ ឋានន្តរសក្តិ លើកសរសើរ ដាក់វិន័យមន្ត្រីចំណុះនាយកដ្ឋាន
- ចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធនានា អំពីកិច្ចការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការងារអត្រា នុកូលដ្ឋាន
- រៀបចំលើកសំណើផែនការ សកម្មភាព ថវិកា និងទិសដៅអនុវត្តការងារប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនិងទិសដៅការងារប្រចាំថ្ងៃ សប្តាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ប្រចាំឆ្នាំរបស់ការិយាល័យ ជូននាយកដ្ឋានតាមរបបកំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៧.-**

*ការិយាល័យអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស មានតួនាទី ភារកិច្ច:*

ធ្វើជាសេនាធិការជូននាយកដ្ឋានលើការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស និង មានភារកិច្ចដូចតទៅ ៖

- ពិនិត្យសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស រួមសហការជាមួយអង្គភាពពាក់ព័ន្ធពិនិត្យសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- ចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសដែលបានផ្ញើមកពីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ទៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងជូនដំណឹងព្រមទាំងប្រគល់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ ទៅសាមីខ្លួនជនបរទេស និងសាមីខ្លួនពលរដ្ឋខ្មែរ ដើម្បីសាមីខ្លួនដាក់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋាន អចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

- ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍
- រៀបចំលើកសំណើផែនការ សកម្មភាព ថវិកា និងទិសដៅអនុវត្តការងាររបស់ការិយាល័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផល និងទិសដៅការងារប្រចាំថ្ងៃ សប្តាហ៍ អឌ្ឍមាស ខែ ត្រីមាស ឆមាស ប្រចាំឆ្នាំរបស់ការិយាល័យ ជូននាយកដ្ឋានតាមរបបកំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៨.-**

*ការិយាល័យគ្រប់គ្រងទិន្នន័យអត្រានុកូលដ្ឋាន មានតួនាទី ភារកិច្ចៈ*

ធ្វើជាសេនាធិការជូន នាយកដ្ឋានលើការងារគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធបញ្ចូលទិន្នន័យ អត្រានុកូលដ្ឋានតាមបច្ចេកវិទ្យាព័ត៌មានវិទ្យា និងមានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រង រៀបចំការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសហការរៀបចំឲ្យមានលេខអត្តសញ្ញាណផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ
- រៀបចំសំណើគម្រោងតម្រូវការថវិកាសម្រាប់ចំណាយលើការងារបញ្ចូលទិន្នន័យ ការដឹកជញ្ជូន ថែទាំ ជួសជុល និងផ្លាស់ប្តូរសម្ភារៈបរិក្ខារបច្ចេកទេសផ្សេងៗសម្រាប់បម្រើឲ្យការងារអត្រានុកូលដ្ឋាន
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ការងារអត្រានុកូលដ្ឋានស្របតាមប្រព័ន្ធបច្ចេកវិទ្យាស្តង់ដារ និងទិន្នន័យរួមរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- គ្រប់គ្រង និងថែរក្សាសៀវភៅអត្រានុកូលដ្ឋាន
- សហការកសាងផែនការប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការពារហានិភ័យផ្សេងៗទៀត ដើម្បីការពារសន្តិសុខ សុវត្ថិភាពប្រព័ន្ធ និងទិន្នន័យនៃអត្រានុកូលដ្ឋាន
- កែតម្រូវទិន្នន័យផ្លូវការ តាមការសម្រេចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- សហការបណ្តុះបណ្តាលការងារបច្ចេកទេសព័ត៌មានវិទ្យាដល់មន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋាន
- តាមដាន ត្រួតពិនិត្យលើការងារបច្ចេកវិទ្យាព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន
- ពិនិត្យនីត្យានុកូលភាពនៃឯកសារអត្រានុកូលដ្ឋាន និងចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធនានាលើការងារព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន
- រៀបចំលើកសំណើផែនការ សកម្មភាព ថវិកា និងទិសដៅអនុវត្តការងារប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផល និងទិសដៅការងាររបស់ការិយាល័យតាមរបបកំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៩.-**

ការិយាល័យនីមួយៗដឹកនាំដោយប្រធានម្នាក់ និងមានអនុប្រធានការិយាល័យមួយចំនួនជាជំនួយ។

រចនាសម្ព័ន្ធរបស់ការិយាល័យនិងតួនាទីភារកិច្ចរបស់ផ្នែកនីមួយៗ ចំណុះការិយាល័យរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

**ប្រការ ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១១.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការនគរបាលជាតិ អគ្គនាយកនៃអគ្គ-នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត-ក្រុង ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

## រចនាសម្ព័ន្ធ នាយកដ្ឋានអន្តោប្រវេសន៍

**នាយកដ្ឋានអន្តោប្រវេសន៍**

- ការិយាល័យ រដ្ឋបាលសរុប
- ការិយាល័យ កិច្ចការច្បាប់
- ការិយាល័យ ត្រួតពិនិត្យ និងគាំទ្រកិច្ចការអន្តោប្រវេសន៍
- ការិយាល័យ អភិវឌ្ឍន៍សមត្ថភាព
- ការិយាល័យ អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- ការិយាល័យ គ្រប់គ្រងទិន្នន័យអន្តោប្រវេសន៍

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

# ឧបសម្ព័ន្ធទី៦ ៖

# របាយការណ៍បូកសរុបលទ្ធផល
# ការងាររបស់នាយកដ្ឋាន
# អគ្គានុកូលដ្ឋាន នៃអគ្គនាយកដ្ឋាន
# អត្តសញ្ញាណកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
នាយកដ្ឋានអត្រានុកូលដ្ឋាន
លេខ:០១៥ ណ.អ.ក.អ.ត

ថ្ងៃ អង្គារ ៣ កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០២០

# របាយការណ៍
## បូកសរុបលទ្ធផលការងារឆមាសទី១
(គិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០)
**របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សម្រាប់ឆ្នាំ២០២០**

## I. លទ្ធផលការងារ

### ១.១. លទ្ធផលជាក់ស្តែង

-បានទទួលសាលក្រម និងដីកាសម្រេច ពីសាលាដំបូងរាជធានី ខេត្ត សរុបចំនួន៤៦៨ច្បាប់

| ល.រ | សាលាដំបូងរាជធានី ខេត្ត | ចំនួន | | ល.រ | សាលាដំបូងរាជធានី ខេត្ត | ចំនួន |
|---|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ១៤០ | | ១១ | ខេត្តកំពត | ៨ |
| ២ | ខេត្តកណ្តាល | ៨៩ | | ១២ | ខេត្តស្វាយរៀង | ៧ |
| ៣ | ខេត្តបន្ទាយមានជ័យ | ៦៧ | | ១៣ | ខេត្តបាត់ដំបង | ៤ |
| ៤ | ខេត្តកំពង់ស្ពឺ | ៣៦ | | ១៤ | ខេត្តកំពង់ធំ | ៤ |
| ៥ | ខេត្តតាកែវ | ៣០ | | ១៥ | ខេត្តកោះកុង | ៤ |
| ៦ | ខេត្តប៉ៃលិន | ២០ | | ១៦ | ខេត្តពោធិ៍សាត់ | ៣ |
| ៧ | ខេត្តកំពង់ចាម | ១៣ | | ១៧ | ខេត្តត្បូងឃ្មុំ | ៣ |
| ៨ | ខេត្តព្រៃវែង | ១៣ | | ១៨ | ខេត្តឧត្តរមានជ័យ | ២ |
| ៩ | ខេត្តក្រចេះ | ១២ | | ១៩ | ខេត្តសៀមរាប | ១ |
| ១០ | ខេត្តព្រះវិហារ | ១១ | | ២០ | ខេត្តកំពង់ឆ្នាំង | ១ |

-នាយកដ្ឋានបានទទួលពាក្យស្នើសុំកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានសរុបចំនួន ៧,៣៧១ច្បាប់ (នៅសល់៣០៦ច្បាប់) ក្នុងនោះនាយកដ្ឋានបានទទួលពីប្រជាពលរដ្ឋដែលមកដាក់ពាក្យដោយផ្ទាល់នៅនាយកដ្ឋានចំនួន ៥,១០១ច្បាប់ និងពីរដ្ឋបាលរាជធានី ខេត្ត ចំនួន ២,២៧០ច្បាប់

-នាយកដ្ឋានបានសម្រេចលើកយោបល់ស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សរុបចំនួន ៧,២៥៦ច្បាប់

-បានទទួលសេចក្តីសម្រេចស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានពី ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ សរុបចំនួន៧,២៦៣ច្បាប់

-នាយកដ្ឋានបានទទួលពាក្យស្នើសុំកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានពាក់ព័ន្ធសេចក្តីណែនាំលេខ០១៥សណន ស្តីពីការចេញលិខិតរដ្ឋបាល និងលិខិតអត្រានុកូលដ្ឋាន

ឱ្យសហព័ន្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន្តចំនួន ២០ច្បាប់ ក្នុងនោះសម្រេចបាន៣២ច្បាប់ បូកយោងក្នុងខែកន្លងមកនៅសល់០៣ច្បាប់ នាយកដ្ឋានបន្តចាត់ចែងតាមនីតិវិធី

-បានចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋសរុបចំនួន២,៤៩៤ច្បាប់ ស្មើនឹង ១៥,៩៤១សន្លឹក ក្នុងនោះរួមមាន៖

| | |
|---|---|
| ១-សេចក្តីចម្លងសំបុត្រកំណើត | ចំនួន២១៣ច្បាប់ ស្មើនឹង ១,១១៦សន្លឹក |
| ២-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ចំនួន២,១៤៩ច្បាប់ ស្មើនឹង១៣,៧២៩សន្លឹក |
| ៣-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ចំនួន១១៧ច្បាប់ ស្មើនឹង ៩៩១សន្លឹក |
| ៤-សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ចំនួន១៣ច្បាប់ ស្មើនឹង ៧៥សន្លឹក |
| ៥-សេចក្តីចម្លងសំបុត្រមរណភាព | ចំនួន០២ច្បាប់ ស្មើនឹង ២៧សន្លឹក |

-បានថតចម្លងគល់បញ្ជីតាមការស្នើរបស់ប្រជាពលរដ្ឋសម្រាប់ចេញសេចក្តីចម្លងសំបុត្រអត្រា-នុកូលដ្ឋានគ្រប់ប្រភេទ និងសម្រាប់ធ្វើការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន សរុបចំនួន ១១,៧៨១ច្បាប់

-បានស្កេន (scan) សៀវភៅអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើតរបស់ខេត្តបាត់ដំបង បានចំនួន២២៧ក្បាល ស្មើនឹង ២១,០២១បញ្ជី

-បានកិបភ្ជាប់ និងកែតម្រូវបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមសាលក្រម និងសេចក្តីសម្រេចស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានចំនួន២,៧៩១ច្បាប់

-បានដឹកសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួច ពីខេត្តក្រចេះ កោះកុង ស្វាយរៀង និងខេត្តព្រះសីហនុ មករក្សាទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានចំនួន ២,៤២៨ក្បាល

-បានបើកសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៣០,៣៤៧ក្បាល និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៤,០១០,៥០០សន្លឹក ដល់រដ្ឋបាលរាជធានី-ខេត្តចំនួន២៣ហើយ នៅសល់តែខេត្តកំពង់ចាម និងខេត្តកែប ប៉ុណ្ណោះដែលមិនទាន់បានបើកផ្តល់

-បានរៀបចំសំណើសុំគោលការណ៍ និងចុះបញ្ជីអត្រានុកូលដ្ឋានកំណើតជូនកូនជនបរទេស ដែលកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា លើស៣០ថ្ងៃ បានចំនួន០៧នាក់

-បានរៀបចំសំណើសុំគោលការណ៍ និងចុះបញ្ជីអត្រានុកូលដ្ឋានកំណើតជូនពលរដ្ឋខ្មែរ និងនិវត្តជន ពីសហរដ្ឋអាមេរិក បានចំនួន៣៨នាក់

-បានចុះគាំទ្រ តាមដាន និងត្រួតពិនិត្យការអនុវត្តការងារអត្រានុកូលដ្ឋាន ចំនួន០៥រាជធានីខេត្ត ក្នុងនោះមាន៖ រាជធានីភ្នំពេញ ខេត្តកណ្តាល មណ្ឌលគិរី ព្រះវិហារ និងខេត្តតាកែវ

-បានចុះស្រាវជ្រាវសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ តាមការស្នើសុំរបស់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ចំនួន១២រាជធានី ខេត្ត ស្មើនឹង២៦ករណី ដែលមានដូចជា៖ រាជធានីភ្នំពេញ ខេត្តព្រះវិហារ ស្វាយរៀង តាកែវ កំពង់ស្ពឺ ត្បូងឃ្មុំ កំពត មណ្ឌលគិរី ព្រៃវែង កណ្តាល កំពង់ធំ និងខេត្តកោះកុង

-បានទទួលសំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស សរុបបាន ចំនួន៦២៦ច្បាប់

-បានលើកយោបល់ ករណីការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យសម្រេច សរុបចំនួន៧០១ច្បាប់ ដែលមាន២៧សញ្ជាតិ ដូចជា៖

| ល.រ | សញ្ជាតិ | ចំនួន (ច្បាប់) | | ល.រ | សញ្ជាតិ | ចំនួន(ច្បាប់) |
|---|---|---|---|---|---|---|
| ១ | ចិន | ២៣៦ | | ១៥ | ហ្វីលីពីន | ០៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | កូរ៉េ | ១៨៦ | | ១៦ | អូទ្រីស | ០២ |
| ៣ | អាមេរិក | ១៥១ | | ១៧ | អ៊ីរ៉ាក់ | ០២ |
| ៤ | បារាំង | ២២ | | ១៨ | ស៊ុយអែត | ០២ |
| ៥ | កាណាដា | ២១ | | ១៩ | វៀតណាម | ០១ |
| ៦ | អូស្ត្រាលី | ១៩ | | ២០ | ហ្វាំងឡង់ | ០១ |
| ៧ | ម៉ាឡេស៊ី | ១៥ | | ២១ | អាល្លឺម៉ង់ | ០១ |
| ៨ | ជប៉ុន | ១០ | | ២២ | នីហ្សេរីយ៉ា | ០១ |
| ៩ | ឥណ្ឌូនេស៊ី | ០៦ | | ២៣ | អេស្ប៉ាញ | ០១ |
| ១០ | អង់គ្លេស | ០៤ | | ២៤ | ឥណ្ឌា | ០១ |
| ១១ | ញូហ្ស៊ីឡែន | ០៤ | | ២៥ | ឡាវ | ០១ |
| ១២ | ថៃ | ០៣ | | ២៦ | គុយបា | ០១ |
| ១៣ | ហុងគ្រី | ០៣ | | ២៧ | រុស្ស៊ី | ០១ |
| ១៤ | អ៊ីតាលី | ០៣ | | | | |

-គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ រាជធានី ខេត្តទាំង ២៥ បានផ្ញើរបាយការណ៍ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទមកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សរុបចុះបញ្ជីចំនួន៣១៥,៨៦៣នាក់ (ស្រី១៥៤,៥៤២នាក់) ក្នុងនោះរួមមាន៖

១-បញ្ជីកំណើត ចំនួន ៨៦,៦៣៩នាក់(ស្រី៤១,៧៧៧នាក់)

២-បញ្ជីបញ្ជាក់កំណើត ចំនួន ១១០,៤២២នាក់ (ស្រី ៥៤,៥៧១នាក់)

៣-បញ្ជីអាពាហ៍ពិពាហ៍រវាងខ្មែរ និងខ្មែរ ចំនួន ៤៨,៧០២គូ

៤-បញ្ជីអាពាហ៍ពិពាហ៍រវាងខ្មែរ និងបរទេស ចំនួន ៦០៨គូ

៥-បញ្ជីមរណភាព ចំនួន ២០,១៨២នាក់ (ស្រី ៨,៧៨៥នាក់)

-គិតចាប់ពីឆ្នាំ២០០២ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ រាជធានី ខេត្តទាំង២៥ បានផ្ញើរបាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន គ្រប់ប្រភេទមកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សរុបចុះបញ្ជីចំនួន ១៩,១៦៨,៦៥២នាក់ ស្រីចំនួន ៩,១២៨,៩៧២នាក់ ក្នុងនោះមាន៖

| ល.រ | បញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | បញ្ជីកំណើត | ២,៩៩៥,៤៤៩នាក់ | ស្រី ១,១១៩,៩៣៣នាក់ |
| ២ | បញ្ជីបញ្ជាក់កំណើត | ១៤,២៦១,៨៨៨នាក់ | ស្រី ៧,០៨៥,៩៩៧នាក់ |
| ៣ | បញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ | ១១៦,១៤៨គូ | ស្រី ១១៦,១៤៨នាក់ |
| ៤ | អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងខ្មែរ | ៦៥៨,៧៤០គូ | ស្រី ៦៥៨,៧៤០នាក់ |
| ៥ | អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស | ១០,១៨៧គូ | ស្រី ១០,១៨៧នាក់ |
| ៦ | បញ្ជីបញ្ជាក់មរណភាព | ១៣,២៥០នាក់ | ស្រី ៤,១១៣នាក់ |
| ៧ | បញ្ជីមរណភាព | ៣២៧,៤៥៣នាក់ | ស្រី ១៣៣,៨៥៤នាក់ |
| ៨ | កំណើតជនបរទេស | ១៧៩នាក់ | |

| | | | |
|---|---|---|---|
| ៩ | អាពាហ៍ពិពាហ៍ជនបរទេស | ៣៦គូ | |
| ១០ | មរណភាពជនបរទេស | ២១១នាក់ | |

-រដ្ឋបាលថ្នាក់ក្រោមជាតិបានចុះបញ្ជីអត្រានុកូលដ្ឋានកំណើត ជូនប្រជាពលរដ្ឋដល់មណ្ឌលសុខភាព បានចំនួន៩៥ នាក់ និងតាមខ្នងផ្ទះបានចំនួន២២៦នាក់ បញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ បានចំនួន៥៩ គូ និងបញ្ជីមរណភាពបានចំនួន៨៤នាក់។ កិច្ចការនេះអនុវត្តដោយខេត្តកំពង់ចាម កណ្តាល ប៉ៃលិន បាត់ដំបង តាកែវ ស្វាយរៀង កំពង់ធំ ក្រចេះ សៀមរាប ព្រៃវែង កំពង់ឆ្នាំង និងខេត្តត្បូងឃ្មុំ។

II. **បញ្ហាប្រឈម**

-មន្ត្រីបម្រើការងារនៅនាយកដ្ឋានអត្រានុកូលដ្ឋាននៅមានចំនួនតិចនៅឡើយ

-ខ្វះថវិកាសម្រាប់ថែទាំជួសជុលសម្ភារៈបរិក្ខា និងបច្ចេកទេសផ្សេងៗ

-មន្ត្រីអនុវត្តការងារអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួនមានការផ្លាស់ប្តូរញឹកញាប់ ជាហេតុនាំឱ្យមានកំហុសឆ្គងពេលចុះបញ្ជីជូនប្រជាពលរដ្ឋមិនបានពេញលេញ ដូចជា៖ ការសរសេរអក្សរមិនច្បាស់ ប្រើប្រាស់ទឹកលុប ខ្វះស្នាមមេដៃ ខ្វះហត្ថលេខា ឬត្រា ជាដើម

-រដ្ឋបាលរាជធានី ខេត្ត មួយចំនួន នៅតែផ្ញើរបាយការណ៍ស្តីពីការចុះបញ្ជីសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងរបាយការណ៍ប្រើប្រាស់ក្រដាស និងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ យឺតយ៉ាវមិនស្របតាមសេចក្តីណែនាំលេខ០០៨ សណន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត។

III. **សន្និដ្ឋាន**

ទោះបីជា នាយកដ្ឋាននៅមានបញ្ហាប្រឈមមួយចំនួនយ៉ាងណាក៏ដោយ នាយកដ្ឋានបានខិតខំ និងបន្តប្រឹងប្រែងថែមទៀតដើម្បីដោះស្រាយ រាល់បញ្ហានានាចំពោះមុខដើម្បីសម្រេចបានស្របទៅតាមផែនការសកម្មភាពការងារដែលបានគ្រោងទុក។

ជាមួយគ្នានោះ យោងតាមផែនការសកម្មភាពការងារ ដែលនាយកដ្ឋានបានគ្រោងទុកក្នុងឆ្នាំ២០២០ នេះ នាយកដ្ឋានបានអនុវត្តដូចខាងក្រោម៖

១-នាយកដ្ឋានបានបើកផ្តល់សៀវភៅអត្រានុកូលដ្ឋានចំនួន៣០,៣៤៧ក្បាល និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៤,០១០,៥០០សន្លឹក ដល់រដ្ឋបាលរាជធានី-ខេត្តដើម្បីបម្រើសេវាជូនប្រជាពលរដ្ឋ

២-បានចុះត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងារអត្រានុកូលដ្ឋាននៅថ្នាក់ក្រោមជាតិបានចំនួន ០៥រាជធានី ខេត្ត នៅសល់០៦ខេត្តទៀតធៀបនឹងផែនការសកម្មភាពការងាររបស់នាយកដ្ឋានឆ្នាំ២០២០

៣-បានចុះស្រាវជ្រាវពាក់ព័ន្ធសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ចំនួន១២លើក តាមការស្នើសុំរបស់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ធៀបនឹងផែនការសកម្មភាពការងារគ្រោងតែ០៨លើកតែប៉ុណ្ណោះ

៤-បានសហការដាក់ឱ្យប្រើប្រាស់សាកល្បងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ដោយប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន នៅខេត្តកែប និងខេត្តកំពត

ដោយឡែកពាក់ព័ន្ធនឹងការបណ្តុះបណ្តាលធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការវាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋាន នាយកដ្ឋានមិនទាន់បានអនុវត្តនៅឡើយទេ ។

IV. **ទិសដៅ**

-បន្តផ្តល់សេវា ជូនប្រជាពលរដ្ឋលើការងារកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

-បន្តជំរុញលើកយោបល់ ស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន តាមការស្នើសុំរបស់ប្រជាពលរដ្ឋ អោយកាន់តែរហ័ស និងទាន់ពេលវេលាស្របតាមសេចក្តីណែនាំលេខ០៤៥ ស្តីពីការបន្តដំណើរការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

-បន្តលើកយោបល់ ពិនិត្យសម្រេច អំពីការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

-ត្រៀមសហការបណ្តុះបណ្តាលស្តីពីកិច្ចការអត្រានុកូលដ្ឋាននៅខេត្តចំនួន០៦ ស្របតាមគោលការណ៍របស់ក្រសួងមហាផ្ទៃ

-ត្រៀមសហការវាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានកំណើតចំនួន២៤៦,៩១៣បញ្ជី ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន ស្របតាមគោលការណ៍របស់ក្រសួងមហាផ្ទៃ

-បន្តពិនិត្យ និងចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមការស្នើសុំរបស់ប្រជាពលរដ្ឋ

-បន្តបើកផ្តល់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ

-បន្តចុះត្រួតពិនិត្យ និងគាំទ្រលើការអនុវត្តការងារអត្រានុកូលដ្ឋាន នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តចុះស្រាវជ្រាវ និងពិនិត្យភាពត្រឹមត្រូវលើសំបុត្រអត្រានុកូលដ្ឋាន នៅតាមបណ្តារាជធានី-ខេត្ត តាមការស្នើសុំពី ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា

-បន្តចុះដឹកសៀវភៅអត្រានុកូលដ្ឋានដែលបានអនុវត្តរួច ពីរាជធានី ខេត្ត

-ត្រៀមសហការបណ្តុះបណ្តាលស្តីពីការដាក់ឱ្យប្រើប្រាស់សាកល្បងប្រព័ន្ធតាមដានឯកសារកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានតាមបណ្តាខេត្តចំនួន១៩

-បន្តលើកយោបល់ និងចុះបញ្ជីអត្រានុកូលដ្ឋានក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិមិនអាចសម្រេចបាន ស្របតាមស្មារតីនៃអនុក្រឹត្យលេខ១៣៤អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

**ប្រធាននាយកដ្ឋាន**

**អេង ចំនួតារា**

បានឃើញ និងគោរពជូន

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក**

**នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

មេត្តាជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**អគ្គនាយករង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
នាយកដ្ឋានអត្រានុកូលដ្ឋាន
លេខ: ១២៩ [illegible]

ថ្ងៃចន្ទ ១២ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០១៩

# របាយការណ៍
## បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩
(គិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ហូតដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩)
## របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សម្រាប់ឆ្នាំ២០១៩

### I. **លិខិតបទដ្ឋាន**

-បានរៀបចំសេចក្តីព្រាងកែសម្រួលសេចក្តីណែនាំលេខ០៣៥សណន របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន។

### II. **លទ្ធផលការងារ**

#### ១.១. លទ្ធផលជាក់ស្តែង

-បានទទួលសាលក្រម និងដីកាសម្រេច ពីសាលាដំបូងរាជធានី ខេត្ត សរុបចំនួន៧១០ច្បាប់

| ល.រ | សាលាដំបូងរាជធានី ខេត្ត | ចំនួន | ល.រ | សាលាដំបូងរាជធានី ខេត្ត | ចំនួន |
|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ៣០៤ | ១១ | ខេត្តឧត្តរមានជ័យ | ០៦ |
| ២ | ខេត្តកណ្តាល | ១៦៧ | ១២ | ខេត្តកំពង់ធំ | ០៥ |
| ៣ | ខេត្តតាកែវ | ៩៣ | ១៣ | ខេត្តបាត់ដំបង | ០៩ |
| ៤ | ខេត្តក្រចេះ | ២១ | ១៤ | ខេត្តកំពង់ស្ពឺ | ០៧ |
| ៥ | ខេត្តកំពត | ២៤ | ១៥ | ខេត្តពោធិ៍សាត់ | ០៤ |
| ៦ | ខេត្តកោះកុង | ១៩ | ១៦ | ខេត្តបន្ទាយមានជ័យ | ០៤ |
| ៧ | ខេត្តកំពង់ចាម | ១៥ | ១៧ | ខេត្តព្រះវិហារ | ០៣ |
| ៨ | ខេត្តព្រៃវែង | ១១ | ១៨ | ខេត្តស្វាយរៀង | ០៣ |
| ៩ | ខេត្តត្បូងឃ្មុំ | ០៧ | ១៩ | ខេត្តកំពង់ឆ្នាំង | ០២ |
| ១០ | ខេត្តសៀមរាប | ០៦ | | | |

-នាយកដ្ឋានទទួលពាក្យស្នើសុំកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានសរុបចំនួន ១៣,០៩២ច្បាប់ (នៅសល់២២៨ច្បាប់) ក្នុងនោះ នាយកដ្ឋានបានទទួលពីប្រជាពលរដ្ឋដែលមកដាក់ពាក្យដោយផ្ទាល់នៅនាយកដ្ឋានចំនួន ៩,៩៩៥ច្បាប់ និងពីរដ្ឋបាលរាជធានី ខេត្ត ចំនួន ៣,០៩៧ច្បាប់។

-នាយកដ្ឋាន បានសម្រេចលើកយោបល់លើការងារកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សរុបបានចំនួន ១៩,៣៩១ច្បាប់

-បានទទួលសេចក្តីសម្រេចស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន ពី **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** សរុបបានចំនួន១៩,០៩២ច្បាប់

-នាយកដ្ឋានបានទទួលពាក្យស្នើសុំកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានពាក់ព័ន្ធសេចក្តីណែនាំលេខ០១៥សណន ស្តីពីការចេញលិខិតរដ្ឋបាល និងលិខិតអត្រានុកូលដ្ឋានឱ្យសហព័ទ្ធជាខ្មែរ កូន និងជនបរទេសអន្តោប្រវេសន្តចំនួន ៤៨ច្បាប់ ក្នុងនោះសម្រេចបាន៣៣ច្បាប់ នៅសល់១៥ច្បាប់ នាយកដ្ឋានកំពុងបន្តចាត់ចែងតាមនីតិវិធី

-បានចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋសរុបចំនួន៣,៧២២ច្បាប់ ស្មើនឹង ១៦,៧០២សន្លឹក ក្នុងនោះរួមមាន៖

| | |
|---|---|
| ១-សេចក្តីចម្លងសំបុត្រកំណើត | ចំនួន៤០០ច្បាប់ ស្មើនឹង ៣,៤៣៧សន្លឹក |
| ២-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ចំនួន៣,១៤៨ច្បាប់ស្មើនឹង១២,៥០៧សន្លឹក |
| ៣-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ចំនួន១៤៦ច្បាប់ ស្មើនឹង ៦២៨សន្លឹក |
| ៤-សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ចំនួន២១ច្បាប់ ស្មើនឹង ១០៣សន្លឹក |
| ៥-សេចក្តីចម្លងសំបុត្រមរណភាព | ចំនួន០៨ច្បាប់ ស្មើនឹង ២៧សន្លឹក |

-បានធ្វើការវាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ឆ្នាំ២០១៩ របស់ខេត្តកំពង់ធំ បានចំនួន ២៧២,៤៧៥បញ្ជី

-បានថតចម្លងគល់បញ្ជីតាមការស្នើរបស់ប្រជាពលរដ្ឋសម្រាប់ចេញសេចក្តីចម្លងសំបុត្រអត្រា-នុកូលដ្ឋានគ្រប់ប្រភេទ និងសម្រាប់ធ្វើការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន សរុបចំនួន ១៦,៧៩៥ច្បាប់

-បានកិបភ្ជាប់ និងកែតម្រូវបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមសេចក្តីសម្រេចស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានចំនួន៣,៧៥៩ច្បាប់

-បានដឹកសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួចពី១៣រាជធានី ខេត្ត សរុបចំនួន២៩,៥៩៤ក្បាល ដែលក្នុងនោះមាន រាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង កែប តាកែវ ស្ទឹងត្រែង ក្រចេះ កំពង់ស្ពឺ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ ព្រះសីហនុ រតនគីរី និងខេត្តកណ្តាល

-បានចូលរួមកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយលទ្ធផលសន្និបាតប្រចាំឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

-បានចុះធ្វើការស្រាវជ្រាវលើសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៥៤ករណី នៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម កណ្តាល ព្រះសីហនុ ព្រះវិហារ កំពត ស្វាយរៀង សៀមរាប និងខេត្តកំពង់ឆ្នាំង

-បានរៀបចំវគ្គបណ្តុះបណ្តាល និងរំលឹកឡើងវិញពី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន និងរបៀបប្រើប្រាស់សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ចំនួន ០៦ខេត្ត មានខេត្តព្រៃវែង កំពត កោះកុង ស្វាយរៀង កំពង់ស្ពឺ និងខេត្តកណ្តាល សិក្ខាកាមចូលរួមសរុប ២,០៤៨នាក់ (ស្រី៧២៦នាក់)

-បានចុះបញ្ជីអត្រានុកូលដ្ឋានកំណើតជូនជនបរទេសដែលកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចំនួន០៨នាក់

-បានចុះបញ្ជីអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើតជូនពលរដ្ឋខ្មែរ និងនិវត្តន៍ជនមកពីសហរដ្ឋអាមេរិក សរុបចំនួន៣៧នាក់

-បានសហការជាមួយនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា រៀបចំកសាងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងតាមដានឯកសារកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន នៅនាយកដ្ឋានអត្រានុកូលដ្ឋាន

-បានទទួលសំណុំឯកសារការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ២,០៥២ច្បាប់

-បានលើកយោបល់ពីការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យសម្រេច សរុបចំនួន២,០២០ច្បាប់ ដែលមាន៣៧ជនជាតិដូចជា៖

| ល.រ | ជនជាតិ | ចំនួន (ច្បាប់) | ល.រ | ជនជាតិ | ចំនួន(ច្បាប់) |
|---|---|---|---|---|---|
| ១ | កូរ៉េ | ៦៤៥ | ២០ | ហ្វីលីពីន | ០៣ |
| ២ | ចិន | ៥៩៥ | ២១ | អូទ្រីស | ០២ |
| ៣ | អាមេរិក | ៤០៨ | ២២ | ទួគី | ០២ |
| ៤ | កាណាដា | ៧៣ | ២៣ | នីហ្សេរីយ៉ា | ០២ |
| ៥ | អូស្ត្រាលី | ៧០ | ២៤ | ហុងគ្រី | ០២ |
| ៦ | បារាំង | ៤៣ | ២៥ | ន័រវេស | ០២ |
| ៧ | ម៉ាឡេស៊ី | ៣៩ | ២៦ | ដាណឺម៉ាក | ០២ |
| ៨ | ជប៉ុន | ២៧ | ២៧ | អាល្លឺម៉ង់ | ០២ |
| ៩ | អង់គ្លេស | ២៥ | ២៨ | បែលហ្ស៊ិក | ០១ |
| ១០ | ញូហ្សីឡែន | ១២ | ២៩ | ស៊ីរី | ០១ |
| ១១ | វៀតណាម | ១៥ | ៣០ | ស៊ុយអែត | ០១ |
| ១២ | ថៃ | ១២ | ៣១ | ស្រីលង្កា | ០១ |
| ១៣ | អ៊ីតាលី | ០៦ | ៣២ | អ៊ីរ៉ង់ | ០១ |
| ១៤ | ឥណ្ឌូនេស៊ី | ០៥ | ៣៣ | ប៉ូឡូញ | ០១ |
| ១៥ | ហូឡង់ | ០៥ | ៣៤ | អៀឡង់ | ០១ |
| ១៦ | ឥណ្ឌា | ០៤ | ៣៥ | ហ្វីជី | ០១ |
| ១៧ | ប៊ុលហ្គារី | ០៣ | ៣៦ | ឆែក | ០១ |
| ១៨ | សិង្ហបុរី | ០៣ | ៣៧ | នេប៉ាល់ | ០១ |
| ១៩ | ស្វីស | ០៣ | | | |

-ការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត បានចំនួនសរុប ៥០៨,៥៨៨នាក់ (ស្រី២៤៥,៨១៨នាក់) ក្នុងនោះរួមមាន៖

១-បញ្ជីកំណើត ចំនួន ១៤៧,៩៨២នាក់(ស្រី៧០,២៩៣នាក់)

២-បញ្ជីបញ្ជាក់កំណើត ចំនួន ២១២,៧០៥នាក់(ស្រី១០៣,៥៧១នាក់)

៣-បញ្ជីអាពាហ៍ពិពាហ៍រវាងខ្មែរ និងខ្មែរ ចំនួន ៥៥,៨១៩គូ

៤-បញ្ជីអាពាហ៍ពិពាហ៍រវាងខ្មែរ និងបរទេស ចំនួន ១,០៨២គូ

៥-បញ្ជីមរណភាព ចំនួន ៣៤,០៩៥នាក់ (១៥,០៥៣នាក់)

-ការចុះបញ្ជីអត្រានុកូលដ្ឋានកំណើតដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានចុះបញ្ជីជូនប្រជាពលរដ្ឋដល់មណ្ឌលសុខភាព និងតាមខ្នងផ្ទះផ្ទាល់ដែលអនុវត្តដោយរដ្ឋបាលរាជធានី ខេត្តចំនួន១០ គឺនៅខេត្តប៉ៃលិន សៀមរាប ក្រចេះ កំពង់ចាម កណ្តាល បាត់ដំបង កំពត កំពង់ធំ ព្រៃវែង និងខេត្តត្បូងឃ្មុំ

-គិតចាប់ឆ្នាំ២០០២ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ របាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទមកក្រសួងមហាផ្ទៃ សរុបចំនួន **១៨,៨៣១,២៣៨នាក់** ស្រីចំនួន **៨,៩៦៣,១៥៣នាក់** ក្នុងនោះមាន៖

| ល.រ | បញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ | ចំនួន | ផ្សេង |
|---|---|---|---|
| ១ | បញ្ជីកំណើត | ២,៩០៤,២២២នាក់ | ស្រី ១,០៧៥,៨៤០នាក់ |
| ២ | បញ្ជីបញ្ជាក់កំណើត | ១៤,១៥០,១០៧នាក់ | ស្រី ៧,០៣១,០២២នាក់ |
| ៣ | បញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ | ១១៦,១៤៨គូ | ស្រី ១១៦,១៤៨នាក់ |
| ៤ | អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងខ្មែរ | ៦០៣,៣៦៦គូ | ស្រី ៦០៣,៣៦៦នាក់ |
| ៥ | អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស | ៩,៥៥៥គូ | ស្រី ៩,៥៥៥នាក់ |
| ៦ | បញ្ជីបញ្ជាក់មរណភាព | ១៣,២៥០នាក់ | ស្រី ៤,១១៣នាក់ |
| ៧ | បញ្ជីមរណភាព | ៣០៥,០៥៩នាក់ | ស្រី ១២៤,១២៤នាក់ |
| ៨ | កំណើតជនបរទេស | ១៧៩នាក់ | |
| ៩ | អាពាហ៍ពិពាហ៍ជនបរទេស | ៣៦គូ | |
| ១០ | មរណភាពជនបរទេស | ២១១នាក់ | |

-គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃ១៩ ខែធ្នូ ឆ្នាំ២០១៩ នាយកដ្ឋានបានបើកផ្តល់សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋាន សរុបចំនួន ១៩,១២៧ក្បាល និង២,៤៤៦,០០០សន្លឹក ជូនរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម បាត់ដំបង ប៉ៃលិន កោះកុង ព្រះសីហនុ ស្វាយរៀង សៀមរាប ស្ទឹងត្រែង ក្រចេះ បន្ទាយមានជ័យ កែប និងខេត្តត្បូងឃ្មុំ មានចំនួនដូចខាងក្រោម៖

❖ **សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ**

១-សៀវភៅកំណើត ចំនួន ៤,៧៨២ក្បាល

២-សៀវភៅបញ្ជាក់កំណើត ចំនួន ៥,១៧៤ក្បាល

៣-សៀវភៅចម្លងសំបុត្រកំណើត និង
សំបុត្របញ្ជាក់កំណើត ចំនួន ១,២១៦ក្បាល

៤-សៀវភៅអាពាហ៍ពិពាហ៍ ចំនួន ៣,៧៧២ក្បាល

៥-សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង
សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ចំនួន ២០០ក្បាល

៦-សៀវភៅមរណភាព ចំនួន ៣,៤៤២ក្បាល

៧-សៀវភៅចម្លងសំបុត្រមរណភាព និង
សំបុត្របញ្ជាក់មរណភាព ចំនួន ៥៤១ក្បាល

សរុប ចំនួន ១៩,១២៧ក្បាល

❖ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ

| | | |
|---|---|---|
| ១-សំបុត្រកំណើត | ចំនួន | ២២២,០០០សន្លឹក |
| ២-សេចក្តីចម្លងសំបុត្រកំណើត (ក្នុងឆ្នាំ) | ចំនួន | ១៧៥,៥០០សន្លឹក |
| ៣-សេចក្តីចម្លងសំបុត្រកំណើត (ឆ្លងឆ្នាំ) | ចំនួន | ២៤៧,០០០សន្លឹក |
| ៤-សំបុត្របញ្ជាក់កំណើត | ចំនួន | ២០១,០០០សន្លឹក |
| ៥-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត(ក្នុងឆ្នាំ) | ចំនួន | ២១២,៥០០សន្លឹក |
| ៦-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត(ឆ្លងឆ្នាំ) | ចំនួន | ៦៨៦,០០០សន្លឹក |
| ៧-សំបុត្រអាពាហ៍ពិពាហ៍ | ចំនួន | ១៣៦,៥០០សន្លឹក |
| ៨-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ក្នុងឆ្នាំ) | ចំនួន | ១៤៥,៥០០សន្លឹក |
| ៩-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ឆ្លងឆ្នាំ) | ចំនួន | ១២៣,០០០សន្លឹក |
| ១០-សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ចំនួន | ៣,០០០សន្លឹក |
| ១១-សំបុត្រមរណភាព | ចំនួន | ៩០,៥០០សន្លឹក |
| ១២-សេចក្តីចម្លងសំបុត្រមរណភាព(ក្នុងឆ្នាំ) | ចំនួន | ៩៦,៥០០សន្លឹក |
| ១៣-សេចក្តីចម្លងសំបុត្រមរណភាព(ឆ្លងឆ្នាំ) | ចំនួន | ៦៧,០០០សន្លឹក |
| ១៤-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | ចំនួន | ៤០,០០០សន្លឹក |
| សរុប | ចំនួន | ២,៤៤៦,០០០សន្លឹក |

III. **បញ្ហាប្រឈម**

-មន្ត្រីដែលបម្រើការនៅនាយកដ្ឋានអត្រានុកូលដ្ឋាន មានចំនួនតិច មិនស្របទៅតាមការងាររបស់នាយកដ្ឋាន ជាពិសេសលើការផ្តល់សេវាជូនប្រជាពលរដ្ឋ

-ទីតាំងតូចចង្អៀត សម្រាប់ការផ្តល់សេវាជូនប្រជាពលរដ្ឋ ជាពិសេសការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន និងការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ជូនប្រជាពលរដ្ឋ

-មិនមានថវិកាសម្រាប់ធ្វើការថែទាំ និងជួសជុលសម្ភារបរិក្ខាក្នុងនាយកដ្ឋានដែលមានដូចជាម៉ាស៊ីនថតចម្លង ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនត្រជាក់ ឬកុំព្យូទ័រ ជាដើម

-របាយការណ៍ស្តីពីការចុះបញ្ជីសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងរបាយការណ៍ប្រើប្រាស់ក្រដាស និងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទពីរដ្ឋបាលរាជធានី ខេត្ត នៅតែមានការយឺតយ៉ាវ និងមិនបានទៀងទាត់។

IV. **សន្និដ្ឋាន**

ទោះបីជា នាយកដ្ឋាននៅមានបញ្ហាប្រឈមមួយចំនួនយ៉ាងណា នាយកដ្ឋាននឹងបន្តខិតខំ ប្រឹងប្រែងដោះស្រាយ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ និងសម្រេចឱ្យបានតាមផែនការសកម្មភាពដែលនាយកដ្ឋានបានគ្រោងទុក។

V. **ទិសដៅ**

-រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងាររបស់នាយកដ្ឋានក្នុងឆ្នាំ២០២០

-បន្តលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេចលើការងារកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន តាមការស្នើសុំរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត

-បន្តលើកយោបល់ ពិនិត្យសម្រេច អំពីការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

-បន្តពិនិត្យ និងចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមការស្នើសុំរបស់ប្រជាពលរដ្ឋ

-បន្តចុះស្រាវជ្រាវ និងតាមដានត្រួតពិនិត្យ និងវាយតំលៃ ការអនុវត្តការងារអត្រានុកូលដ្ឋាននៅតាមបណ្តារាជធានី ខេត្ត

-បន្តធ្វើការបណ្តុះបណ្តាលស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាន និងការប្រើប្រាស់សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលប្រើប្រាស់ដោយមេភូមិ នៅតាមរាជធានី ខេត្ត គោលដៅ

-បន្តដឹកសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួចពីរាជធានី ខេត្ត

-បន្តវាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា

-បន្តកសាងសមត្ថភាពដល់មន្ត្រីនៅក្នុងនាយកដ្ឋានអត្រានុកូលដ្ឋាន

-សហការជាមួយនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាលនៃនាយកដ្ឋានអត្រានុកូលដ្ឋាន ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដល់ពលរដ្ឋខ្មែរនៅតាមស្ថានទូត និងប្រព័ន្ធគ្រប់គ្រងសៀវភៅអត្រានុកូលដ្ឋាន។

**ប្រធាននាយកដ្ឋាន**

សេង ម៉ិន្ទភារ

បានឃើញ និងគោរពជូន

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

មេត្តាជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**អគ្គនាយករង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
នាយកដ្ឋានអត្រានុកូលដ្ឋាន
លេខ:១៣៧.រឃត.អរក

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៨

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨

(គិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ហូតដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨)

## របស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

I. **លទ្ធផលការងារ**

**១.១. លទ្ធផលជាក់ស្តែង**

-នាយកដ្ឋានបានទទួលលិខិតចូលក្នុងឆ្នាំ២០១៨នេះសរុបចំនួន ៣២៣ច្បាប់ និងបានសម្រេចលិខិតចេញចំនួន៤៩៣ច្បាប់

-នាយកដ្ឋានទទួលពាក្យស្នើសុំកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានសរុបចំនួន ១៧,១១៣ច្បាប់ ក្នុងនោះ នាយកដ្ឋានបានទទួលពីសំណាក់ប្រជាពលរដ្ឋដែលមកដាក់ពាក្យដោយផ្ទាល់នៅនាយកដ្ឋានចំនួន ៨,៩៧៥ច្បាប់ និងពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត ចំនួន ៨,១៣៨ច្បាប់

-បានជំរុញឯកសារស្តីពីការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មសរុបចំនួន ៩,១៨១ច្បាប់

១-សេចក្តីសម្រេចស្តីពីការកែតម្រូវទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានចំនួន ៧,៩២៣ច្បាប់

២-សេចក្តីសម្រេចស្តីពីការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានចំនួន ២០០ច្បាប់

៣-សេចក្តីសម្រេចស្តីពីការដកហូតសំបុត្រអត្រានុកូលដ្ឋានចំនួន ២៧ច្បាប់

៤-សាមីខ្លួនបានមកដកពាក្យស្នើសុំចំនួន ៥០ច្បាប់

៥-បានបញ្ជូនឯកសារត្រលប់ទៅរាជធានី ខេត្ត ដែលមិនអាចអនុញ្ញាតឱ្យកែតម្រូវ និងមោឃភាព និងតម្រូវឱ្យសាមីខ្លួនបំពេញឯកសារយោងបន្ថែមចំនួន ៩៨១ច្បាប់

-បានទទួលសាលក្រម និងដីកាសម្រេច ពីសាលាដំបូងរាជធានី ខេត្ត សរុបចំនួន៧៩៦ច្បាប់

| ល.រ | សាលាដំបូងរាជធានី ខេត្ត | ចំនួន (ច្បាប់) | ល.រ | សាលាដំបូងរាជធានីខេត្ត | ចំនួន (ច្បាប់) |
|---|---|---|---|---|---|
| ១ | សាលាដំបូងរាជធានីភ្នំពេញ | ២៨៦ | ៩ | សាលាដំបូងខេត្តស្វាយរៀង | ០៤ |
| ២ | សាលាដំបូងខេត្តពោធិ៍សាត់ | ២០៣ | ១០ | សាលាដំបូងខេត្តបន្ទាយមានជ័យ | ០២ |
| ៣ | សាលាដំបូងខេត្តកណ្តាល | ១៩៤ | ១១ | សាលាដំបូងខេត្តព្រះវិហារ | ០២ |
| ៤ | សាលាដំបូងខេត្តតាកែវ | ៦៣ | ១២ | សាលាដំបូងខេត្តកំពង់ស្ពឺ | ០២ |
| ៥ | សាលាដំបូងខេត្តកំពង់ឆ្នាំង | ១៥ | ១៣ | សាលាដំបូងខេត្តប៉ៃលិន | ០១ |
| ៦ | សាលាដំបូងខេត្តកំពត | ១០ | ១៤ | សាលាដំបូងខេត្តកោះកុង | ០១ |
| ៧ | សាលាដំបូងខេត្តក្រចេះ | ០៦ | ១៥ | សាលាដំបូងខេត្តកំពង់ធំ | ០១ |
| ៨ | សាលាដំបូងខេត្តកំពង់ចាម | ០៥ | ១៦ | សាលាដំបូងខេត្តសៀមរាប | ០១ |

-បានចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមការស្នើសុំរបស់ប្រជាពលរដ្ឋ សរុបចំនួន ៥,០២៤ច្បាប់ ស្មើនឹង ៣០,១៤៤សន្លឹក ក្នុងនោះមាន៖

១-សេចក្តីចម្លងសំបុត្រកំណើតចំនួន ៦៣៦ច្បាប់ ស្មើនឹង ៣,៨១៦សន្លឹក

២-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតចំនួន ៤,១៦៩ច្បាប់ ស្មើនឹង ២៥,០២៤សន្លឹក

៣-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន១៦១ច្បាប់ ស្មើនឹង ៩៦៦សន្លឹក

៤-សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចំនួន ៤០ច្បាប់ ស្មើនឹង ២៤០សន្លឹក

៥-សេចក្តីចម្លងសំបុត្រមរណភាពចំនួន ១៤ច្បាប់ ស្មើនឹង ៨៤សន្លឹក

៦-សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពចំនួន ០៤ច្បាប់ ស្មើនឹង ២៤សន្លឹក

-បានចុះដឹកសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួចពីខណ្ឌចំការមន ខណ្ឌជ្រោយចង្វារ ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង ខេត្តកំពត និងខេត្តកំពង់ចាម មកតម្កល់ទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សរុប ១២,១៤០ក្បាល

-បានចុះស្រាវជ្រាវអំពីភាពមិនប្រក្រតីលើសំបុត្រអត្រានុកូលដ្ឋានចំនួន ៥៥ករណី នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តបាត់ដំបង ក្នុងនោះ៖

១-នាយកដ្ឋានបានស្រាវជ្រាវឃើញថាជាសំបុត្រដែលមានទិន្នន័យត្រឹមត្រូវ ចំនួន១៧ករណី

២-នាយកដ្ឋានកំពុងស្រាវជ្រាវបន្ត ចំនួន២១ករណី

៣-នាយកដ្ឋានស្រាវជ្រាវឃើញថាជាសំបុត្រដែលគ្មានចុះក្នុងគល់បញ្ជីទេចំនួន ០២ករណី

៤-នាយកដ្ឋានស្រាវជ្រាវឃើញថាជាសំបុត្រដែលមិនបានចុះត្រឹមត្រូវតាមនីតិវិធីចំនួន ១៥ករណី

-ចំពោះ០៨ករណីដែលអគ្គស្នងការដ្ឋាន បានបញ្ជូនមកអគ្គនាយកដ្ឋាន ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ នាយកដ្ឋានពុំមានទិន្នន័យ ដើម្បីស្រាវជ្រាវទេ ព្រោះគ្មានភ្ជាប់សំបុត្រអត្រានុកូលដ្ឋានមកជាមួយ

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការកត់ត្រាការងារអត្រានុកូលដ្ឋាន និងរបៀបប្រើប្រាស់សៀវភៅស្រង់ស្ថិតិកំណើត អាពាហ៍ពិពាហ៍ និងមរណភាពដែលប្រើប្រាស់ដោយមេភូមិ នៅខេត្តបាត់ដំបង ខេត្តកំពត ខេត្តកែប ខេត្តតាកែវ ខេត្តកំពង់ចាម និងខេត្តព្រៃវែង ដែលមានសិក្ខាកាមចូលរួមចំនួន ១,៣៥១នាក់ (ស្រី១៨២នាក់)

-បានបណ្តុះបណ្តាលមន្ត្រីបម្រើការងារនៅនាយកដ្ឋានអត្រានុកូលដ្ឋានស្តីពីការងារអត្រានុកូលដ្ឋាន នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៨ មានសិក្ខាកាមចូលរួមចំនួន ៣៩នាក់ (ស្រី១២នាក់)

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន និងការងារអត្រានុកូលដ្ឋាន ដល់ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុទាំង២៥រាជធានី ខេត្ត នាថ្ងៃទី១៩-២០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលប្រជុំអគារA (ជាន់ទី៣) អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលមានសិក្ខាកាមចូលរួមចំនួន ២២៥នាក់ (ស្រី៧៣នាក់)

-បានចុះបំពេញបេសកកម្មនៅខេត្តកោះកុង ដើម្បីធ្វើការបញ្ជាក់អំពីសញ្ជាតិរបស់ប្រជាពលរដ្ឋ ចំនួន១២៣នាក់ ដែលមានទីកន្លែងកំណើតនៅខេត្តកោះកុង តែបានស្នាក់នៅប្រទេសថៃ

-បានចុះនៅតាមបណ្តាខណ្ឌនៃរាជធានីភ្នំពេញ និងខេត្ត ដូចជាខណ្ឌពោធិ៍សែនជ័យ ៧មករា សែនសុខ ព្រែកព្នៅ ជ្រោយចង្វារ ឫស្សីកែវ និងខណ្ឌដង្កោ ខេត្តស្ទឹងត្រែង តាកែវ បាត់ដំបង បន្ទាយមានជ័យ និងខេត្តកណ្តាល តាមដានត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រកិច្ចការអត្រានុកូលដ្ឋាន

-បានទទួលសំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសសរុប ចំនួន ១,៥៧៣ច្បាប់

-បានលើកកំណត់បង្ហាញនិងរៀបចំសេចក្តីសម្រេចក្នុងនាមមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិស្តីពីការស្នើសុំរៀបអាពាហ៍ពិពាហ៍ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យសម្រេច សរុបចំនួន ១,៩១៨ច្បាប់។

-គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ របាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន គ្រប់ប្រភេទមកក្រសួងមហាផ្ទៃ សរុបចំនួន ៤៦៨,១៤៦នាក់ ស្រីចំនួន ២៣០,៥៨៦នាក់ ក្នុងនោះមានៈ

| **ល.រ** | **បញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ** | **ចំនួន** | **ផ្សេង** |
|---|---|---|---|
| ១ | បញ្ជីកំណើត | ១២៦,៩០៣នាក់ | (ស្រី៦២,១៨២នាក់) |
| ២ | បញ្ជីបញ្ជាក់កំណើត | ២០៦,០៣៤នាក់ | (ស្រី ១០២,៨៦៨នាក់) |
| ៣ | អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងខ្មែរ | ៥១,៣៤៧គូ | |
| ៤ | អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស | ១,៥៧១គូ | |
| ៥ | បញ្ជីមរណភាព | ២៩,៣៦៥នាក់ | (ស្រី១២,៦១៨នាក់) |
| ៦ | កំណើតជនបរទេស | ០៨នាក់ | |

-បានបើកសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានជូនរាជធានី ខេត្ត សរុបសំបុត្រអត្រានុកូលដ្ឋានចំនួន **៥,៥៥៩,៥០០សន្លឹក** និងសៀវភៅអត្រានុកូលដ្ឋានចំនួន **៥៥,២៦៥ក្បាល** ក្នុងនោះៈ

សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទមានដូចខាងក្រោម:

១-សៀវភៅកំណើត ចំនួន ១៣,៨០០ក្បាល
២-សៀវភៅបញ្ជាក់កំណើត ចំនួន ១៥,១២១ក្បាល
៣-សៀវភៅចម្លងសំបុត្រកំណើត និង
សៀវភៅចម្លងសំបុត្របញ្ជាក់កំណើត ចំនួន ២,៤២៥ក្បាល
៤-សៀវភៅអាពាហ៍ពិពាហ៍ ចំនួន ១០,៩៨០ក្បាល
៥-សៀវភៅចម្លងអាពាហ៍ពិពាហ៍ និង
សៀវភៅចម្លងបញ្ជាក់អាពាហ៍ពិពាហ៍ ចំនួន ៨៣៥ក្បាល
៦-សៀវភៅមរណភាព ចំនួន ១១,៤០៦ក្បាល
៧-សៀវភៅចម្លងមរណភាព និង
សៀវភៅចម្លងបញ្ជាក់មរណភាព ចំនួន ៦៥០ក្បាល
៨-សៀវភៅកំណើតជនបរទេស ចំនួន ២៤ក្បាល
៩-សៀវភៅមរណភាពជនបរទេស ចំនួន ២៤ក្បាល

**សរុបសៀវភៅអត្រានុកូលដ្ឋាន ចំនួន ៥៥,២៦៥ក្បាល**

សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទមានដូចខាងក្រោម:

១-សំបុត្រកំណើត ចំនួន ៤៦៥,៥០០សន្លឹក
២-សេចក្តីចម្លងសំបុត្រកំណើត(ក្នុងឆ្នាំ) ចំនួន ៤៤១,០០០សន្លឹក
៣-សេចក្តីចម្លងសំបុត្រកំណើត(ផ្លូងឆ្នាំ) ចំនួន ៣៨៨,០០០សន្លឹក
៤-សំបុត្របញ្ជាក់កំណើត ចំនួន ៥៣៧,៥០០សន្លឹក
៥-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ក្នុងឆ្នាំ) ចំនួន ៤៧៣,៥០០សន្លឹក
៦-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ផ្លូងឆ្នាំ) ចំនួន ១,៣៩៨,០០០សន្លឹក

៧-សំបុត្រអាពាហ៍ពិពាហ៍ ចំនួន ៣១៨,០០០សន្លឹក
៨-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ក្នុងឆ្នាំ) ចំនួន ៣៣០,៥០០សន្លឹក
៩-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ឆ្លងឆ្នាំ) ចំនួន ២៧៥,០០០សន្លឹក
១០-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ចំនួន ២៣០,៥០០សន្លឹក
១១-សំបុត្រមរណភាព ចំនួន ២៤២,៥០០សន្លឹក
១២-សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំ) ចំនួន ២៦៣,០០០សន្លឹក
១៣-សេចក្តីចម្លងសំបុត្រមរណភាព (ឆ្លងឆ្នាំ) ចំនួន ១៩៦,៥០០សន្លឹក
**សរុបសំបុត្រអត្រានុកូលដ្ឋាន ចំនួន ៥,៥៥៩,៥០០សន្លឹក**

## II. បញ្ហាប្រឈម

-មន្ត្រីដែលបម្រើការនៅនាយកដ្ឋានអត្រានុកូលដ្ឋាន មានចំនួនតិច មិនស្របទៅតាមទំហំការងាររបស់នាយកដ្ឋាន (មន្ត្រី០២រូបទើប ផ្លាស់ប្តូរអង្គភាពបម្រើការងារ)

-ខ្វះខាតសម្ភារការិយាល័យសម្រាប់បម្រើការងារនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ដែលមានដូចជា៖ ក្រដាសរ៉ាម សឺមី អាតាស ទឹកថ្នាំ និងDrum ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនព្រីនធ័រ ខ្វះទូសម្រាប់ទុកដាក់ឯកសារ

-ម៉ាស៊ីនហ្វូតូកូពី និងម៉ាស៊ីនព្រីនធ័រនៅនាយកដ្ឋានអត្រានុកូលដ្ឋាន ចាស់ និងយឺត ដែលលំបាកក្នុងការបំពេញការងារឱ្យបានទាន់ពេលកំណត់

-របាយការណ៍ស្តីពីការចុះបញ្ជីសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ និងរបាយការណ៍ប្រើប្រាស់សំបុត្រ និងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ មានការយឺតយ៉ាវ ជាហេតុធ្វើឱ្យនាយកដ្ឋានមិនមានទិន្នន័យគ្រប់គ្រាន់ក្នុងការធ្វើរបាយការណ៍ជូនអគ្គនាយកដ្ឋាន និងតាមឃុំ-សង្កាត់មួយចំនួនមិនមានសំបុត្រ និងក្រដាសអត្រានុកូលដ្ឋាន បណ្តាលមកពីអាជ្ញាធរខេត្ត មិនសូវយកចិត្តទុកដាក់លើបញ្ហាអត្រានុកូលដ្ឋាន។

## III. សំណូមពរ

-ស្នើសុំថវិកាសម្រាប់ថែទាំ និងជួសជុលម៉ាស៊ីនហ្វូតូកូពី និងម៉ាស៊ីនព្រីនធ័រ

-ស្នើសុំសម្ភារការិយាល័យដើម្បីបន្តនិរន្តភាពការងាររបស់នាយកដ្ឋាន

## IV. ទិសដៅ

-បន្តធ្វើកំណត់បង្ហាញការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន តាមការស្នើសុំរបស់ប្រជាពលរដ្ឋ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត

-បន្តពិនិត្យ និងផ្តល់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទតាមការស្នើសុំរបស់ប្រជាពលរដ្ឋ

-បន្តចុះស្រាវជ្រាវលើសំបុត្រអត្រានុកូលដ្ឋាននៅរាជធានី ខេត្ត តាមការស្នើសុំរបស់ស្ថានទូត ស្ថានកុងស៊ុល តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានលិខិតឆ្លងដែន តាមការស្នើសុំ

-បន្តលើកយោបល់ អំពីការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

**ប្រធាននាយកដ្ឋាន**

ស៊េង ចិន្តាភា